ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ប៉ុល ពត ដើរចេញពីផ្ទះ
- ១៧មេសា កម្ពុជារំដោះ

លេខ១៦ ខែមេសា ឆ្នាំ២០០១

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៤ ខែមេសា ឆ្នាំ២០០០



តើនរណាជាអ្នកសម្លាប់ក្រុមគ្រួសារខ្ញុំ?

**មាតិកា**


- សំបុត្រៈ ប៉ុល ពត ដើរចេញពីផ្លូវ............................. ១

**ផ្នែកឯកសារ**

- វាយរំដោះទីក្រុងភ្នំពេញ............................................ ២
- ខ្លឹមសារនៃពិធីបុណ្យ.................................................. ៥
- បងស្រី ប៉ុល ពត ............................................. ៦
- ចម្លើយសារភាពៈ ប្រវត្តិអ្នកទោសអគ្គការ...................... ៩
- ប្រវត្តិរូប ដួន ប្រាសិទ្ធ.......................................... ១២
- ភូមិចន្ទ្រាធ្លាក់ក្នុងវិនាសកម្មនៃសង្គ្រាម.............................. ១៥
- ប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ...................................... ១៩
- អណ្តូងសាកសពជនរងគ្រោះ.......................................... ២៤

**ផ្នែកប្រវត្តិសាស្ត្រ**

- សម្ងេងពីមន្ទីរស-២១............................................... ២៦
- គ្រោះថ្នាក់នៃអព្យាក្រឹតភាព........................................ ៣១

**ផ្នែកច្បាប់**

- គំរូមួយនៃភ័ស្តុតាងឯកសារ......................................... ៣៥
- ដំណើរការច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម............................. ៣៨

**វេទិកាពិភាក្សាជាសាធារណៈ**

- ហេតុអ្វីត្រូវតែមានការចូលរួមពីអគ្គការសហប្រជាជាតិ......... ៤១
- ម្ភៃប្រាំឆ្នាំក្រោយស្រមោលនៃការពិត............................. ៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- មាស សារិន បានដឹងអំពីជោគវាសនារបស់បងប្អូន......... ៤៩
- លិខិតស្វែងរកដំណឹងអំពីឪពុក....................................... ៥៣
- គ្រួសាររបស់ខ្ញុំក្រោមរបប ប៉ុល ពត.......................... ៥៤
- កោះខ្សាច់ទន្លេ កោះស្ត្រីមេម៉ាយ................................. ៥៨

**សិល្បៈខ្មែរក្រហម**

- ១៧ មេសា កម្ពុជារំដោះ.......................................ក្របក្រោយ


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម.៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ** ជូម៉ាស់ ហាម៉ាប៊ឺក, គ្រេក អេចឆេសាន់, សាស្ត្រាចារ្យ ដេវីត ឆេនដល័រ, មៃឃើល ស៊ីព័រ, យែនគុន ក្លែមម័រ, សាស្ត្រាចារ្យ ស៊ីវ ហេឌ័រ, រស់ សមណ្ឌរៈវុឌ្ឍិ, ម៉ម កល្យានី **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុឃឹម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

***សំបុត្រ:***

# ប៉ុល ពត ដើរចេញពីផ្លូវ

ប៉ុល ពត ស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ។ ក៏ប៉ុន្តែការស្លាប់របស់ ប៉ុល ពត គឺពុំមែនជាការបិទនូវទំព័រប្រវត្តិសាស្ត្រដ៏គួរឲ្យភ័យរន្ធត់ដែលមានមនុស្សជាង១លាននាក់បានបាត់បង់ជីវិតនោះទេ ។ ហើយការស្លាប់នេះទៀតសោត ក៏ពុំមែនបញ្ជាក់ពីភាពបរាជ័យទាំងស្រុងនៃរបបខ្មែរក្រហមដែរ ។ ក្រុមមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ «មានន័យថា បក្ខជន (ឬជនបង្គោល) នៃបក្សកុម្មុយនិស្តកម្ពុជាដែលជាសមាជិកពេញសិទ្ធិ និងសមាជិកត្រៀមនៃគណៈកម្មាធិការអចិន្ត្រៃយ៍និងគណៈកម្មាធិការមជ្ឈិម» ដែលបានរៀបចំឬចូលរួមក្នុងការបង្កើតគោលនយោបាយ ដែលបណ្តាលឲ្យមានការកាប់សម្លាប់មនុស្សយ៉ាងរង្គាល ហើយនិងទាហានខ្មែរក្រហមរាប់ពាន់នាក់ទៀត កំពុងតែជ្រកកោននៅក្រោមរូបភាពផ្សះផ្សាជាតិ និងគេចវេះពីការប្រឈមមុខនឹងជនរងគ្រោះ និងការដាក់ទោសដោយច្បាប់នៅចំពោះមុខសង្គម និងប្រវត្តិសាស្ត្រកម្ពុជា ។ មេខ្មែរក្រហមផ្តាច់ខ្លួនទាំងនោះ ទោះបីមានឈាមជ័រជាខ្មែរដូចជនរងគ្រោះ ក៏នៅតែជាក្រុមមនុស្សមួយក្រុមដែលខួរក្បាលត្រូវបានដុសខាត់ និងសម្រួចដោយមនោគមន៍វិជ្ជា ប៉ុល ពត ហើយមួយចំនួនដែលជាថ្នាក់ដឹកនាំកំពូលបានបង្កការសម្លាប់ ឬចូលរួម ឬសមគំនិត ធ្វើទារុណកម្មដល់មនុស្សដែលខ្លួនយល់ថាជា «ខ្មាំងរបស់អង្គការ» ។ មនោគមន៍វិជ្ជាដែលពន្យកមនុស្សឲ្យសម្លាប់ «ខ្មាំងអង្គការ» ក្រោមទ្រឹស្តី «ដឹកស្មៅត្រូវដឹកទាំងឫស» ឬ «ទុកក៏មិនចំណេញដកចេញក៏មិនខាត» កំពុងជះឥទ្ធិពលមកលើសង្គមកម្ពុជាបច្ចុប្បន្ន និងកំពុងរារាំងទប់ស្កាត់ការកសាងកម្ពុជានៅក្រោមវិធានច្បាប់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។ មនោគមន៍វិជ្ជានេះនៅជិតជាប់យ៉ាងជ្រៅនៅក្នុងខួរក្បាលរបស់ពួកនេះ ។ វាគឺជាដៃគូអរូបរបស់អតីតមេដឹកនាំខ្មែរក្រហមមួយចំនួនដែលបានផ្តាច់ខ្លួន ហើយខ្លះទៀតដែលកំពុងកាន់កាប់កិច្ចការរាជរដ្ឋាភិបាលកម្ពុជា និងយោធា ដែលមានតួនាទីជាអ្នកសម្រេច ឬដាក់ចុះនូវការផ្សារដឹកនាំសង្គមកម្ពុជា ។ ប៉ុល ពត ស្លាប់រលាយរូបកាយមែនពិត ប៉ុន្តែនៅរស់ជាមេព្រាយ អសុរកាយនៃសតិអារម្មណ៍ និងមនោគមន៍វិជ្ជា និងនៅតែកំពុងគំរាមមេខ្មែរក្រហមផ្តាច់ខ្លួនឲ្យបន្តអនុវត្តនូវគោលនយោបាយ «ធ្វើសង្គមឲ្យបរិសុទ្ធ» ឲ្យបានសម្រេចមួយរយភាគរយ និងមហាលោតផ្លោះ មហាអស្ចារ្យ ។


ប៉ុល ពត

© រូបថតឯកសារ Peter H. Maguire

សមាជិករាជរដ្ឋាភិបាលកម្ពុជា បុគ្គលជាតំណាងរាស្ត្រមកពីគណបក្សទាំងបីដែលមានអសនៈនៅក្នុងសភា និងព្រឹទ្ធសភាជាតិ មានកាតព្វកិច្ចពីរដើម្បីដោះស្រាយបញ្ហាខាងលើគឺ ១-ដាក់ទណ្ឌកម្មដល់មេដឹកនាំខ្មែរក្រហមទាំងឡាយណាដែលបានដឹកនាំបង្កើត ឬគាំទ្រគោលនយោបាយ ហើយដែលបានជំរុញកម្មាភិបាលថ្នាក់ក្រោមឲ្យអនុវត្តផែនការ ឈានទៅដល់ការកាប់សម្លាប់មនុស្សតាមរយៈតុលាការឯករាជ្យមួយ ដោយគោរពតាមបទដ្ឋានជាអន្តរជាតិ និង២-ផ្តល់សេវាកម្មឲ្យបានទាន់ពេលវេលាដល់ក្រុមគ្រួសារយោធាខ្មែរក្រហមទាំងអស់ ជាពិសេស **(តទៅទំព័រទី១៨)**

# ទិវារំដោះទីក្រុងភ្នំពេញ

**(ដកស្រង់តាមសំណៅដើមទាំងស្រុងពីឯកសារ D ០០៧១០)**

***ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥៖*** *ជាថ្ងៃដែលរបបសាធារណរដ្ឋខ្មែរបរាជ័យ ជាថ្ងៃបក្សខ្មែរក្រហមទទួលជោគជ័យ ។*

## ១. សកម្មភាពកងទ័ព

***សាធារណរដ្ឋខ្មែរ៖*** *ភ្នំពេញ៖ ១៧-៤-៧៥៖ ០៥ម៉ ០០*

*- ម៉ោង ០១:០០នាទី មានរថយន្តហ្សីប អាឌី ពីរគ្រឿង មានចងក្រណាត់សជាសញ្ញាសន្តិភាពរបស់កងពលធំលេខ 3ème D.I បើកតាមខ្សែក្រវាត់ក្រុងភ្នំពេញ ប្រកាសថា ថ្ងៃនេះជាថ្ងៃសន្តិភាពរបស់ខ្មែរ ពួកយើងត្រូវតែទម្លាក់អាវុធចរចារវាងគូភាគីទទួលសន្តិភាព យើងគ្រប់គ្នាត្រូវលើកទង់សសញ្ញាសន្តិភាព ។*

*- ម៉ោង ០១:៣០នាទី បញ្ជាពីលោកឧត្តមសេនីយ៍ លន់ ណុន កាំភ្លើងធំ 105 M/M ត្រូវបាញ់ភ្លើងជាសញ្ញាទទួលសន្តិភាព ។*

*- ម៉ោង ០២:៤៥នាទី ខ្សែត្រៀមក្រវាត់ក្រុងភ្នំពេញត្រូវតែចេញទាំងអស់ហើយ ប្រមូលអាវុធទុកដាក់តាមអគ្គភាពរបស់ខ្លួនតាមដែលអាចធ្វើបាន ។*

*- ម៉ោង ០៦:០០ ឧទ្ធម្ភាគចក្រហោះហើរចាកចេញចោលទីក្រុងភ្នំពេញ មុខឆ្ពោះទៅទិសខាងលិចតាមតែគេធ្វើបានពាសពេញមេឃលើប្រទេសកម្ពុជា ។*

## ២. សកម្មភាពកងទ័ព

***បក្សខ្មែរក្រហមចូលក្រុង៖*** *ភ្នំពេញ៖ ១៧-៤-៧៥*

*- ម៉ោង ០៦:១៥នាទី កងទ័ពបក្សខ្មែរក្រហមដើរចូលទីក្រុងភ្នំពេញ ។*

*- ប្រដាប់អាវុធគ្រប់ដៃ (ជារបស់ប្រទេសចិនកុម្មុយនិស្ត) ប៉េកាំង ។*

*- សំលៀកបំពាក់ខ្មៅ មួកកន្ទប ស្បែកជើងសង្រែក (កង់ឡាន) ។*

*- ក្បួនដើរអមសងខាងថ្នល់ជាជួរបណ្ដោយៗគ្នាចុងកាណុងចេញក្រៅ ។*

*- តាមផ្លូវធំៗ មុខឆ្ពោះទៅវត្តភ្នំដូនពេញ*

*- តាមមុខសញ្ញារបស់បក្សគេដាក់ចុះជាស្រេច*

## ៣. មុខសញ្ញាបក្សខ្មែរក្រហម

**ចូលទីក្រុងភ្នំពេញ៖**

*១- កងទ័ពភូមិភាគបូព៌ាទិស៖ ចូលតាមថ្នល់ជាតិលេខ១*

*២- កងទ័ពភូមិភាគឧត្តរទិស៖ ចូលតាមថ្នល់ថ្មីក្បាលស្ពានជ្រោយចង្វា ។*

*៣- កងទ័ពភូមិភាគពាយ័ព្យទិស៖ ចូលតាមថ្នល់ជាតិលេខ៥*

*៤- កងទ័ពភូមិភាគបស្ចិមទិស៖ ចូលតាមថ្នល់ជាតិលេខ៤*

*៥- កងទ័ពភូមិភាគនិរតីទិស៖ ចូលតាមថ្នល់ជាតិលេខ៣*

*៦- កងទ័ពភូមិភាគពិសេស៖ ចូលតាមថ្នល់ជាតិលេខ២*

*កងទ័ពខ្មែរក្រហមចាប់ដៃគ្នាទ៦ភូមិភាគ ត្រង់វត្តភ្នំដូនពេញ*

### ៣.១ មុខសញ្ញាបក្សខ្មែរក្រហម

**បែកប្រជាជនក្រុងភ្នំពេញ**

*-អង្គការបក្សខ្មែរក្រហម យកផ្សារធំថ្មីធ្វើជាគោលកណ្ដាលដើម្បីជម្លៀសប្រជាជនភ្នំពេញចេញទៅកាន់ខេត្តក្រៅ តាមមុខសញ្ញារបស់ភូមិភាគនីមួយៗ ។*

*១- ភ្នំពេញខាងកើតភាគខាងត្បូង៖ ប្រជាជនភាគនេះត្រូវបានទៅភូមិភាគបូព៌ាទិស៖ ខេត្តព្រៃវែង ខេត្តស្វាយរៀង ។*

*២-ភ្នំពេញខាងកើតភាគខាងជើង៖ ប្រជាជនភាគនេះត្រូវបានទៅភូមិភាគឧត្តរទិស៖ មុខឆ្ពោះទៅខេត្តកំពង់ចាម កំពង់ធំ និងខេត្តសៀមរាប ។*

*៣-ភ្នំពេញខាងលិចភាគខាងជើង៖ ប្រជាជនភាគនេះត្រូវបានទៅភូមិភាគពាយ័ព្យទិស មុខឆ្ពោះខេត្តកំពង់ឆ្នាំង ខេត្ត*



ពោធិសាត់ និងខេត្តបាត់ដំបង ។

៤- ភ្នំពេញខាងលិចភាគខាងត្បូងៈ ប្រជាជនភាគនេះត្រូវបានទៅភូមិភាគបស្ចិមទិស មុខឆ្ពោះទៅខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ។

៥- ភ្នំពេញខាងត្បូងភាគខាងលិចៈ ប្រជាជនភាគនេះត្រូវបានទៅភូមិភាគនិរតីទិស មុខឆ្ពោះទៅខេត្តកំពត ខេត្តតាកែវ ។

៦- ភ្នំពេញខាងត្បូងភាគខាងកើតៈ ប្រជាជនភាគនេះត្រូវបានទៅភូមិភាគពិសេស មុខឆ្ពោះទៅខេត្តតាកែវ តាមផ្លូវជាតិលេខ២ ។

◆ **សកម្មភាពប្រជាជន**

**ទីក្រុងភ្នំពេញ** ១៧-៤-៧៥ៈ ០៦h ១៥

**អ្នកទីក្រុងភ្នំពេញ ចែកជា យ៉ាង?**

១- អ្នកជាប់និន្នាការបម្រើរបបសាធារណរដ្ឋខ្មែរ មនុស្សប្រភេទនេះមានការភិតភ័យ សម្ងំនៅក្នុងផ្ទះ រង់ចាំស្តាប់ព័ត៌មានផ្សេងៗអំពីរឿងសន្តិភាពខ្មែរ រវាងគូរភាគីទាំង២ គេរៀបចំសាជាថ្មី ។

២- អ្នកដែលគេមិនពេញចិត្ត នឹងរបបសាធារណរដ្ឋខ្មែរ លន់ ណុល គេនាំគ្នាទៅទទួលការធ្វើដំណើរចូលទីក្រុងរបស់បក្សខ្មែរក្រហមតម្រៀបជាជួរអមសងខាងផ្លូវនីមួយៗដែលកងទ័ពខ្មែរក្រហមគេដើរចូលទីក្រុងភ្នំពេញៈ ពេលនោះគេស្រែកជយឃោសថា ជយោៗ ទ្រហឹងអាប់ពាសពេញទីក្រុងភ្នំពេញ ។

៣- អ្នកដែលបាក់បែកគ្រួសារ ដោយចេញទៅប្រកបការងារ និងទៅព្យាបាលជំងឺនៅតាមផ្ទះពេទ្យរដ្ឋ និងឯកជន ប្រជាជនប្រភេទនេះមានការជ្រួលច្របល់ ឆ្លងចុះឆ្លងឡើងកាត់មុខកងទ័ពខ្មែរក្រហម បណ្តាលឲ្យមានគ្រោះថ្នាក់ដល់ស្លាប់ដោយអំណាចចុងកាណុងរបស់បក្សខ្មែរក្រហម ។

៤- អ្នកដែលគេបានចូលដៃរួមគំនិតនឹងខ្មែរក្រហមពីមុនមក ពេលនោះគេស្លៀកពាក់ខ្មៅចេញពីផ្ទះដើរកាត់រកបក្សពួករបស់គេ ឆ្វាត់ចុះឆ្វាត់ឡើង របៀបជាអ្នកនាំផ្លូវ ឬបំភ្លឺផ្លូវរបស់កងទ័ពខ្មែរក្រហម និងជាអ្នកសង្កេតតាមពិនិត្យតែមនុស្សម្នាក់ៗដែលគេកត់សម្គាល់ថាជាអ្នកមុខអ្នកការរបស់របប លន់ ណុល ។ល ។

**៥. កងទ័ពបក្សខ្មែរក្រហម**

**សម្រេចផែនការចាប់ដៃគ្នា** ៦ ភូមិភាគ វគ្គភ្នំៈ ថ្ងៃ ១៧-៤-៧៥ៈ ០៦h ៣០

កងទ័ពបក្សខ្មែរក្រហមវាយខ្សែត្រៀមកាត់ទីក្រុងចែកតាមភូមិភាគនីមួយៗតាមស្នូលច្បារ មុខស្ថានីយ៍រថភ្លើង ត្រង់ទៅរកមាត់ទន្លេចតុមុខ (បួនមុខ) ។

**លើកទី១** ថ្ងៃ១៧-៤-៧៥ៈ ០៦h ៤៥

វិទ្យុផ្សាយសម្លេងក្រុងភ្នំពេញផ្សាយដោយបក្សខ្មែរក្រហមភូមិភាគនិរតីទិសថាៈ

១- ពេលនេះបក្សយើងបានទទួលជោគជ័យ១០០% លើប្រទេសកម្ពុជាទាំងមូល ។

២- បក្សយើងត្រូវការរកសន្តិភាពតាមសន្តិវិធីមិនប្រកាន់បក្សពួក ។

៣- បក្សយើងសុំអញ្ជើញអស់លោក ឯកឧត្តម ក្រុមនិន្នាការ អ្នកទទួលខុសត្រូវ ក្រុមស្ថាប័ន ទៅជួបជុំគ្នានៅក្រសួងឃោសនាការជាតិជាបន្ទាន់ ។

**មូលហេតុ** ចរចាគ្នារកសន្តិភាពតាមមធ្យោបាយសន្តិវិធីជូនប្រជាជនខ្មែរទូទាំងប្រទេស ។

**លើកទី២** ១៧-៤-៧៥ៈ ០៧h ១៥

វិទ្យុផ្សាយសម្លេងភ្នំពេញ ផ្សាយដោយបក្សខ្មែរក្រហមបស្ចិមទិសម្តងទៀតថា

១- បក្សយើងឈ្នះ១០០% លើរបបសាធារណរដ្ឋខ្មែរ បនក្បត់ លន់ ណុល ទូទាំងប្រទេសកម្ពុជា ។

២- ជ័យជម្នះនេះ គឺបក្សយើងឈ្នះដោយចុងកាណុងយ៉ាងក្តៅគគុក ។



៣- បក្សយើងគ្មានត្រូវការចរចាជាមួយអ្នកណា ឬបក្សណាទៀតទេ ។

៤- ពួកក្បត់បក្សត្រូវតែទទួលការបរាជ័យរបស់ខ្លួន គ្មានអ្នកណាទទួលជំនួសអ្នកណាទេ ។

**៥.៣** ១៧-៤-៧៥ៈ ០៧h ៣០

បក្សខ្មែរក្រហម (ប្រើរថយន្តឡាំប្រើគាម៉ូតូ)

**ប្រកាសតាមប្រដាប់បំពងសំឡេង?**

១- ប្រជាជនកុំជ្រួលច្របល់ឆ្លងចុះឆ្លងឡើង

២- ចូលផ្ទះតាមរៀងៗខ្លួន

៣- រៀបចំការចាកចេញក្រៅក្រុង បណ្តោះអាសន្នមួយរយៈខ្លីសិន ចំនួន៣ថ្ងៃ ។

៤- ចេញឲ្យផុតពីទីក្រុងចម្ងាយ៣គីឡូម៉ែត្រ

៥- ចេញតាមផ្លូវដែលអង្គការបក្សកំណត់ឲ្យ

៦- មិនបាច់យករបស់របរទៅច្រើនពេកទេ

៧- បើករយៈកាលឲ្យចេញកំណត់៣ថ្ងៃ

៨- កុំដើរបញ្ច្រាសផ្លូវដែលអង្គការបក្សកំណត់ឲ្យដើរ

**៦. មូលហេតុបក្សកំណត់ឲ្យចេញ?**

១- អង្គការបក្សត្រូវការបោសសម្អាតខ្មាំង

២- រៀបចំឲ្យសមស្របតាមគោលអង្គការបក្សកំណត់ទុក

៣- អង្គការបក្សត្រូវមាននាទីការពារអាយុជីវិត និងការពារទីក្រុងឲ្យគង់វង្ស ។

៤- អង្គការបក្សដឹងមុនថា មានខ្មាំងអាមេរិកាំង និងបរិវាររៀបចំកម្ទេចទីក្រុងរបស់យើងដោយប្រើយន្តហោះធុនធំៗជាងមុនៗទៅទៀត ។

**៦.១** ១៧-៤-៧៥ៈ ០៧h ៤៥

- កងទ័ពអង្គការបក្សខ្មែរក្រហម ដើរចល័តតាមផ្លូវតូចៗដេញបង្ខំប្រជាជនឲ្យចេញពីទីក្រុង អ្នកណារឹងទទឹងគេប្រើអាវុធយកជាគ្នារតែម្តង (គឺបាញ់) ។

**៦.២ ផែនការឆែកឆេរច្រកចេញពីក្រុង របស់អង្គការបក្សខ្មែរក្រហម**

- ភូមិភាគនីមួយៗ គេរៀបកន្លែងឆែកឆេរតាមមុខសញ្ញា និងទទួលខុសត្រូវដូចជម្រាបមកខាងលើ ក្នុងភូមិភាគនីមួយៗមានកន្លែងឆែកឆេរធំ៣កន្លែង (ភារកិច្ច)

១- សង្កេតឆែករកជនក្បត់ពីអ្នកទទួលតំណែងធំៗ

២- ទាហានសាធារណរដ្ឋខ្មែរ (លន់ ណុល)

៣- ពួកគិញ Sédok និង Cos (ពួកការិយាល័យស៊ើបអង្កេតរបបសាធារណរដ្ឋខ្មែរ) ។

៤- អ្នកដែលរត់ចេញពីបក្សរបស់គេមកចូលនឹង លន់ ណុល

**ការសង្កេតៈ** ពេលនោះអង្គការបក្សខ្មែរក្រហមចាប់បានទាហាន លន់ ណុល ក្នុងមួយថ្ងៃៗ ក្នុងកន្លែងនីមួយៗចាប់ ១០០-៣០០នាក់ ។

**ចម្លើយទី១ វគ្គទី១**

យើងខ្ញុំសុំចែកទីក្រុងភ្នំពេញជា៤ផ្នែក ដូចពាក្យបរិយាយពីអត្ថបទដើមគឺ

១- ប្រជាជននៅទីក្រុងភ្នំពេញភាគខាងកើតទន្លេមេគង្គ គឺចែកចេញជា ២ផ្នែកៈ

ក- ផ្នែកខាងត្បូងទន្លេបួនមុខ ពួកខ្មែរក្រហមបានជម្លៀសចេញមុខឆ្ពោះទៅកាន់ខេត្តស្វាយរៀង និងខេត្តព្រៃវែង ចេញតាមថ្នល់ជាតិលេខ១ ប៉ុន្តែប្រជាជនទាំងអស់នេះមិនបានទៅតាមទិសកំណត់របស់អង្គការខ្មែរក្រមដាក់ចុះមក ១០០%ទេ លុះមកដល់ព្រែកអ្នកលឿង ខាងលិចទន្លេ ប្រជាជនខ្លះត្រូវបែកទៅក្តួមសំណរ លុះដល់ថ្នល់កាត់មួយចេញពីទន្លេទៅស្រុកសំរោងយ៉ោងចំបក់ ខេត្តតាកែវ ត្រង់ថ្នល់ជាតិលេខ២ ក៏បែកទៅតាកែវខ្លះទៀតទៅកំពត គឺគេកាត់ទៅរកស្រុកកំណើតរបស់គេ អ្នកខ្លះទៅមិនដល់ទិសដៅរបស់ខ្លួនទេ ព្រោះពេលនោះអង្គការខ្មែរក្រហមកំណត់ឲ្យដើរបានតែ១៥ថ្ងៃ គឺគិតពីថ្ងៃ១៧-៤-៧៥ រហូតដល់ថ្ងៃ១-៥-៧៥ អ្នកណាទៅដល់ទីណា គ្រប់កំណត់ថ្ងៃធ្វើដំណើរខាងលើគឺគណៈភូមិនោះគេឃាត់ឲ្យនៅត្រង់នោះឯង ។

ខ- ផ្នែកខាងជើងទន្លេបួនមុខ ពួកខ្មែរក្រហមជម្លៀសចេញមុខឆ្ពោះទៅកាន់ខេត្តព្រៃវែង និងខេត្តកំពង់ចាម តាមផ្លូវថ្មីស្ពានជ្រោយចង្វា ទៅខេត្តកំពង់ចាម ។

- ប្រជាជនទាំងអស់នោះ ក៏មិនបានទៅដល់កំពង់ចាមតាមការកំណត់របស់អង្គការខ្មែរក្រហម ដូចជាប្រជាជនខាងលើដែលអធិប្បាយរួចមកហើយដែរ ព្រោះប្រជាជនមានខ្លះឆ្លៀតបែកផាកទៅរកទិសដៅរបស់គេពីស្រុកកំណើតដើម ផុតកំណត់ការធ្វើដំណើរត្រឹមណាគឺនៅត្រឹមនោះ ។ **(នៅមានត)**

# ខ្លឹមសារនៃពិធីបុណ្យរបស់របបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងខែមេសា

នៅក្នុងសេចក្តីសម្រេចរបស់គណៈមជ្ឈិមដែលជាអង្គការកំពូលរបស់បក្សកុម្មុយនិស្តកម្ពុជា ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ (ឯកសារលេខ D៦៩៣ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា) ក្រោមចំណងជើងថា «សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន» បានសរសេរថា «ជ័យជម្នះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នេះគឺជានិមិត្តរូបនៃវីរភាពរបស់ប្រជាជនយើង តស៊ូប្រជាជាតិ តស៊ូវណ្ណៈ ពេលមុននិងក្រោយសង្គ្រាមប្រឆាំងសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក» ។ គណៈអចិន្ត្រៃយ៍នៃរបបកម្ពុជាប្រជាធិបតេយ្យបានប្រកាសថ្ងៃខួបរំឭកព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះក្នុងខែមេសា មានអត្ថន័យដូចខាងក្រោមនេះ÷

## ថ្ងៃ១ មេសា ១៩៧៥

មហាជ័យជម្នះនៃនយោបាយខ្មែររូបនីយកម្មសង្គ្រាមរបស់ចក្រពត្តិអាមេរិកនៅកម្ពុជា ឬមហាបរាជ័យនៃទ្រឹស្តីនិចសុនយកខ្មែរវាយខ្មែរ ។

## ថ្ងៃ១២ មេសា ឆ្នាំ១៩៧៥

មហាជ័យជម្នះនៃសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិកជាមូលដ្ឋានដោយតំណាងជាផ្លូវការចក្រពត្តិត្រូវវាយបណ្តេញចេញពីកម្ពុជា ។

## ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥

បុណ្យឯករាជ្យជាបុណ្យជាតិធំជាងគេបំផុត ។ កម្មវិធីបុណ្យឯករាជ្យៈ ថ្ងៃ១៥-១៦-១៧ ខែមេសា គឺជាបុណ្យឯករាជ្យផង និងបុណ្យចូលឆ្នាំផង ។

ថ្ងៃ១៥គឺជាថ្ងៃគោរពវិញ្ញាណក្ខន្ធវីរបុរសយើង (ប៉ុល ពត ស្លាប់នៅថ្ងៃ១៥ ខែមេសា ឆ្នាំ១៩៩៨ ដែលជារឿងមួយដែលចម្លែកបំផុត) ។ ទង់ជាតិត្រូវដាក់ចុះពាក់កណ្តាល ។ អានវិចារណកថាវិទ្យុថា វាយចក្រពត្តិអាមេរិកលាតត្រដាងឲ្យសកលលោកឃើញថាប្រជាជនយើងពលិកម្មប៉ុន្មាន ត្រូវអានវិចារណកថានេះក្នុងរយៈពេល១ម៉ោងម្តងតាមវិទ្យុ ។ ចាក់ភ្លេងជាតិ១ម៉ោងម្តងក្រៅពីនេះភ្លេងវីរភាព ។

ថ្ងៃ១៦ ទទួលអំណរមហាជ័យជម្នះ រៀបរាប់វីរភាពកងទ័ពយុទ្ធជនយុទ្ធនារី រៀបរាប់ពីសមរភូមិសំខាន់ៗ ។

ថ្ងៃ១៧ គឺជាថ្ងៃបំផុសនូវសេចក្តីប្តេជ្ញាចិត្តកសាងប្រទេសនិងការការពារប្រទេសឲ្យបានមហាលោតផ្លោះមហាអស្ចារ្យ ។



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

មូលដ្ឋានក៏ត្រូវធ្វើយ៉ាងដូច្នេះដែរឲ្យប្រជាជនសម្រាកបីថ្ងៃដើម្បីអប់រំនយោបាយ ។

តាមរយៈកម្មវិធីបុណ្យ ដូចដែលបានបញ្ជាក់ក្នុងឯកសារខាងលើនេះ របបកម្ពុជាប្រជាធិបតេយ្យបានផ្លាស់ប្តូរថ្ងៃបុណ្យចូលឆ្នាំខ្មែរ ហើយបានប្រែក្លាយជាទិវាប្រារព្ធមហាជ័យជំនះ ប្រឆាំងចក្រពត្តិអាមេរិក និងជាថ្ងៃអប់រំនយោបាយអនុវត្តទិសនយោបាយអង្គការបដិវត្តន៍ មហាលោតផ្លោះមហាអស្ចារ្យរបស់ខ្លួន ។ ជាផ្លូវការសិទ្ធិសេរីភាពនៃការជួបជុំគ្រួសារ និងទិដ្ឋភាពបុណ្យប្រពៃណីចូលឆ្នាំខ្មែរទាំងអស់ត្រូវបានបំបាត់ចោល ។

**ផាត កុសល**

# បងស្រី ប៉ុល ពត



សាឡុត រឿង
អាយុ ៨១ឆ្នាំ
រូបថតឆ្នាំ១៩៩៧

ជីតារបស់ប៉ុល ពត ឈ្មោះ ដែម ។ ខ្ញុំមិនស្គាល់ឈ្មោះឪពុកឬជីតារបស់ ដែម ឡើយ ។ ដែមមានកូនប្រុសម្នាក់ឈ្មោះ សាឡុត ដែលត្រូវជាឪពុករបស់ ប៉ុល ពត ។ ប៉ុល ពត បានយកឈ្មោះឪពុកមកធ្វើជាគោត្តនាមរបស់ខ្លួនគឺ សាឡុត ស ។ «ស» គឺជានាមខ្លួនរបស់ ប៉ុល ពត ។

ដែម គឺជាមេបញ្ជាការកងទ័ពខ្មែរសេរីក្នុងរាជវង្ស ព្រះស៊ីសុវត្ថិ ។ នៅពេលនោះគាត់បានចូលរួមក្នុងចលនាតស៊ូហើយក៏បាត់បង់ជីវិតទៅ ។ គាត់គឺជាមិត្តភ័ក្តិរបស់តេជោ ថោង និងតេជោ អ៊ី ដែលជាអតីតចៅហ្វាយខេត្តកំពង់ធំ ។ ខ្ញុំមិនបានសួរអំពីមូលហេតុដែលលោកតាដែមជាខ្មែរសេរី ហើយមានមិត្តជាចៅហ្វាយខេត្តរបស់រាជានិយមឡើយ ។ ប្រហែលជាគាត់ស្គាល់គ្នាតាំងពីកុមារភាពមកម្ល៉េះក៏មិនដឹង ។ ប៉ុន្តែគ្រប់គ្នាមានការសរសើរចំពោះគ្រួសារ ប៉ុល ពត ដែលមានជីតាជាអ្នកចម្បាំងដ៏ពូកែកាលសម័យដើមយូរលង់ណាស់មកហើយ ។ ដើម្បីឲ្យដឹងច្បាស់អំពីមុខរបរពិតរបស់ដែម ថាតើគាត់ជាមេបញ្ជាការយោធា ជាខ្មែរសេរី ឬក៏ជាមេបញ្ជាការផង និងខ្មែរសេរីផង នោះគួរតែមានការស្រាវជ្រាវថែមទៀត ។

ចំពោះឪពុក ប៉ុល ពត «ដែម សាឡុត» និងម្តាយ «ឌុក ណែម» វិញ គាត់ទាំងពីរគឺជាប្រជាកសិករសុទ្ធសាធ គ្មានធ្វើអ្វីផ្សេងទៀតឡើយ ។ គាត់ទាំងពីរស្លាប់នៅភូមិកំណើតរបស់ខ្លួនគឺភូមិព្រែកស្បូវ ឃុំពោធិចិនត្បូង ស្រុកស្ទឹងសែន «សង្កាត់លេខ៤» ខេត្តកំពង់ធំ ។

ភូមិព្រែកស្បូវនៅជំនាន់សាធារណរដ្ឋចន្លោះឆ្នាំ១៩៧០-១៩៧៥ ត្រូវបានទាហាន លន់ ណុល យកប្រើប្រាស់ជាមូលដ្ឋានកងកាំភ្លើងធំ ។ គណៈមេបញ្ជាការកងទ័ពមានឈ្មោះថា ទេព ប៉ែន ។ អ្នកស្រុកបាននិយាយថាមុនឆ្នាំ១៩៧៥ ដែលជារយៈពេលនៃការដួលរលំនៃរបបសាធារណរដ្ឋ ទ័ពព្រៃខ្មែរក្រហមមិនដែលបានវាយភូមិនោះទេ ។ តំណាងរាស្ត្រមាននៅពេលនោះឈ្មោះ ជា ឆេង ហើយមេឃុំឈ្មោះ សេង នី ។ សព្វថ្ងៃនេះគាត់ស្លាប់អស់ហើយ ។ នៅក្នុងភូមិមានវត្តមួយឈ្មោះថាពោធិសី ។ នៅក្នុងរបប ខ្មែរក្រហម ឆ្នាំ ១៩៧៥-៧៩ ភូមិនេះគ្មានមនុស្សរស់នៅទាល់តែសោះ ។ ប្រជាជនដែលរស់នៅខាងជើងបឹងស្ទឹងសែនត្រូវបានដេញឲ្យទៅទិសខាងជើងហើយ អ្នករស់នៅខាងត្បូងបឹងត្រូវពួកខ្មែរក្រហមជម្លៀសទៅទិសខាងត្បូងកាន់តែជ្រៅ ។ កាលណោះភូមិទាំងមូលត្រូវបានកាន់កាប់ទាំងស្រុង ដោយពួកខ្មែរក្រហមដែលរួមទាំងជនជាតិភាគតិច ដូចជាគួយ និងចាម ដែលជិតដិតជាមួយនឹងពួកខ្មែរក្រហម ។

កាលពីជំនាន់សាធារណរដ្ឋប្រជាមានិតកម្ពុជា «១៩៧៩-១៩៨៩» និងសម័យរដ្ឋកម្ពុជា «១៩៨៩-១៩៩២» ប្រជាជនចាម និងគួយ ដែលនៅកាន់កាប់ភូមិព្រែកស្បូវ បានវិល

ត្រឡប់មកស្រុកកំណើតវិញតាមភូមិនានា ដូចជាភូមិត្រឡែកកូនក្អែក ភូមិប្រាសាទ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ពេលនោះអ្នកភូមិដែលរស់ចាកផុតពីរបបខ្មែរក្រហមក៏បានវិលត្រឡប់មកភូមិកំណើតខ្លួនវិញដែរ ។

អ្នកភូមិព្រែកស្បូវនិយាយថា ទោះបីជាមានការវាយប្រហារយ៉ាងខ្លាំងក្លានៅក្នុងខេត្តកំពង់ធំក៏ដោយ ក៏ភូមិព្រែកស្បូវមិនដែលត្រូវបានគំរាមកំហែងពីសំណាក់ខ្មែរក្រហមឡើយ ។ លើសពីនេះទៀតលោក យុន ពោក ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកំពង់ធំ បានមានប្រសាសន៍ថា នៅឆ្នាំ១៩៩៣ ឪពុកមារបស់ ប៉ុល ពត ម្នាក់ដែលធ្វើមាតុភូមិនិវត្តន៍ពីជំរំជនភៀសខ្លួននៅប្រទេសថៃបានមកធ្វើផ្ទះពីរខ្នងនៅទីរួមខេត្តកំពង់ធំ ។ អន្ទុយលេងជាមួយនឹងខ្ញុំដែរ ។ ដោយចៃដន្យលោកយាយ រឿង បានរៀបរាប់ប្រាប់ខ្ញុំអំពីផ្ទះរបស់ យុន មាគ ដែលស្ថិតនៅក្នុងបរិវេណព្រះបរមរាជវាំង ។ ខ្ញុំពុំបានសួរថាតើ យុន មាគ នេះជានរណាទេ ។

លោកយាយមានប្រសាសន៍ថា ផ្ទះរបស់ យុន មាគ នេះធ្វើអំពីថ្ម លាបពណ៌ពងមាន់ ហើយគ្មានសួនច្បារពិតប្រាកដឡើយ ។ នៅវាំងមានសួនច្បារស្អាតៗចម្រុះដោយផ្កាគ្រប់មុខ ។ នៅឯរោងរបាំមានអ្នករបាំកំពុងរេរាំឥតដាច់ ។ កម្រាលព្រំនៅរោងរបាំស្អាតណាស់ ។ «ខ្ញុំចូលចិត្តមែនទែន» លោកយាយ រឿង បញ្ជាក់ ។ ហើយរោងរបាំមានក្លិនក្រអូបសាយ ។ នាពេលយប់ខ្ញុំមានភ្លើងអគ្គីសនីប្រើប្រាស់ ។ ខ្ញុំមិនដែលប្រើទៀនឡើយ ។


សាឡុត ស
© រូបថតឯកសារ Peter H. Maguire


សាឡុត សេង


សាឡុត ញឹប

ឪពុកមារបស់ ប៉ុល ពត នេះ ធ្លាប់ទាក់ទងពីប៉ៃលិនមកកំពង់ធំដែលជាកន្លែងគាត់អាចយកលុយកាក់ពី ប៉ុល ពត តាមរយៈសមមិត្ត អ៊ី ឈាន ដែលបច្ចុប្បន្នជាអភិបាលក្រុងប៉ៃលិន ។ គាត់ក៏បានទទួលលុយកាក់ពីទាហានរបស់ ប៉ុល ពត ប្រចាំនៅភ្នំដងរែក ស្រុកស្ទោង ថែមទៀតផង ។

ខ្ញុំទៅដល់ភូមិព្រែកស្បូវពេលមេឃកំពុងភ្លៀង ។ វាលស្រែមានពណ៌ខៀវស្រងាត់ ។ ផ្លូវទៅកាន់ផ្ទះរបស់លោកយាយ រឿង ដែលត្រូវជាបងស្រីបង្កើតរបស់ ប៉ុល ពត មានភក់ប៉ប៉ិចប៉ប៉ាច់ ហើយរអិលទៀតផង ។ ផ្លូវទៅកាន់ទីនោះតូចណាស់ រថយន្តធុនកាពីតាស់ក៏មិនអាចចូលដល់ឡើយ ។ ដូច្នេះខ្ញុំត្រូវចុះដើររហូតដល់ផ្ទះគាត់ ។ ពេលទៅដល់គាត់កំពុងតែសម្រាន្តក្នុងផ្ទះនៅឡើយ ។ កូនប្រសារស្រី និងចៅៗរបស់គាត់ បានចេញមកស្វាគមន៍ខ្ញុំ ។ បន្តិចក្រោយមកកូនប្រុសរបស់គាត់ចូលមក

លោកយាយ រឿង និយាយទៀតថា ស្តេចមុនីវង្សមានព្រះទ័យល្អណាស់ ។ លោកយាយនៅជាមួយព្រះអគ្គក្នុងពេលដែលព្រះអង្គសោយទិវង្គត ។ លោកយាយមានប្រសាសន៍ថា ពេលសោយទិវង្គត ស្តេចមុនីវង្សពាក់អាវស និងស្លៀកសារុង ។ ពេលនោះលោកយាយពាក់អាវផ្កា និងស្លៀកសំពត់ពណ៌ខ្មៅ ។ សក់លោកយាយខ្ចីធម្មតាគ្មានតុបតែងអ្វីឡើយ ។ ពេលខ្ញុំសួរលោកយាយថា តើព្រះអង្គមានចិត្តប្រតិព័ទ្ធលើលោកយាយទេ? លោកយាយបាននិយាយជន្ទចិត្តខ្ញុំថាហេតុអ្វីបានជាសួរសំណួរបែបនេះទៅវិញ ។ លោកយាយនិយាយទាំងញញឹមថា«ឆ្លើយមិនបានទេព្រោះជារឿងសម្ងាត់» ។ ខ្ញុំសួរគាត់ថាតើមុនពេលសោយទិវង្គតស្តេចមានបានផ្ទុំជាមួយលោកយាយទេ? លោកយាយនៅស្ងៀមមិនឆ្លើយគ្រាន់តែញឹមៗ ។ លោកយាយនិយាយទៀតថា ស្តេចមុនីវង្សមិនចូលចិត្តស្ត្រីដែលមានសក់វែង

ហើយគុបតែងទេ ។ ព្រះអង្គស្រលាញ់សក់ខ្លីធម្មតា ។ ពេលឃើញស្ត្រីណាមានសក់វែងគុបតែងផ្កាភ្ញី ព្រះអង្គតែងតែដេរពេបជ្រាយដាក់ ។ ពេលព្រះអង្គសោយទិវង្គតនៅដំណាក់បូកគោ លោកយាយយំសោកយ៉ាងខ្លាំង ។ លោកយាយនៅតែនឹកព្រះអង្គណាស់មកដល់សព្វថ្ងៃនេះ ។ ហើយពេលខ្ញុំសួរថាព្រះអង្គធ្វើអ្វីខ្លះចំពោះគាត់បានជាធ្វើឲ្យគាត់នឹកព្រះអង្គខ្លាំងយ៉ាងនេះ ។ ពេលនោះលោកយាយញញឹមហើយមានប្រសាសន៍ថា ព្រះអង្គទ្រង់ប្រទានអ្វីៗគ្រប់យ៉ាងដល់លោកយាយ ។ ពេលលោកយាយទៅដល់ព្រះបរមរាជវាំងជាលើកដំបូង ស្តេចបានប្រទានក្រវិលទំហ៊ូពេជ្រមួយគូ ។ បីខែក្រោយមក ព្រះអង្គបានសង់ផ្ទះឲ្យលោកយាយមួយមានពីរខ្នង ទិញរថយន្តមួយគ្រឿង គ្រឿងសង្ហារិម ពូកទូតាំង និងរបស់ផ្សេងៗទៀតគ្រប់យ៉ាង ។ ព្រះអង្គព្រមទាំងបានរៀបចំគ្រឿងសង្ហារិម ឲ្យលោកយាយទៀតផង ។ លើសពីនេះព្រះអង្គបានដាក់ងារឲ្យលោកយាយថា «អ្នកម្នាង» ។ លោកយាយ រឿង សើចហើយបន្តទៀតថា គាត់មានតែខ្លួនទទេប៉ុណ្ណោះនៅពេលចូលមកនៅផ្ទះនោះ ។ រាល់ពេលរដូវក្តៅព្រះអង្គតែងតែនាំគាត់ទៅដើរលេងនៅកំពត និងបូកគោ ហើយនៅរដូវវស្សាព្រះអង្គនាំគាត់ដើរលេងនៅត្រពាំងជង ខេត្តពោធិសាត់ ។ «ព្រះអង្គតែងតែយកខ្ញុំទៅតាមរហូតទៅដើរលេងទីណាក៏ដោយ ។ ព្រះអង្គស្រឡាញ់ខ្ញុំ» លោកយាយបញ្ឈាក់ទាំងញញឹម ។ ពេលខ្ញុំសួរគាត់ថា តើពេលនោះលោកយាយមានរូបសម្ផស្សស្អាតដែរឬទេ? លោកយាយ រឿង ពុំព្រមឆ្លើយ ប៉ុន្តែចេះតែសើច ។ លោកយាយបន្តទៀតថា ព្រះអង្គសោយក្រយាមុន ទើបគាត់ទទួលទានតាមក្រោយ ។ នៅព្រះបរមរាជវាំងមានចុងភៅបីនាក់ ខ្មែរម្នាក់ និងជនជាតិបារាំងពីរនាក់ ។ មានមនុស្សជាច្រើននៅចាំបម្រើព្រះអង្គ ពេលសោយក្រយាម្តងៗ ។ លោកយាយធ្លាប់បានទទួលទានជាមួយព្រះអង្គតែពីរនាក់ ។ ពេលនោះខ្ញុំសួរថា តើទទួលទានអាហារនៅកន្លែងណា? លោកយាយឆ្លើយថានៅបូកគោ ហើយព្រះអង្គបានទិញគ្រឿងអលង្ការជាច្រើនជូនគាត់ទៀតផង ។ ខ្ញុំសួរថា តើព្រះអង្គមានដែលជូនផ្កាដល់លោកយាយដែរឬទេ? លោកយាយ រឿង សើចញឹមៗហើយពោលថា «មិនដែលទេ ព្រោះយើងស្គាល់ចិត្តគ្នាទៅវិញទៅមកហើយ ។ ព្រះអង្គចង់ឲ្យខ្ញុំធ្វើជាអ្នករបាំ តែខ្ញុំបដិសេធមិនព្រម» ។ ខ្ញុំសួរទៀតថាតើលោកយាយហ៊ានបដិសេធដែរឬទេ? លោកយាយតបថា «ព្រះអង្គមិនអាចទ្រាំបាននូវការអង្វរកដ៏ផ្អែមល្ហែមរបស់ខ្ញុំទេ ។ ខ្ញុំធ្វើអ្នករបាំមិនកើតទេ ព្រោះខ្ញុំមានការខ្មាស់អៀនច្រើនណាស់ ។ ហើយក្រោយមកព្រះអង្គក៏យល់ព្រមតាមខ្ញុំ» ។ លោកយាយនៅតែមានចិត្តស្រឡាញ់ព្រះអង្គដដែល ។ លោកយាយនៅតែនិយាយដដែលៗអំពីស្តេចមុនីវង្ស និងការយកចិត្តទុកដាក់របស់ព្រះអង្គចំពោះខ្លួន ។ «ខ្ញុំចង់តែធ្វើជាឈឺទេដើម្បីឲ្យព្រះអង្គមកថ្នាក់ថ្នមថែ តែវាមិនព្រមឈឺសោះ» ។ ជីវិតនៅក្នុងវាំងគឺជាឋានសួគ៌សម្រាប់រូបលោកយាយ រឿង ។ ខ្ញុំសួរលោកយាយបន្តទៀតថាតើព្រះអង្គមានដែលជូនកន្សែងដៃដល់លោកយាយទេ? លោកយាយ រឿង សើចញឹមៗ ។ តើស្តេចមុនីវង្សមានដែលនាំលោកយាយទៅដើរបរបាញ់សត្វទេ? លោកយាយសើចញឹមៗដដែល ។

ពេលដែលខ្ញុំនិយាយជាមួយលោកយាយ សាឡុត រឿង ខ្ញុំមានអារម្មណ៍ថា ហាក់ដូចជាកំពុងនិយាយជាមួយស្រីម្នាក់ដែលមានអាយុ២០ឆ្នាំ ដែលមានរូបសម្ផស្សស្រស់សោភានិងឆ្លាតវាងវៃដូច្នេះ ។ លោកយាយរឿងនិយាយប្រាប់ខ្ញុំអំពី ប៉ុល ពត ។ ប៉ុល ពត បានចាកចោលគ្រួសាររបស់ខ្លួនតាំងពីអាយុ៦ឆ្នាំ ហើយនៅពេលមានអាយុ៧ឆ្នាំ ប៉ុល ពត បានមកលេងភូមិម្តងគត់ដោយស្លៀកពាក់ខោអាវពណ៌ស និងពាក់ស្បែកជើងឈើ ។ ប៉ុល ពត ចូលចិត្តនិយាយកំប្លែងលាយឡំជាមួយសម្តីមែនទែន ។ ប៉ុល ពត កើតនៅឆ្នាំឆ្លូវ ខែបុស្ស ឆ្នាំ១៩២៥ ។ ខ្ញុំមានការរន្ធត់ចិត្តមែនទែនពេលដឹងថា គាត់កើតនៅឆ្នាំឆ្លូវដូចខ្ញុំដែរ ។ ខ្ញុំក៏កើតនៅឆ្នាំឆ្លូវដែរ តែខុសគ្នា៣ជួរ ។

ពេលឪពុករបស់ខ្លួនស្លាប់ ប៉ុល ពត និង ខៀវ ប៉ុណ្ណារី ដែលត្រូវជាប្រពន្ធបានមកធ្វើបុណ្យនៅភូមិ ។

លោកយាយ រឿង ហាក់ដូចជាកំពុងប្រាប់ខ្ញុំថា ប៉ុល ពត បានបំផ្លាញនូវសុភមង្គលរបស់គាត់នៅក្នុងព្រះបរមរាជវាំង ។

សាឡុត សេង ដែលជាបងប្រុសបង្អស់របស់ប៉ុល ពត គឺជាកសិករសុទ្ធសាធបានប្រាប់ខ្ញុំថា ខ្មែរក្រហមបានសម្លាប់កូនប្រុសតែមួយរបស់គាត់ដែលមានអាយុ២១ឆ្នាំ ដែលកាលណោះធ្វើជាទាហានរបស់លន់ ណុល ។ សាឡុត ញឹប ដែលជាប្អូនប្រុសពៅរបស់ ប៉ុល ពត បាននិយាយថា «ប៉ុល ពត គឺជាបងប្រុសគួរឲ្យស្រលាញ់ ។ ហើយបើសិនជាគាត់គ្មានទោសកំហុសអ្វីទេខ្ញុំនឹងយកគាត់មកវិញ» ។ ប៉ុន្តែ ប៉ុល ពត បានស្លាប់បាត់ទៅហើយ ។

**ឆាំង យុ**



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

# ចម្លើយសារភាពៈ ប្រវត្តិរូបអ្នកទោសអង្គការ ឃួន សុន ហៅ កឹម ផាន នៅភូមិភាគបូព៌ា

***ឃួន សុន ហៅ កឹម ផាន និងសកម្មភាពប្រឆាំងនឹងខ្មែរក្រហម***

ឃួន សុន ហៅ កឹម ផាន អាយុ ២៣ឆ្នាំ កើតនៅភូមិតាខេង ឃុំម៉ឺនជ័យ ស្រុកសំរោង ខេត្តស្វាយរៀង ក្នុងតំបន់២៣ ។ នៅឆ្នាំ១៩៧៣ កឹម ផាន បានចូលធ្វើបដិវត្តន៍តាមរយៈមិត្ត សាផុង (ជាអនុនយោបាយក៣) ក្នុងតំបន់២៣ ។ ប៉ុន្តែបន្ទាប់មកដោយមិត្ត សាផុង ត្រូវបានអង្គការហៅទៅរៀននៅតាខ្មៅ ។ សាផុង បានយក កឹម ផាន ទៅផ្ញើទុកដាក់ជាមួយមិត្ត យ៉ា អគ្គសេនាធិការតំបន់២៣ ។

ពេលនោះមិត្ត យ៉ា បានអប់រំមិត្ត កឹម ផាន ថា «ថ្ងៃនេះប្អូនត្រូវមើលឃើញឲ្យច្បាស់ធ្វើបដិវត្តន៍គឺតឹងតែងមានវិន័យតឹងរ៉ឹង ដើរហើរសេរីមិនបាន គ្មានបុណ្យសក្តិ ហើយជីវភាពរស់នៅក៏មិនបានទូលំទូលាយដែរ» ។ បន្ទាប់មកឈ្មោះមិត្ត យ៉ា ក៏បាននិយាយប្រាប់អំពីខ្សែរយៈទាក់ទងខាងលើទៀតដែលមានមិត្ត សូ និងមិត្ត ធុច ហើយបានប្រគល់តួនាទីឲ្យ កឹម ផាន ធ្វើជានិរសារបស់ខ្លួនទាក់ទងជាមួយក្រុមក្បត់បដិវត្តន៍របស់ខ្លួនចំនួន ១០នាក់មកប្រជុំ ។ ខ្លឹមសារប្រជុំមានផែនការ ទី១-ដើម្បីឲ្យទាហានចូលមកតាមផ្លូវជាតិលេខ១ ។ ទី២-ពេលទាហានរបស់មិត្ត យ៉ុង (សក្តិបួន) ចូលមកគឺកុំឲ្យបងប្អូនបាញ់ ។

***ការទាក់ទងសុំជំនួយពីកងទ័ពវៀតណាមក្នុងការធ្វើសកម្មភាពក្បត់បដិវត្តន៍ខ្មែរក្រហម***

ក្រោយមកមិត្ត យ៉ា ក៏បានឲ្យ កឹម ផាន ទាក់ទងជាមួយជនជាតិវៀតណាមឈ្មោះ ថាំង ជាលេខាកងពលលេខ៧ របស់វៀតណាមដែលមានទីកន្លែងនៅវត្តចន្ទ្រី ដើម្បីសុំគ្រាប់បែក និងគ្រាប់កាំភ្លើងដៃមួយចំនួនសម្រាប់យកមកបម្រើសកម្មភាពក្បត់ប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហម ។ ខាងវៀតណាមក៏សុខចិត្តឧបត្ថម្ភឲ្យគ្រាប់រំសេវចំនួន ៣ប្រភេទដែលមានដូចជាគ្រាប់បែកធុនផ្លែក្រសាំងចំនួន៣កេស, គ្រាប់អឹម ៧៩ចំនួន១០០គ្រាប់ និងអាវុធអាកាចំនួន៣កេស ។ ក្រោយពីបានធ្វើការទាក់ទងសុំគ្រាប់រំសេវពីកងទ័ពវៀតណាមរួចមកមិត្តយ៉ា បានឲ្យ

គឹម ដាន ទៅហៅមិត្ត ប៊ុណ្ណារិត ជាប្រធានសន្តិសុខនៅស្រុករមាសហែក ឲ្យមកជួបដើម្បីប្រាប់ពីផែនការនិងទិសដៅក្បត់បដិវត្តន៍មួយចំនួន ។ នៅពេលនោះមិត្ត យ៉ា បានឲ្យ ប៊ុណ្ណារិត ទៅយកគ្រាប់រំសេវដែលទ័ពវៀតណាមបានខបត្តម្ភទាំងអស់នៅខាងកើតវត្តចន្ទ្រី ដែលជាកន្លែងរបស់មិត្ត ថាំង (សក្តិបួនវៀតណាម) ដើម្បីឲ្យយកទៅកម្ទេចមុខសញ្ញាពីរកន្លែង ទី១-ឲ្យយកទៅកម្ទេចឃ្លាំងពាណិជ្ជកម្មភូមិភាគ នៅផ្សារបោះព្រីង ទី២-ឲ្យយកទៅកម្ទេចរោងចក្រ ម៉ាស៊ីនអារឈើ ម៉ាស៊ីនធ្វើក្រដាស ម៉ាស៊ីនក្រឡឹងដែក ។

នៅខែកញ្ញា ឆ្នាំ១៩៧៣ ការទាក់ទងរវាងក្រុមក្បត់ទាំងនោះរួមជាមួយវៀតណាម ថាំង និង ទឹងា គឺក្នុងគោលបំណងដើម្បីឲ្យកម្លាំងទាំងពីរមានភាពកាន់តែជិតស្និទ្ធនឹងគ្នាហើយងាយស្រួលក្នុងការអនុវត្តន៍ការកម្ទេចកម្លាំងរបស់បដិវត្តន៍ចោលដើម្បីផ្លាស់ប្តូរការអនុវត្តន៍តាមរបៀបសង្គមចាស់ដែលមានបុណ្យសក្តិ ប្រាក់ខែ និងអាចដើរហើរបានដោយសេរី ។ នៅពេលនោះក្រុមក្បត់ប្រឆាំងនឹងបដិវត្តន៍ខ្មែរក្រហមបានបើកការប្រជុំគ្នាដែលមាន យ៉ា ជាគណៈសេនាធិការ, ស៊ើល គណៈអប់រំ ទទួលបន្ទុកជាប្រធាននយោបាយ, មិត្ត រឹម ជាគណៈអប់រំ ទទួលបន្ទុកជាប្រធានយោធា, មិត្ត សត្យា ជាគណៈអប់រំ ទទួលបន្ទុកជាអនុយោធា, មិត្ត សួន ជាលេខាវរសេនាតូចលេខ២៣, មិត្ត សែន ជា អនុយោធាវរសេនាតូចលេខ២៣, មិត្ត ពិន ជាអនុនយោបាយ-យ២៣, មិត្ត សាត ជាប្រធាននយោបាយ-យ៦៨ តំបន់២៣, សាម៉ន ជាប្រធានយោធា-យ៣៥ និងមិត្ត ជា ដែលជាប្រធានយោធា-យ៩០ ។ ការប្រជុំនេះគឺដើម្បីប្រាប់ឲ្យដឹងពីផែនការដែលត្រូវអនុវត្តដូចជា ទី១-ហាមផ្ទុះអាវុធលើកម្លាំងរបស់មិត្ត យ៉ុង សក្តិបួន ដើម្បីងាយស្រួលក្នុងការទាក់ទងកម្លាំងឲ្យធ្វើសកម្មភាពជាមួយគ្នា ។ ទី២-ត្រូវធ្វើសកម្មភាពជុំវិញមន្ទីរបដិវត្តន៍ និងគ្រប់មូលដ្ឋានហើយត្រូវរៀបចំកម្លាំងងាយស្រួលក្នុងការអនុវត្តន៍ការកម្ទេចកម្លាំងបដិវត្តន៍ ។

នៅខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ១៩៧៣ គឹម ដាន ត្រូវបានមិត្ត យ៉ា ចាត់ឲ្យទៅនៅធ្វើជានិរសាររបស់មិត្ត ស៊ើល ហើយមិត្ត ស៊ើល បានណែនាំ គឹម ដាន ថា «ប្អូនជានិរសាត្រូវតែអនុវត្តការងារឲ្យបានហ្មត់ចត់លើភារកិច្ចរបស់ខ្លួន ក្នុងការទាក់ទងសំបុត្រពីកន្លែងមួយទៅកន្លែងមួយ» ។ មិត្តស៊ើល បានឲ្យ គឹម ដាន យកសំបុត្រទៅឲ្យមិត្ត សូ នៅភូមិតាសូសេក ស្រុកសំរោង ខេត្តស្វាយរៀង ក្នុងតំបន់២៣ ។ បន្ទាប់ពីមិត្ត សូ បានអានសំបុត្ររួចភ្លាមមិត្ត សូ បានឲ្យ គឹម ដាន យកគ្រាប់បែកចំនួន៥០គ្រាប់ទៅប្រគល់ឲ្យនិរសាររបស់ខ្លួនគឺមិត្ត ស៊ាន ជា និរសាសេនាធិការ, មិត្ត ស៊ុន ជានិរសាររបស់មិត្ត យ៉ា, មិត្ត ម៉ាន ជាអ្នកស៊ើបការណ៍របស់សេនាធិការ, និងមិត្ត គឹមហ៊ាង ជាសមាជិកបច្ចេកទេសពេទ្យតំបន់២៣ ។ ក្នុងអំឡុងពេលនោះមិត្ត ឆន ជាអនុប្រធានឃុំញ មិត្ត គឹម ហៀង បានឲ្យធ្វើសកម្មភាពបោកគ្រាប់បែកនៅឃុំគ្នោត និងមិត្ត ម៉ាន ។ ក្នុងបំណងសម្លាប់អនុប្រធានឃុំគ្នោតម្នាក់ ដើម្បីកុំឲ្យអនុប្រធានឃុំគ្នោតនោះរាយការណ៍ពីសកម្មភាពដែលបានទាក់ទងគ្នាជាមួយទ័ពវៀតណាមនៅភូមិអំពិល ឃុំគ្នោត កាលពីលើកមុន ។

ពីខែមករា ដល់ខែកុម្ភៈ ឆ្នាំ១៩៧៤មិត្ត ស៊ើល បានឲ្យ គឹម ដាន, មិត្ត សាត, មិត្ត ជា, និងមិត្ត សាម៉ន ឲ្យមកប្រជុំនៅភូមិក្រសាំងដោយមានការចូលរួមចំនួន១៥នាក់ ហើយចំពោះខ្លឹមសារនៃការប្រជុំនេះមានពីរចំណុចជាសំខាន់គឺ១-ត្រូវអនុវត្តបន្តទៀតលើផែនការក្នុងឆ្នាំ១៩៧៤ ដើម្បីកម្ទេចកម្លាំងបដិវត្តន៍ខ្មែរក្រហមគ្រប់ផ្នែកក្នុងតំបន់២៣ដោយប្រើប្រាស់គ្រាប់បែករួមផ្សំនឹងអាវុធផង ២-ត្រូវរៀបចំកម្លាំងដើម្បីងាយស្រួលក្នុងការទាក់ទងជាមួយកម្លាំងរបស់មិត្ត យ៉ុង ជាសក្តិបួនប្រចាំខេត្តស្វាយរៀង ដើម្បីកម្ទេចនិងបំផ្លាញសម្ភារ និងទ្រព្យសម្បត្តិរបស់បដិវត្តន៍ឲ្យអស់ក្នុងតំបន់ ២៣ ទាំងមូល ។

## ផែនការសហការជាមួយកងទ័ពវៀតណាមក្នុងការប្រឆាំងបដិវត្តន៍ខ្មែរក្រហមក្នុងឆ្នាំ១៩៧៥

នៅខែឧសភា ឆ្នាំ១៩៧៥ មិត្ត សូ លេខាតំបន់២៣ បានហៅមិត្ត យ៉ា, ឆែម, ស៊ើល និងមិត្ត ឈិត ទៅប្រជុំនៅខេត្តស្វាយរៀង ដែលមានសមាជិកនៅក្នុងពេលប្រជុំនោះចំនួន ២៩នាក់ ដែលមានឈ្មោះដូចតទៅៈ ឈ្មោះ សូ ជាលេខាតំបន់ ២៣, ធុច អនុលេខាតំបន់២៣, សាផាត ជាសមាជិក,

កែវ អាន ជាសមាជិក, ដៃ សារី ជាសមាជិក, យ៉ា ជាលេខាសេនាធិការ, ឆែម ជាអនុលេខាសេនាធិការ, សឿល ជាសមាជិក, ឈិត ជាសមាជិក, ប៉ុន ជាលេខាធិការស្រុកសំរោង, ផន លេខាស្រុកកំពង់រោទិ៍, សាលីវ ជាលេខាស្រុកប្រសូត្រ, គួន ជាលេខាស្រុកស្វាយរៀង, សាម៉ន ជាលេខាស្រុកសំរោង, ចាន់ ជាអនុលេខាស្រុកប្រសូត្រ, រីស្សា ជាអនុលេខាស្រុកស្វាយរៀង, រីថា ជាសមាជិកស្រុកប្រសូត្រ, សត្យា ជាគណៈក្រសួងនយោបាយ, ធឿន ជាគណៈយុវកកមន្ទីរសេនាធិការ, សួន ជាលេខាវរសេនាតូចកាំភ្លើងធំ, សែន ជាលេខាវរសេនាតូចលេខ៧៥ ខាងផ្នែកភស្តុភារ, សាគុន ជាលេខា-ឃស៊ើបការណ៍សេនាធិការ, កាវន ជាអនុសេនាធិការវរសេនាធំលេខ១១៣ តំបន់២៣, ពិន អនុលេខាវរសេនាធំលេខ១៣០, សាត ជាលេខាវរសេនាធំលេខ៩០, យ៉ាន ជាអនុលេខា-ឃស៊ើបការណ៍សេនាធិការ, សាម៉ន ជាលេខាវរសេនាធំលេខ១៣០, ជា ជាអនុលេខាវរសេនាតូចលេខ៩០ និង សារ៉ាត់ ជាអនុលេខាវរសេនាតូចលេខ៧៣ ។ ក្រោយពីប្រជុំហើយ គឹម ដាន បានស្តាប់ឮមិត្ត សូ និយាយថា «បើវៀតណាមចូលតាមមុខសញ្ញាណា កុំឲ្យបងប្អូនបាញ់ ។ ត្រូវប្រឆាំងនឹងផែនការ ៣គោនក្នុងដំណើរការកសាងប្រទេសកុំឲ្យរីកលូតលាស់ទៅមុខបាន ហើយត្រូវរៀបចំកម្លាំងរបស់យើងឲ្យបានស្រួល ដើម្បីបន្តសកម្មភាពក្នុងឆ្នាំ១៩៧៥ឲ្យបានខ្លាំងក្លា» ។ នៅអំឡុងខែមិថុនា ដល់ខែកក្កដា ឆ្នាំ១៩៧៥ មិត្ត សឿល និងមិត្ត ផន បានទៅទាក់ទងគ្នាជាមួយមិត្ត តឿង (កងទ័ពវៀតណាម) នាទីជាលេខាកងពលលេខ៥ ។ ពេលទៅដល់ គឹម ដាន និងនិរសារបស់មិត្ត ផន បានអង្គុយចាំនៅខាងក្រៅ ហើយបានស្តាប់ឮមិត្ត សឿល និងមិត្ត ផន និយាយថា «ខ្ញុំមកនេះដើម្បីឲ្យកម្លាំងរបស់មិត្តចូលមកធ្វើសកម្មភាពក្នុងស្រុកកំពង់រោទិ៍ ភូមិព្រៃវល្លិ៍ ទី១-ឲ្យចូលពីខាងជើង ទី២-ឲ្យនៅខាងកាណុង (កាំភ្លើងធំ) ធ្វើសកម្មភាពវាយបុកចូលស្រុកប្រសូត្រ» ។ ពួកទ័ពវៀតណាមបានបាញ់ផ្លោងដាក់ភូមិព្រៃវល្លិ៍ បណ្តាលឲ្យប្រជាជនរត់ចោលការដកស្ទូង ហើយបានសម្លាប់កងទ័ពអស់ចំនួន៩នាក់ ។


យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

នៅក្នុងខែសីហា ឆ្នាំ១៩៧៥ មិត្ត សឿល និងមិត្ត យ៉ា បានឲ្យ គឹម ដាន យកសំបុត្រទៅឲ្យមិត្ត ថាំង ជាលេខាកងពលវៀតណាមនៅបាតគ្រាស់ ។ ក្រោយពី ថាំង បានអានសំបុត្រនោះរួចហើយ ក៏បាននិយាយប្រាប់ គឹម ដាន ថា «បងយ៉ា, បងសឿល ឲ្យកម្លាំងខ្ញុំចូលទៅនៅស្រុករមាសហែកធ្វើសកម្មភាពបាញ់ផ្លោង» ។ ក្រោយពី គឹម ដាន បានត្រឡប់មកវិញ មិត្ត យ៉ា, មិត្ត សឿល, និងមិត្ត ឈិត បានទៅកន្លែងរបស់មិត្ត សាម៉ន និងមិត្ត ជា នៅខាងកើតកំពង់ត្រាច ដោយនិយាយទាក់ទងគ្នាថា «ចំពោះកម្លាំងមិត្ត ថាំង ខ្ញុំឲ្យមកនៅព្រៃតាឱបចំនួនមួយកងវរសេនាតូច ហើយមិត្តទាក់ទងឲ្យជាប់ដើម្បីងាយស្រួលក្នុងការងាររបស់យើងតទៅទៀត» ។ **(នៅមានត)** **សុភារិទ្ធ**

# ប្រវត្តិរូប ដួន ប្រាសិទ្ធ

(កត់ត្រាតាមសំណៅដើមទាំងស្រុង)


ដួន ប្រាសិទ្ធ
ថតនៅឆ្នាំ១៩៧៥

ដោយសមមិត្តទទួលខុសត្រូវបានឲ្យពត៌មានថា មានខ្ទាំងវណ្ណៈបានចោទប្រកាន់មកដល់ខ្លួនខ្ញុំ ខ្ញុំសូមធ្វើប្រវត្តិរូបនេះជូនបក្សដោយស្មោះអស់ពីចិត្ត ។

## I.អំពីឪពុកម្តាយ បងប្អូន គ្រួសារ

ឈ្មោះដើមផ្ទាល់ៈ ដួន ប្រាសិទ្ធ, ឈ្មោះក្នុងបដិវត្តន៍ៈ សាន, ភេទប្រុស, ជនជាតិខ្មែរ មានគ្រួសារឈ្មោះ គ្រិស្ទាន គូរេ ជនជាតិបារាំងសព្វថ្ងៃនៅប្រទេសបារាំង មានកូន៣ៈ នារី ២ បុរស១ ។ នារីកូនបងអាយុ ២១ឆ្នាំ ចូលបដិវត្តន៍ហើយ ។ កូន២ទៀតនៅជាមួយម្តាយនៅឡើយ ។ ថ្ងៃ ខែ ឆ្នាំ កំណើតរបស់ខ្ញុំៈ ៣ កុម្ភៈ ១៩៣០ នៅភ្នំពេញ ជីតាឈ្មោះ ដួន វណ្ណៈសក្តិភូមិប្រតិកិរិយាក្បត់ជាតិឲ្យអាណានិគមនិយមបារាំង ឪពុកឈ្មោះ ដួន ហល វណ្ណៈសក្តិភូមិអភិរក្សបម្រើអាណានិគមនិយមបារាំង ។ ស្លាប់ពីឆ្នាំ១៩៥២ ឬ ១៩៥៣ ។ ម្តាយឈ្មោះ ប៊ុន ចាន់ម៉ូលី វណ្ណៈសក្តិភូមិអភិរក្សនៅរស់ អាយុមិនដឹងប្រហែលជាង៧០ឆ្នាំ ។

**បងប្អូន**ៈបងប្រុសៈ ដួន ជឿន ធ្វើពេទ្យនិងរដ្ឋមន្ត្រីសុខាភិបាល ។ បងស្រីៈ ដួន ជឿម មានប្តីឈ្មោះ ឈាន វ៉ឹម នាយទុនកុំប្រាដ័រ ។ និន្នាការនយោបាយៈ មិនដឹង ខានជួបយូរឆ្នាំមកហើយ ។ បងប្រុសៈ ដួន ជុំ នាយទុនកុំប្រាដ័រ ។ និន្នាការនយោបាយមិនដឹងទេ ខានជួបយូរមកហើយ ។ បងប្រុសៈ ដួន ម៉ុម ចូលបដិវត្តន៍តាំងពីឆ្នាំ១៩៥១ សព្វថ្ងៃនៅក្រសួងឧស្សាហកម្ម ។ ខ្លួនខ្ញុំជាប្អូនគេបង្អស់ ។

## II.ពីឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៤៩

១-ពីឆ្នាំ១៩៣៥ (ឬ១៩៣៦?) ដល់ឆ្នាំ១៩៤១ៈ រៀនសូត្រសាលាបារាំងនៅភ្នំពេញរហូតដល់ថ្នាក់លេខ៦ ។ ដល់ថ្នាក់លេខ៦ ដោយរៀនមិនបានល្អ មេសាលាបារាំងវិទ្យាល័យស៊ីសុវត្ថិបានសម្រេចឲ្យឈប់រៀននៅវិទ្យាល័យនោះ ។ ឪពុកខ្ញុំក៏សម្រេចឲ្យខ្ញុំទៅរៀនសូត្រនៅព្រៃនគរ នៅវិទ្យាល័យ សាសេឡូ ឡូបា ។

២-ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៥ៈ ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៤ ខ្ញុំនៅបន្តរៀនសូត្រនៅព្រៃនគរ ។ ដោយព្រៃនគរត្រូវពួកចក្រពត្តិអាមេរិកទម្លាក់គ្រាប់បែក ឪពុកខ្ញុំសម្រេចឲ្យខ្ញុំទៅបន្តរៀនសូត្រនៅក្រុងដាឡាត់ នៅវៀតណាមខាងត្បូងពីខែ៩ ឆ្នាំ១៩៤៤ តែថ្ងៃ៩ ខែ៣ ឆ្នាំ១៩៤៥ ពួកហ្វាស៊ីសជប៉ុនធ្វើរដ្ឋប្រហារ ខ្ញុំត្រូវពួកវាបញ្ជូនត្រឡប់មកភ្នំពេញវិញនៅខែ៤ ។

៣-ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ១៩៤៩ៈ ត្រឡប់មកភ្នំពេញវិញខ្ញុំ

បានបន្តការរៀនសូត្រនៅវិទ្យាល័យស៊ីសុវត្ថិរហូតប្រឡងចប់នៅខែ៧ ឆ្នាំ១៩៤៩ គឺនៅពេលនោះហើយដែលខ្ញុំបានចាប់អារម្មណ៍ស្នេហាជាតិឡើង ។ គឺជាមុនដំបូងដែលខ្ញុំបានរស់នៅទាក់ទងខ្លះជាមួយជនជាតិកម្ពុជា ។ ដល់ខ្ញុំប្រឡងចប់នៅខែ៧ ឆ្នាំ១៩៤៩ ពួកអាណានិគមបារាំងខំអូសទាញក្នុងក្តីសង្ឃឹមអប់រំខ្លួនខ្ញុំឲ្យបម្រើវាដូចឪពុក ជីតា ខ្ញុំទៀត ។ ហេតុនេះវាឲ្យរង្វាន់ខ្ញុំមួយឲ្យធ្វើដំណើរទេសចរណ៍តាមជើងទឹកទៅក្រុងម៉ានីល (ហ្វីលីពីន) និងហុងកុង (ខែកក្កដា-សីហា ១៩៤៩) ។

### III. ពីឆ្នាំ១៩៤៩ (ខែកញ្ញា) ដល់ឆ្នាំ១៩៥៥ (ខែធ្នូ

ខ្ញុំបានទៅបន្តសិក្សានៅប្រទេសបារាំង នៅខែកញ្ញា ឆ្នាំ១៩៤៩ ។ ទៅនេះដោយមានអាហារូបករណ៍ពាក់កណ្តាលរហូតឆ្នាំ១៩៥២ ឆ្នាំដែលរាជរដ្ឋាភិបាលពេលនោះបានកាត់បញ្ឈប់ ព្រោះខ្ញុំបានធ្វើសកម្មភាពប្រឆាំងវា ។ ខ្ញុំទៅដើម្បីរៀនសូត្រខាងជកធ្មេញ ។ តែបានផ្លាស់ទៅរៀនសូត្រខាងធ្វើនិងលក់ថ្នាំ ។ រៀនបាន២ឆ្នាំ បានផ្លាស់មករៀនខាងដឹកជញ្ជូនវិញ រហូតដល់ចប់ចុងឆ្នាំ១៩៥៤ ។ រៀនចប់ហើយរាជរដ្ឋាភិបាលបានឲ្យចូលធ្វើការខាងរទេះភ្លើង ហើយឲ្យចូលធ្វើកម្មសិក្សា៦ខែក្នុងរទេះភ្លើងបារាំង ។

គឺនៅរយៈពេល៦ឆ្នាំនេះនៅប្រទេសបារាំងដែលខ្ញុំមានការភ្ញាក់រឭកខាងស្មារតីស្នេហាជាតិ ចូលរួមក្នុងការតស៊ូប្រឆាំងអាណានិគមនិយមបារាំងដើម្បីទាមទារឯករាជ្យ ហើយមានគោលបំណងចង់ឲ្យកម្ពុជាទៅជាសង្គមនិយម ។ នៅឆ្នាំ១៩៥១ បានចូលក្នុង «ក្រុមម៉ាក្ស-លេនីន» ដែលបានបង្កើតនៅទីក្រុងប៉ារីស ដោយសមមិត្តបង ប៉ុលពត, បងរ៉ាន់, បងខៀវ...។ល។ បានចូលរួមសកម្មភាពជាប់និងជិតស្និទ្ធរហូតដល់ឆ្នាំ១៩៥៥ ។ នៅឆ្នាំ១៩៥៣ ក្រោមការណែនាំបងៗទាំងនោះ បានសម្រេចចូលបក្សបារាំង ។ នៅឆ្នាំ១៩៥៣ ដដែលនេះប៉ូលិសសន្តិសុខបារាំងបានចាប់ខ្ញុំយកទៅឃុំឃាំង១ថ្ងៃដើម្បីសួរចម្លើយក្នុងសកម្មភាពសមាគមនិស្សិតខ្មែរប្រឆាំងសីហនុ ក្បត់ប្រជាជនពេលនោះ ។

ស្មារតីភ្ញាក់រឭកពេលនោះត្រឹមស្នេហាជាតិមិនទាន់ដល់វណ្ណៈទេ ។ ម្យ៉ាងទៀតព្រលឹងជាតិក៏មិនទាន់បានដល់កម្រិតទេ ដោយមានការច្របូកច្របល់រវាងស្នេហាជាតិនិងអន្តរជាតិនិយម ។ ហេតុនេះបានជានៅខែធ្នូ ឆ្នាំ១៩៥៤ ខ្ញុំបានកសាងគ្រួសារជាមួយនារីបារាំង មូលហេតុនេះក៏មកពីការអប់រំរបស់វណ្ណៈសក្តិភូមិជិះជាន់និងអាណានិគមនិយមបារាំង ។ ការដែលខ្ញុំបានសម្រេចខុសនេះនាំឲ្យមានការស្មុគស្មាញក្នុងសតិអារម្មណ៍រហូតមកដល់សព្វថ្ងៃ ។ នៅពេលរៀនសូត្រនៅប្រទេសបារាំងខ្ញុំគ្មានមិត្តភក្តិណាក្រៅពីសមមិត្តដទៃគ្នានៅក្នុងរង្វង់ម៉ាក្ស-លេនីននេះទេ ។ ឯមិត្តបរទេសមានម្នាក់ជាជនជាតិបារាំងដែលមានការរាប់អានជិតស្និទ្ធរហូតសព្វថ្ងៃ ។ មិត្តនេះពីមុនធ្វើនយោបាយខ្លះក្នុងបក្សបារាំង តែរួចទៅឈប់ហើយចេញពីបក្សនេះយូរឆ្នាំមកហើយ ។ ជាមិត្តរួមជាមួយស.ម រស់ ជិតធរ ដែលពលីទៅ ។ សព្វថ្ងៃមិត្តបារាំងនេះធ្វើការរកស៊ីធម្មតា ។ ពេលជួបជាមួយគាត់ខ្ញុំមិនដែលនិយាយអ្វីពីកម្ពុជាក្រៅពីពត៌មានចំហទេ ។ គាត់ក៏មិនសូវសួរអីដែរ ។ គាត់សម្ងំសុខយកតែរួចខ្លួន ។

### IV. ពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៦៣ ជារយៈកាលច្របូកច្របល់ផ្ទៃក្នុង

១-ខ្ញុំត្រឡប់មកប្រទេសវិញនៅចុងខែធ្នូ ឆ្នាំ១៩៥៥ ។ ខ្ញុំចូលធ្វើការក្នុងរទេះភ្លើង ។ បក្សបានណែនាំឲ្យចាត់តាំងជាសាខារទេះភ្លើងមួយអប់រំកម្មករ និងអ្នកធ្វើការនៅទីនោះ ។ នៅពេលនោះខ្ញុំបានទទួលការណែនាំជាប់ពីបក្សធ្វើជាលេខាសាខាបក្សនៅរទេះភ្លើង អប់រំសម្ងាត់កម្មករមួយចំនួន ចូលរួមសរសេរកាសែត «អុបស័រវ៉ាទ័រ»ផង ។

២-ពីខែវិច្ឆិកា ឆ្នាំ១៩៥៨ ដល់ខែមេសា ឆ្នាំ១៩៥៩ តាមការស្នើពីក្រសួងរទេះភ្លើង និងតាមការសម្រេចរបស់បក្ស ខ្ញុំបានទៅធ្វើកម្មសិក្សានៅក្រសួងរទេះភ្លើងជប៉ុន ។ ពេលនោះហើយដែលខ្ញុំបានពត៌មានអំពីព្រឹត្តិការណ៍អាក្បត់ សម សារី និង ដាប ឈួន ។ ហើយក៏បានដឹងឮអំពីសកម្មភាពអាចារបុរសជប៉ុនឈ្មោះ តាដាតូម៉ា ក្នុងចំណោមនិស្សិតខ្មែរនៅជប៉ុន ។

៣-ត្រឡប់ពីជប៉ុនវិញ ខ្ញុំនៅក្នុងសាខារទេះភ្លើងរហូតឆ្នាំ១៩៦១ ខែ៦ គឺពេលដែល សីហនុ វាយប្រហារខ្ញុំយ៉ាងខ្លាំង ។ ខ្លាំងវណ្ណៈវាធ្វើដូច្នេះ ព្រោះចលនាកម្មកររទេះភ្លើងឡើងខ្លាំងពេលនោះ ។

៤-បក្សបានសម្រេចឲ្យខ្ញុំផ្តាច់ការទាក់ទងមួយរយៈ (រវាងជិតមួយឆ្នាំ) ។ រដ្ឋអំណាចវណ្ណៈជិះជាន់ខ្ញុំបានផ្លាស់មកក្រសួងសាធារណការ ។ ក្នុងឆ្នាំ១៩៦២ បក្សបានផ្លាស់ខ្ញុំឲ្យមកធ្វើសកម្មភាពក្នុងចំណោមបញ្ញាជនវិញ និងតាមដានសភាព

ការណ៍វណ្ណៈកាន់អំណាច និងបរទេស ។ នៅពេលនោះខ្ញុំបាន ស្គាល់វរសេនីយ៍បារាំងម្នាក់ឈ្មោះ ម៉ារេ ។ តាមការទាក់ទងនេះ ខ្ញុំក៏យកបានពត៌មានខ្លះតែវា (ខ្ញុំដឹងក្រោយថា វាជាចារបុរស បារាំងរបស់ការិយាល័យទី២) ខំយកពត៌មានពីខ្ញុំដែរ ។ តែតាម ការពិនិត្យផ្ទាល់ខ្ញុំក៏មិនបានបែកការណ៍សម្ងាត់ជាមួយវាទេ ។

៥-ឆ្នាំ១៩៦៣ ក្រោយព្រឹត្តិការណ៍៣៤នាក់ បក្សបានលើកទិសដៅឲ្យខ្ញុំភៀសខ្លួនទៅប្រទេសបារាំងមួយរយៈពេល ។ មុនដំបូងខ្ញុំមានការព្រួយបារម្ភខ្លាំង ព្រោះមិនដឹងរស់យ៉ាងណា នៅប្រទេសបារាំង ។ តែដោយសភាពការណ៍តឹងតែងខ្លាំង ពេលនោះក៏ខ្ញុំបានសម្រេចស្នើបក្សសុំអនុញ្ញាតទៅប្រទេសបារាំង ។ បក្សក៏បានយល់ស្រប ។ ពេលនោះឃើញការភៀសខ្លួននេះ ស្មុគស្មាញច្រើន ។ តែក្រោយពីបានរៀនសូត្រពាក់ព័ន្ធពិនិត្យមើលខ្លួនឯងទៅឃើញថា ការភៀសខ្លួននេះក៏សមស្របនឹងសភាពការណ៍ជាក់ស្តែងរបស់ខ្លួន និងរបស់គ្រួសារខ្លួន ។

៦-ខែ៦ ឆ្នាំ១៩៦៣ ក្រោយពីបានទទួបសុំទិដ្ឋាការពីរដ្ឋអំណាចវណ្ណៈជិះជាន់អស់រយៈ២ខែ ខ្ញុំទៅប្រទេសបារាំងជាមួយកូនស្រីច្បងរបស់ខ្ញុំ ។ គ្រួសារខ្ញុំនិងកូន២ទៀត បានទៅជួបខ្ញុំនៅខែធ្នូ ឆ្នាំ១៩៦៣ ។ ខ្ញុំបានទៅប្រទេសបារាំងតាមក្រុងប្រាហ្គ (Prague) ដោយចង់ឆ្លៀតឱកាសពេលនោះស្គាល់ក្រុងនៃប្រទេសដែលគេហៅថា សង្គមនិយម ។ ខ្ញុំបាននៅក្រុងនេះ ២ថ្ងៃរង់ចាំយន្តហោះមកប៉ារីស ។

៧-ក្នុងរយៈពេល៧ឆ្នាំកន្លះនេះ ខ្ញុំបានទទួលការអប់រំច្រើនពីបក្ស និងបានចូលរួមសកម្មភាពច្រើនតស៊ូប្រឆាំងចក្រពត្តិ និងវណ្ណៈកាន់អំណាច ។ បានដកពិសោធន៍មួយចំនួនធំជាមួយកម្មករនិងជាមួយបញ្ញាជន ។ ពិតមែនតែខ្លាំងតាមដានសកម្មភាព ហើយយកវិធានការសង្កត់ តែសតិអារម្មណ៍រីករាយតស៊ូ ។ តែនៅពេលនោះក៏នៅគំនិតនិយមខ្លាំងដែរ ។ម្យ៉ាងទៀតទស្សនៈគោលជំហរវណ្ណៈមិនច្បាស់លាស់ទេនៅស្រពេចស្រពិល ។ រស់នៅដូចវណ្ណៈជិះជាន់ ។

(**នៅមានត**)

(**តមកពីទំព័រទី១**) ស្ត្រី និងកុមារតាមរយៈសុខាភិបាលសង្គមកិច្ចការងារ និងការអប់រំ មានន័យថា គ្រួសារខ្មែរក្រហមផ្តាច់ខ្លួនគួរត្រូវបានផ្តល់ឲ្យនូវសិទ្ធិស្មើគ្នានឹងពលរដ្ឋកម្ពុជាគ្រប់រូបក្នុងការទទួលសេវាកម្មសង្គម ។

ការពុំបានអនុវត្តនូវចំណុចទីពីរខាងលើឲ្យបានគ្រប់គ្រាន់ គឺមានន័យថា ជាការមិនអើពើចំពោះសេចក្តីត្រូវការជាមូលដ្ឋានរបស់មនុស្ស ហើយនិងអនុញ្ញាតជាប្រយោលដល់ក្រុមគ្រួសារខ្មែរក្រហមផ្តាច់ខ្លួនរស់នៅក្រៅការគ្រប់គ្រងដោយច្បាប់នៃសង្គមកម្ពុជា ។ មិនតែប៉ុណ្ណោះទៀតសោត ការពុំបានសម្រេចនូវកាតព្វកិច្ចជាប្រវត្តិសាស្ត្រទាំងពីរខាងលើនេះ ក៏មានន័យដែរថាពុំបានផ្តល់យុត្តិធម៌ដ៏សមរម្យមួយដល់ជនរងគ្រោះរាប់លាននាក់ដែលបានស្លាប់យ៉ាងអាណោចអធ័ម និងអយុត្តិធម៌ ហើយនិងគឺជាការបើកគម្របឲ្យ ប៉ុល ពត ដើរចេញពីផ្លូវទាំងកណ្តាលថ្ងៃត្រង់មកអបអរសាទរនូវជ័យជម្នះរបស់ខ្លួនជាបន្ត ។ យើងមិនត្រូវបណ្តោយឲ្យ ប៉ុល ពត ងើបពីផ្នូរមកទទួលជ័យជម្នះជាថ្មីតទៅទៀតឡើយ ។

**ឆាំង យុ**

## "គោលការណ៍ចំហក្នុងការបោសសម្អាតសត្រូវ អង្គការជំបូងបំផុត"

◆ ការស៊ើរូងបង្កប់ផ្ទៃក្នុងៈ ប្រទេសយើងក្បត់ស៊ីរូងពី១% ដល់៥% យើងត្រូវតាមដានប្រវត្តិរូបច្បាស់លាស់ និងជីវទស្សន៍ច្បាស់លាស់ ពិសេសក្នុងក្រសួងការបរទេស ទូតទាំងអស់ចង់ដឹងពីអ្នកដឹកនាំដើម្បីម្យ៉ាងរាយការណ៍ទៅប្រទេសគេ និងម្យ៉ាងទៀតមានបំណងអ្វីផ្សេង ។ (ដកស្រង់ចេញពីសៀវភៅកំណត់ហេតុថ្ងៃ២១ ខែឧសភា ឆ្នាំ១៩៧៦ ដល់ថ្ងៃ៥ ខែមករា ឆ្នាំ១៩៧៩ របស់ក្រសួងការបរទេសដែល អៀង សារី ហៅ សមមិត្ត វ៉ាន់ ជារដ្ឋមន្ត្រី) ។

◆ កម្មករ កសិករក្រ កសិករថ្នាក់កណ្តាលក្រោម និងស្រទាប់ពលករផ្សេងទៀតនៅជនបទនាទីក្រុង ឥតមានចំនួនច្រើនជាង៩០% នៃប្រជាជាតិកម្ពុជាទាំងមូលដែលបានទទួលបន្ទុកសង្គ្រាមបដិវត្តន៍សង្គ្រាមរំដោះប្រជាជនធ្ងន់សែនធ្ងន់ជាងគេបំផុតធ្វើពលី ពលីកម្មសែនធំធេងជាងគេបំផុត ទាំងអាយុជីវិត ទ្រព្យសម្បត្តិ ទាំងមនោសញ្ចេតនា...លះបង់កូនចៅ ប្តីសី រាប់ម៉ឺនរាប់សែននាក់... ។ (ដកស្រង់ចេញពីសៀវភៅកំណត់ហេតុរបស់មិត្ត វ៉ន សារ៉េត កម្មាភិបាលផ្នែកស៊ើបការណ៍ ឆ្នាំ១៩៧៥) ។ **ផាត កុសល**

# ភូមិចន្ទ្រាធ្លាក់ក្នុងវិនាសកម្មនៃសង្គ្រាម

***(តពីលេខមុន)***

*លោកតា សារិន រៀបរាប់ប្រាប់ថា ក្នុងឆ្នាំ១៩៧០ មានមនុស្សស្លាប់ទាំងអស់ជាង១០០នាក់ និងរបួសជាច្រើននាក់ បងជីដូនមួយខ្ញុំម្នាក់ឈ្មោះ ម៉ែ រឿត ស្លាប់ក្នុងឆ្នាំ១៩៧០ ពេលនោះគាត់កំពុងរត់ចេញពីភូមិនៅពេលយប់ ម៉ោងប្រហែល ៧យប់ រត់កាត់វាលស្រែទៅខាងកើតភូមិចន្ទ្រា ដើម្បីឆ្ពោះទៅរកត្រង់សេពួន ប៉ុន្តែមិនទាន់ទៅដល់ត្រង់សេផង គាត់ត្រូវគ្រាប់ផ្លោងស្លាប់ ។ ហើយនៅក្បែរផ្ទះខ្ញុំ មានផ្ទះក្បឿងពីរត្រូវគ្រាប់ផ្លោង ម្តាយនិងកូនពីរនាក់ត្រូវគ្រាប់ស្លាប់ ពេលនោះកូនមួយឈ្មោះ ផេតរាម កំពុងបៅដោះម្តាយ ។ បន្ទាប់ពីបាញ់ហើយ ពួកអាមេរិកបានយកអ្នករបួសមួយចំនួនទៅព្យាបាលនៅមុខរ៉ា ឧទាហរណ៍ដូចជា យាយ ស៊ិន (ឥឡូវគាត់ស្លាប់ហើយ) ។ យាយ ស៊ិន បានត្រូវដឹកតាមយន្តហោះយកទៅព្យាបាល ហើយពេលជាគេដឹកមកវិញតាមឡាន ។*

*ពេលផ្លោងនោះគ្រួសារខ្ញុំបានព្យាយាមរត់ចេញទៅភូមិប្រែះ តែខ្ញុំវង្វេងបែរជាទៅភូមិត្នោតវិញ ហើយខ្ញុំស្នាក់នៅផ្ទះអ្នកស្រុកមួយសន្ទុះបម្រុងនឹងនាំកូនដេកនៅខាងក្រោមផ្ទះ ពេលនោះខ្ញុំមើលទៅសភាពការណ៍មិនស្រួលក៏នាំគ្នារត់ទៅរកត្រង់សេតាមការណែនាំរបស់អ្នកភូមិត្នោត ។ ខ្ញុំពួននៅក្នុងត្រង់សេមួយសន្ទុះ បន្តិចមកមានម្នាក់ថា ចង្អៀតណាស់នៅមិនបានទេ រកត្រង់សេផ្សេងទៀត ខ្ញុំនិងគ្រួសារក៏ចេញពីត្រង់សេនោះសំដៅទៅរកត្រង់សេមួយនៅក្បែរ តែត្រង់សេនោះធំក្លិនអសោច ខ្ញុំមិនហ៊ានចុះក៏ដើរចេញបានបន្តិច គ្រាប់ផ្លោងក៏ធ្លាក់ចំកន្លែងខ្ញុំធ្វើឲ្យខ្ញុំវង្វេងអស់ ។ គ្រាប់បែកមួយគ្រាប់នោះធ្វើឲ្យកូនខ្ញុំពីរនាក់ត្រូវរបួសជាទម្ងន់ ។ ពេលនោះប្រពន្ធខ្ញុំបីកូនមួយ កូនដែលខ្ញុំ*



*យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*

*កំពុងដឹកដៃត្រូវត្រង់ក្លៀក កូនប្រុសមួយឈ្មោះ ទូច សយ (កើតឆ្នាំថោះ) ត្រូវរបួសជើង និងកូនស្រីបងឈ្មោះ ទូច សេង (កើតឆ្នាំកុរ) អាយុជាង១០ឆ្នាំ ដែលទូលសំពាយខោអាវដើរនៅក្បែរមាត់អណ្តូង បានស្រែកថា «ឪជួយផង» ពេលខ្ញុំឮ ខ្ញុំក្រឡេកទៅឃើញពោះរបស់កូនខ្ញុំរបកអស់ ។ រឿងទាំងនេះកើតឡើងក្នុងខែចេត្រ ឆ្នាំ១៩៧០ ។ បន្ទាប់ពីត្រូវរបួសហើយខ្ញុំក៏ចូលទៅរកត្រង់សេ ស្រាប់តែធ្លាក់៣-៤គ្រាប់ទៀត ។ បើសិនជាខ្ញុំមិនចូលត្រង់សេទេមុខតែស្លាប់គ្មានសល់ម្នាក់ ខ្ញុំសំណាងដែរកុំអីងាប់១ជាន់ទៀត ។ ខ្ញុំភ័យណាស់ ហៅបងប្អូន*

ឲ្យគេជួយ តែគេមិនហ៊ានជួយខ្ញុំទេ ព្រោះម្នាក់ៗភ័យខ្លាចទាំងអស់គ្នាគ្មាននរណាអាចជួយនរណាបានទេ ម្នាក់ៗគិតតែពួននៅក្នុងត្រង់សេរហូតដល់ស្ងប់ ។ ខ្ញុំមិនដឹងទៅណាមកណាទេ ពីព្រោះវាផ្ទុះផងអស់ហើយ ខ្ញុំប្រឹងទ្រាំនៅក្នុងត្រង់សេរហូតដល់ភ្លឺបាន ខ្ញុំនាំគ្រួសាររត់ទៅជំរំដើរបានពាក់កណ្តាលផ្លូវមើលទៅឃើញថា កូនដែលត្រូវរបួសទាំងពីរមិនសង្ឃឹមរស់ ខ្ញុំក៏ទុកចោលនៅពាក់កណ្តាលជ្រលងអូរ (ខាងកើតភូមិធំត្នោត) កូនខ្ញុំទាំងពីរនាក់នោះហៀបនឹងស្លាប់ហើយ អ៊ីចឹងខ្ញុំក៏ខំប្រឹងយកកូនដែលនៅរស់យកទៅដាក់នៅជំរំមុនហៅថាជំរំត្នោត៤ ភូមិកោះអណ្តែត ឃុំព្រែះ ។ ហើយបានវិលមកយកកូនរបួសជាក្រោយពេលខ្ញុំត្រលប់មកវិញជាមួយបងថ្លៃដោយសង្ឃឹមថានឹងពារកូនយកទៅជំរំ តែកូនខ្ញុំទាំងពីរក៏បានស្លាប់បាត់ទៅហើយ ។ ខ្ញុំក៏យកសពកូនទាំងពីរនាក់ទៅកប់ក្បែរជ្រលងអូរនោះទៅ ។ ពេលខ្ញុំទុកចោល ពួកវាមិនទាន់ស្លាប់ទេ ពួកវាសុំទឹកដឹក ខ្ញុំក៏ក្បង់ទឹកឲ្យដឹកបន្តក់ឲ្យបន្តិចៗ មិនហ៊ានឲ្យច្រើនទេ ។ ខ្ញុំដឹងច្បាស់ហើយ ថាវាមិនរស់ទេ បើមិនឲ្យទឹកដឹកក៏មិនបានដែរ ។ ពេលនោះពួកវាទាំងពីរនាក់ជិតបាត់ស្មារតីអស់ហើយ មិនដឹងអ៊ីទាំងអស់មានម្នាក់ត្រូវជើងហូរឈាមច្រើនណាស់ ។

នៅឆ្នាំ១៩៧០ ប្រជាជនភូមិចន្ទ្រាទាំងអស់ផ្លាស់ទៅនៅជំរំត្នោត៤ ពេលនោះរើទៅតែខ្លួនទេ បន្ទាប់មកបានត្រឡប់មកយករបស់របរប្រើប្រាស់ ជាពិសេសយកអង្ករ ។ ពួកវៀតកុងលាក់ខ្លួននៅកន្លែងណាមានព្រៃស៊ុបទ្រុបមានឫស្សី ។ រៀងរាល់ព្រឹកពួកវាដឹកបន្លែមកទាំងបាវៗដើម្បីឲ្យទ័ពវា ។ ទ័ពវៀតកុងនោះអ្នកស្រុកហៅថាទ័ពបៀផុង ។ នៅពេលបាញ់គ្នា ពួកវៀតកុងមិនឲ្យយើងរត់ចេញជាដាច់ខាត ប្រសិនបើវាឲ្យរត់ចេញមិនសូវស្លាប់ខ្មែរយើងច្រើនទេ។ បើប្រជាជនចេញពីភូមិអស់ហើយ អាមេរិកដឹងថានៅភូមិមានតែពួកវៀតកុងនោះពួកអាមេរិកនឹងបាញ់ដាក់ភូមិតាមចិត្ត ពួកវៀតកុងយកខ្មែរធ្វើជាខែល ។ រហូតដល់ពួកអាមេរិកវាយបែកហើយ ពួកវៀតកុងរត់ខ្ចាត់ខ្ចាយ ទើបប្រជាជនអាចរត់ចេញពីភូមិបាន ។ ពេលពួកអាមេរិកចូលដល់ភូមិ វាឲ្យត្រីខកំប៉ុង បាយកាតាត (បាយក្រៀម) ជាច្រើនដល់អ្នកភូមិ ។ បងខ្ញុំឈ្មោះ ជន ក៏បានដែរ ។

តាមសម្តីរបស់ពូ សូ សារ៉ុន អាយុ៥៨ឆ្នាំ ជាកសិករ មានស្រុកកំណើតនិងទីលំនៅនៅភូមិចន្ទ្រា ឃុំចន្ទ្រា ស្រុកចន្ទ្រា ខេត្តស្វាយរៀងបានរៀបរាប់ថា ពេលខ្ញុំអាយុ១២ឆ្នាំ ខ្ញុំរៀនបានបញ្ចប់មធ្យមសិក្សាកម្រិត១ ។ ខ្ញុំរៀនបានតែ៥ឆ្នាំប៉ុណ្ណោះ ។ ពេលនោះខ្ញុំបានប្រឡងជាប់ កម្រិតសិក្សាទី១ហើយ តែត្រូវឈប់រៀនដើម្បីមកជួយធ្វើការឪពុកម្តាយ និងម្យ៉ាងទៀតសាលារៀននៅភូមិដីភូឆ្ងាយពីផ្ទះ ។ ដល់ឆ្នាំ១៩៦៤ មានទម្លាក់គ្រាប់បែកបេ៥២របស់អាមេរិក មកលើឃុំចន្ទ្រាទាំងមូល ។ ពេលនោះខ្ញុំបានធ្វើស្រែ និងស្នាក់នៅផ្ទះអ៊ីរបស់ខ្ញុំនៅភូមិគោកតែក ឃុំចន្ទ្រា ។ ពេលដែលខ្ញុំកំពុងតែដាន់ស្រូវក្បែរផ្ទះនៅម៉ោងប្រហែល១០ព្រឹក ស្រាប់តែមានយន្តហោះមកទម្លាក់ភ្លើងសញ្ញាដំបូង បន្ទាប់មកមានយន្តហោះមកទម្លាក់គ្រាប់តាមក្រោយនិងមានរថក្រោះបើកមកពីខាងត្បូងព្រំដែនសំដៅចូលមកភូមិ ព្រមទាំងមានទ័ពថ្មើរជើងរបស់ធីវគីទៀតផង ។ ព្រឹត្តិការណ៍ដែលកើតឡើងឆ្នាំ១៩៦៤នោះ មានប្រជាជនស្លាប់ខ្លះ និងទ្រព្យសម្បត្តិមួយចំនួនត្រូវឆេះអស់ ។ ដូចជាផ្ទះរបស់ឪពុក ជើក នេត ត្រូវឆេះអស់រួមទាំងកូនពីរនាក់ឆេះរលាកក្នុងនោះដែរ ហើយពូជីដូនមួយខ្ញុំម្នាក់ឈ្មោះ ខៀវប៉ុន កាលណោះអាយុ៤០ បានស្លាប់ពេលនោះគាត់ជាកងជីវពល ។

មកដល់ឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែករឹតតែធ្ងន់ធ្ងរជាងឆ្នាំ១៩៦៤ទៅទៀត ។ ការប្រយុទ្ធគ្នាបានប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា៣ថ្ងៃ៣យប់ ហើយប្រជាជនពួននៅក្នុងត្រង់សេរហូតដោយគ្មានបាយគ្មានទឹក ។ ពេលដែលមានការបាញ់គ្នា និងទម្លាក់គ្រាប់បែកនោះមានប្រជាជនមួយចំនួនបានរត់ទៅភូមិក្បែរពួកអាមេរិក ។ ខ្ញុំបានរត់ចេញពីភូមិចន្ទ្រាទៅនៅភូមិផ្សេង ហើយក្រោយមកខ្ញុំសុំពួកវៀតកុងចូលមកយកឪពុកម្តាយនិងបងប្អូនចេញពីភូមិ ។ ពេលស្ងាត់សង្គ្រាមបន្តិចពួកអាមេរិក និងពួកធីវគីជិះខ្ទម្ពាគចក្រស្រែកតាមមេក្រូឲ្យប្រជាជនខ្មែររត់ចេញពីភូមិចន្ទ្រា ។ អ្នកនិយាយនោះជាទាហានធីវគី ដែលចេះភាសាខ្មែរច្បាស់ ។ ប៉ុន្តែពួកវៀតកុងមិនឲ្យប្រជាជនខ្មែរចេញពីភូមិទេ ព្រោះពួកវាខ្លាចស្លាប់ដែរ ។ ពួកវៀតកុងចូលត្រង់សេជាមួយប្រជាជនដែរ ។ ពេលនោះមានស្ត្រី មានផ្ទៃពោះម្នាក់បានឆ្លងទន្លេនៅក្នុងត្រង់សេ ។ ក្នុងឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧២ គ្មានប្រជាជនរស់នៅក្នុងភូមិចន្ទ្រាទេ ប្រជាជននាំគ្នាទៅនៅភូមិព្រែះ,

ភូមិជីភូ ក្នុងឃុំព្រៃះ ខ្លះទៀតរត់ទៅនៅបារិត ។ ពេលមុនសង្គ្រាម ពួកវៀតកុងមិនដែលប៉ះពាល់របស់របរទ្រព្យសម្បត្តិរបស់ប្រជាជនទេ ។ តែក្រោយមកបន្ទាប់ពីប្រជាជនរត់ចេញពីភូមិទៅនៅភូមិដទៃទៀត ហើយក្រោយពីសង្គ្រាមធ្វើឲ្យផ្ទះបាក់ខ្ទេចខ្ទី ពួកវៀតកុងបានរុះរើផ្ទះយកទៅដុតតាមតែអំពើចិត្ត ពួកវៀតកុងបានបំផ្លាញយើងក្រោយឆ្នាំ១៩៧០ ។ ពេលពួកអាមេរិកនិងពួកធីវគីចូលលុកលុយភូមិដើររកពួកវៀតកុង ពួកធីវគីបានចាប់មាន់ទា និងយកមាសប្រាក់ប្រជាជន ។ ពេលនោះមានប្រជាជនស្លាប់ច្រើន ហើយទ្រព្យសម្បត្តិត្រូវបំផ្លាញខ្ទេចខ្ទីអស់ ផ្ទះសម្បែង វត្តអារាម សាលារៀន មន្ទីរពេទ្យត្រូវឆេះអស់ ។ ដោយសារតែពួកវៀតកុងមកជ្រកកោននៅភូមិចន្ទ្រា អ៊ីចឹងហើយបានជាអាមេរិកមកទម្លាក់គ្រាប់បែកនិងមានការបាញ់ផ្លោងពីពួកទ័ពធីវគីទៀត ។ សង្គ្រាមចេះតែបន្តរហូតមកនៅក្នុងឆ្នាំ១៩៧៣ ។ ដោយមានការខ្វះខាតម្ហូបអាហារ ខ្ញុំនិងប្រជាជនដទៃទៀតបាននាំគ្នាទៅចងសន្ទូចនៅបឹងខាងត្បូងភូមិតែងម៉ោ ។ ពេលនោះស្រាប់តែមានឧទ្ធម្ភាគចក្រមួយគ្រឿងរបស់អាមេរិកជិះគ្នាពីរនាក់បានមកបាញ់ពួកខ្ញុំដែលកំពុងចងសន្ទូចដែលមានគ្នា៥នាក់ ធ្វើឲ្យស្លាប់១នាក់ ហើយគ្រាប់ចុងក្រោយធ្វើឲ្យរបួសជើងស្តាំរបស់ខ្ញុំ ។ ចំណែកអ្នកនេសាទ៧នាក់ទៀតដែលកំពុងនេសាទក្បែរខ្ញុំនោះ ត្រូវទាហានអាមេរិកបាញ់ស្លាប់អស់៥នាក់ និងរបួស២នាក់ ។ អ្នកទាំងនោះមានកូនលោកតាអាចារ្យណី ម្នាក់ឈ្មោះ សា និង វាត់ ស្លាប់នៅព្រំដែនវៀតណាម ។ នៅពេលឧទ្ធម្ភាគចក្រនោះមកដល់ពួកខ្ញុំបានលើកទង់សជាសញ្ញាហើយ ហើយខ្ញុំមិននឹកស្មានថាពួកអាមេរិកនៅតែបាញ់ទេ ។ ព្រោះអីកាលពីមុនឲ្យតែមានទង់សពួកអាមេរិកមិនធ្វើអីទេ ។ ពួកអាមេរិកបានប្រកាសប្រាប់ប្រជាជនពេញភូមិថា បើប្រជាជនខ្មែរដើរទៅណាត្រូវមានទង់សជាប់នឹងខ្លួន ។ ខ្ញុំមិនបានរត់ពួនទេ ព្រោះអាងទង់ស ។ ប៉ុន្តែលើកនេះខ្ញុំលើកទង់ស ហើយតែពួកវានៅតែបាញ់បំពានមកលើខ្ញុំ និងក្រុមខ្ញុំទៀត ។ កាលណាមានឧទ្ធម្ភាគចក្ររបស់អាមេរិកមក (យន្តហោះឆែកកាត) ប្រជាជនដែលកំពុងធ្វើដំណើរត្រូវឈប់ដើម្បីឲ្យធ្វើការឆែកឆេរ ។ ពួកអាមេរិកនៅលើយន្តហោះនោះ ចង្អុលឲ្យដោះអាវ យើងត្រូវតែដោះអាវ ស្រាតខោត្រូវស្រាតខោ ឲ្យវាមើលរួចវាមិនធ្វើអីប្រជាជនទេ ។ បើមានរបស់របរអីត្រូវរើឲ្យវាមើល វាហោះក្រឡឹងហើយតម្រង់កាំភ្លើងមករកប្រជាជនឃើញថាគ្មានស្អី (អាវុធ) បានវាឲ្យទៅ ។



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ខ្ញុំឈឺចាប់ណាស់ ពីព្រោះអ្នកខ្លះអស់ទ្រព្យសម្បត្តិ ខ្លះស្លាប់បងប្អូន **«ប៉ុន្តែយើងជាប្រជាជនចេះតែអត់ទ្រាំទៅ»** ។

រឿងរ៉ាវនៅភូមិចន្ទ្រានេះគឺត្រូវបានអ្នកភូមិចន្ទ្រារៀបរាប់ដូចគ្នាៗពីសកម្មភាពនិងទុក្ខវេទនារបស់ប្រជាជន ដូចក្រុមស្រាវជ្រាវយើងបានសម្ភាសអ្នកភូមិចន្ទ្រាដែលជាជនរងគ្រោះចំនួន១០នាក់ ។ អ្នកទាំង១០នាក់នោះមាន ប្រាក់ សារិន,



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ដើក នេត, សូ សាវុន, សោម ឆើត, សុក ឡូម, ហឹង បោយ, សុខ បំរើន, ពុត សយ, ភោគ ទែន និង មាស ហ៊ុង ។

សង្រ្គាមវៀតណាមនិងអាមេរិក បានទន្រ្ទានចូលដល់ទឹកដីកម្ពុជា ហើយបានធ្វើឲ្យប្រជាជនរាប់រយនាក់នៅក្នុងឃុំចន្រ្ទាគ្មានផ្ទះសម្បែង គ្មានទីលំនៅពិតប្រាកដ និងខ្វះស្បៀងអាហារ ។ អ្នកភូមិចន្រ្ទាជាង១០០ នាក់ស្លាប់ជាអសារបង់ ហើយមានប្រជាជនជាច្រើននៅក្នុងឃុំចន្រ្ទាទាំងមូល ខ្លះស្លាប់ ខ្លះត្រូវពិការ និងខ្លះរបួសទាំងផ្លូវចិត្ត និងផ្លូវកាយដោយគ្មានអ្នកណាមកអើពើ ឈឺឆ្អាល អាណិតអាសូរសោះឡើយ តាំងពីឆ្នាំ១៩៧០មកម្ល៉េះ ។ ឆ្លងតាមរយៈ ការសម្ភាសន៍ក៏បានឲ្យដឹងថានៅក្នុងឃុំចន្រ្ទា ភូមិតែងម៉ៅមានឧទ្ធម្ភាគចក្រអាមេរិក២គ្រឿងធ្លាក់ ហើយអាកាសយានិកអាមេរិកពីររូបបានស្លាប់នៅទីនោះ ។ នៅអំឡុងឆ្នាំ១៩៩៦ និងកាលពីខែកុម្ភៈ ឆ្នាំ២០០០ នេះ មានក្រុមស្វែងរកអដ្ឋិធាតុទាហានអាមេរិកាំងមួយក្រុមបានចុះទៅដល់ភូមិចន្រ្ទា និងភូមិតែងម៉ៅ ដើម្បីស្វែងរកអដ្ឋិធាតុទាហានអាមេរិកដែលបានបាត់ខ្លួននៅទីនោះ ។ ទោះជាព្រឹត្តិការណ៍ដ៏ខ្លោចផ្សាទាំងនេះស្ថិតក្នុងការចងចាំដែលមិនអាចបំភ្លេចបានយ៉ាងណាក៏ដោយ ក៏អ្នកភូមិស្វាគមន៍ក្រុមស្វែងរកអដ្ឋិធាតុនេះយ៉ាងរាក់ទាក់ ហើយខ្នះខ្នែងជួយនាំទៅបង្ហាញពីទីកន្លែងដែលធ្លាក់ឧទ្ធម្ភាគចក្រថែមទៀតផង ។

**និនទ្រី, សុភះវិជ្ជា**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០៣៥៨
ឬ Email: dccam@bigbond.com.kh

# ប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ [នៃរបបកម្ពុជាប្រជាធិបតេយ្យ]

**បទឧទ្ទេសនាមរបស់សមមិត្តលេខា**
**ក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ថ្ងៃ២២ មេសា ១៩៧៦**

## I. *រូបភាពចាត់តាំង និងអត្ថន័យនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ*

ការដែលយើងមកប្រជុំថ្ងៃនេះគឺជាការប្រជុំលើកដំបូងរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់យើង ។ យើងបានបញ្ចប់រដ្ឋាភិបាលចាស់ក្នុងក្របខ័ណ្ឌរណសិរ្សរួបរួមជាតិកម្ពុជា ហើយបានចាត់តាំងរដ្ឋាភិបាលថ្មីក្នុងក្របខ័ណ្ឌថ្មី ក្នុងកាលៈទេសៈថ្មី ។ ធាតុពិតរបស់រដ្ឋាភិបាលថ្មីរបស់យើង គឺជារដ្ឋាភិបាលបដិវត្តន៍របស់កម្មករ-កសិករសុទ្ធសាធ របស់បក្សកុម្មុយនិស្តកម្ពុជាសុទ្ធសាធ ។



ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ដូច្នេះ យើងចាប់ផ្តើមបញ្ចេញនូវមុខមាត់នូវតួនាទីរបស់យើងពេញលេញទាំងអស់ចំពោះប្រទេសជាតិ និងប្រជាជនចំពោះកងទ័ពបដិវត្តន៍ និងចំពោះសកលលោកទាំងមិត្តទាំងសត្រូវ ។ រដ្ឋាភិបាលយើងមិនចម្រុះដូចមុនទេ ។ **ការខុស ការត្រូវ ការល្អមិនល្អ ចំណេញខាត ក្នុងប្រទេសក្តី ក្រៅប្រទេសក្តី ចំពោះមិត្តក្តី ចំពោះសត្រូវក្តី គឺយើងទទួលរ៉ាប់រងទាំងអស់ គ្មាននរណាក្រៅពីខ្លួនយើងទៀតទេ ។**

យើងបញ្ជាក់នូវធាតុពិតរបស់រដ្ឋាភិបាលយើង គឺចង់បង្ហាញឲ្យឃើញច្បាស់នូវតួនាទីរបស់យើងនូវបន្ទុកធ្ងន់ធ្ងរនិងទាំងស្រុងរបស់យើង ។ បើឃើញច្បាស់ហើយយើងនឹងចាប់អារម្មណ៍គិតគូរពង្រឹងនិងពង្រីកស្មារតីទទួលខុសត្រូវថែមទៀតក្នុងគ្រប់សកម្មភាពលើគ្រប់ផ្នែកទាំងអស់ ទាំងក្នុងប្រទេស ទាំងក្រៅប្រទេស ។

ដូច្នេះសមាជិករដ្ឋាភិបាលនិងសមាជិករបស់គណៈកម្មាធិការគ្រប់ផ្នែកត្រូវក្តាប់នូវធាតុពិតរបស់រដ្ឋាភិបាលយើងនូវតួនាទីរបស់យើង ហើយខិតខំបំពេញភារកិច្ចឲ្យបានល្អទៅតាមមាគ៌ារបស់បក្ស ។ ក្តាប់មាគ៌ារបស់បក្សបានន័យថាក្តាប់គោលជំហរចាត់តាំងរបស់បក្ស និងក្តាប់សំណូមពរនយោបាយរបស់បក្សលើគ្រប់ផ្នែកដើម្បីអនុវត្តន៍គោលនយោបាយរបស់បក្សឲ្យបានល្អ និងត្រឹមត្រូវ ។

សកលលោកស្គាល់តួនាទីរបស់យើងហើយ ។ ដូច្នោះទាល់តែបំពេញឲ្យតួនាទីនេះមានលក្ខណៈកាន់តែប្រពៃសមរម្យ ទទួលការកក់ក្តៅនិងទទួលការខបត្ថម្ភគាំទ្រពីសកលលោកចំពោះយើងឲ្យកាន់តែច្រើនថែមទៀត ។ សូម្បីខ្មាំងសត្រូវក៏ដោយ ក៏គោរពញញើតយើងដែរ ។

នេះនិយាយរួមក្នុងក្របខ័ណ្ឌរដ្ឋាភិបាលទាំងមូល ។ តែក្នុងក្របខ័ណ្ឌក្រសួងនីមួយៗក៏ដូច្នោះដែរ ។ គឺត្រូវខិតខំបំពេញភារកិច្ចតាមមាគ៌ារបស់បក្សឲ្យបានត្រឹមត្រូវហ្មត់ចត់ និងពេញលេញដណ្តើមកម្លាំងនិងពង្រីកកម្លាំងឲ្យបានជាអតិបរមា ពិសេសជំរុញមហាជនឲ្យរីករាយស្ទុះស្ទារសកម្មក្លៀវក្លាក្នុងការងារបដិវត្តន៍របស់យើង ។

## II. *អត្តភាព និងប្រតិកម្មក្នុងសកលលោកចំពោះការចាត់តាំងរដ្ឋាភិបាលថ្មីនៃកម្ពុជាធិបតេយ្យរបស់យើង*

ប្រតិកម្មសកលលោកចំពោះការចាត់តាំងរដ្ឋាភិបាលថ្មីរបស់យើងមានពីរផ្នែកគឺៈ

- ផ្នែកចក្រពត្តិមិនពេញចិត្ត

-ផ្នែកប្រទេសជាមិត្ត ពេញចិត្តឧបត្ថម្ភគាំទ្រយើង ។

**១-ផ្នែកប្រតិកម្មមិនល្អ**

ចក្រពត្តិអាមេរិកនិងបរិវារវាដូចបានជម្រាបរួចហើយ មិនពេញចិត្តនឹងយើងទេ ។ វារកតែឱកាសដេរយើង ។

ក-មូលហេតុសំខាន់ដែលនាំឲ្យវាមិនពេញចិត្តគឺយើងដើរតាមផ្លូវបដិវត្តន៍ត្រឹមត្រូវ ហើយចលនាបដិវត្តន៍យើងមានដំណើរវិវឌ្ឍន៍កាន់តែល្អឡើងៗ ។ យើងពង្រឹងនិងពង្រីកខ្លួនកាន់តែរឹងប៉ឹង ។ វាវាយយើងមិនបែកទាំងនយោបាយសតិអារម្មណ៍ ទាំងចាត់តាំង ទាំងយោធា ទាំងសេដ្ឋកិច្ច ទាំងទូត ។ វាបរាជ័យហើយបរាជ័យទៀតជាបន្តបន្ទាប់ ធ្វើអីយើងមិនបាន ។

ខ-បរាជ័យមួយខាងនយោបាយ គឺក្រោយយើងរំដោះវាសង្ឃឹមថា សីហនុ និងបក្សពួកនៅមានឥទ្ធិពលច្រើន ។ សីហនុ និងបក្សពួកមានលទ្ធភាពប្រមូលកម្លាំងឡើងវិញ ដើម្បីអុកឡុកយើង ធ្វើឲ្យយើងមានការលំបាកគ្រប់ផ្នែក ហើយតាមរយៈនេះវាសង្ឃឹមថាបំផុសប្រជាជនឲ្យឧបត្ថម្ភសីហនុ ។ ដូច្នេះយើងត្រូវបែងចែករដ្ឋអំណាចឲ្យ សីហនុ ខ្លះគឺមានក្រហម មានខៀវលាយគ្នា កុំឲ្យក្រហមសុទ្ធ ។ ចក្រពត្តិអាមេរិកមានផែនការយ៉ាងនេះ ។ ចក្រពត្តិឯទៀតក៏យ៉ាងនេះ ។ សូវៀតក៏យ៉ាងនេះ ។ **បើយើងដំណើរការជាមួយ សីហនុ យើងទៅមុខមិនលឿនទេ វាឆ្លៀតឱកាសវាយយើងទៀត ទាំងខាងលិច ទាំងខាងកើត ។ ប៉ុន្តែមួយថ្ងៃបន្តិចៗ វាកាន់តែអស់រហូតដល់ថ្ងៃ សីហនុ ត្រូវលាលែង ។ វាសង្ឃឹមថា សីហនុ និងបក្សពួកលើកទង់ជាតិនិយមប្រឆាំងបដិវត្តន៍មិនបាន ។ ប៉ុន្តែ សីហនុ មិនបានលើកទង់ទេ គាត់បន្ទួតទង់ចុះទៅវិញ ។ គ្មាននរណាបន្ទួតទេ គឺគាត់ខ្លួនឯង ។ ដល់ សីហនុ លាឈប់ សកលលោកគ្មានប្រតិកម្មអី ។ សកលលោកផ្នែកខាងមិត្តឧបត្ថម្ភគាំទ្រយើងយ៉ាងកក់ក្តៅ ។ នេះហើយដែលនាំឲ្យវាខឹងខ្លាំង ។**

គ-បរាជ័យរបស់វាមួយទៀតគឺខាងសតិអារម្មណ៍វាចូលមិនចុះខាងផ្នែកពុករលួយ សីលធម៌ អាវាសែ ។ ដូច្នោះបានជាកាសែតវាថាកម្ពុជាធ្វើបដិវត្តន៍ខុសពីវៀតណាម និងខុសពីលាវ ។



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ត្រង់នេះចង់បង្ហាញ ថានៅវៀតណាមនិងនៅលាវវាចូលចុះដោយវារក្សាធាតុពុករលួយបានជាមូលដ្ឋាន ។ តាមរយៈវារស់នៅជាមូលដ្ឋាននេះ ទើបវាអុកឡុកខាងនយោបាយ ខាងសេដ្ឋកិច្ច និងខាងយោធា ។ ឯយើងវាចូលមិនចុះគ្រប់ផ្នែក ។ ដូច្នោះបានជាវាដេរយើង ។ ត្រង់នេះយើងមិនប្លែកទេ ។ ផ្ទុយទៅវិញ បើកាលណាវាសរសើរយើងនោះ យើងត្រូវប្រុងប្រយ័ត្ន ។ វាចូលចុះហើយបានជាវាពេញចិត្តយើងនិងសរសើរយើង ។

បដិវត្តន៍យើងប្រៀបធៀបនឹងបដិវត្តន៍សកលលោកវាដេរតិចនៅឡើយ ។ ជំនាន់ឡេនីនវាដេរសូវៀតសម្បើមណាស់ ។ យប់ក៏ដេរ ថ្ងៃក៏ដេរ ពេញ២៤ម៉ោង ។ សម័យស្តាលីនក៏វានៅតែដេរ ។ បដិវត្តន៍ចិនក៏ដូច្នោះ ។ ១០ឆ្នាំ ១៥ឆ្នាំ ក្រោយរំដោះទើបមានប្រទេសមួយចំនួនទាក់ទងចិន ។ ឯយើងវាដេរម្តងម្កាលទេ ។ ក៏ប៉ុន្តែវាដេរយើងឥឡូវមិនសូវមានប្រសិទ្ធិភាព ។ ម្យ៉ាង

មកពីបដិវត្តន៍សកលលោកកាន់តែរីកចម្រើនប្រជាជនសកលលោកនឹងយល់អ៊ីជាបដិវត្តន៍អ៊ីមិនបដិវត្តន៍។ នេះជាកត្តាសត្យានុម័តិ។ មួយទៀតខាងអត្តនោម័តិវិញ ក៏យើងមានជំហរត្រឹមត្រូវ។ យើងមិនបញ្ចេញគួ មិនអួតអាង មិននាំបដិវត្តន៍យកទៅក្រៅធ្វើឲ្យគេឯងភ័យខ្លាច។ យើងរក្សានយោបាយឯករាជ្យ សន្តិភាព



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធណា។ នេះហើយដែលនាំឲ្យយើងប្រមូលកម្លាំងបានជាអតិបរមា ហើយខ្មាំងសត្រូវវាត្រូវឯកោជាអតិបរមា។ ដូច្នោះវាក៏ពិបាកជេរយើងដែរ។ មួយខែវាជេរយើងម្តងឬពីរដង។ វាជេរយើងយ៉ាងនេះគឺល្អឲ្យយើងព្រោះវាធ្វើឲ្យយើងក្តៅជាប់។ បើវាមិនជេរយើងសោះ ១ខែ ១ឆ្នាំ យូរៗទៅយើងកាន់តែត្រជាក់ កាន់តែស្ពឹក ខ្វះប្រុងប្រយ័ត្នបដិវត្តន៍មិនខាន។ ដូច្នោះ យើងយកចំណុចនេះមកដុតកម្តៅគោលជំហរយើងទៀត។ ***យើងធ្វើល្អយ៉ាងណាក៏ដោយ បើចក្រពត្តិវានៅសេអ៊ីអាវានៅពួកប្រតិកិរិយាវានៅមិនទាន់អស់ពីសកលលោក វានៅតែបន្តប្រឆាំងបដិវត្តន៍ប្រឆាំងយើងទៀត ប្រឆាំងនឹងអ្វីដែលចម្រើនទាំងចំហ ទាំងសម្ងាត់។ នេះជាការធម្មតាទេ។***

**២.ផ្នែកប្រតិកម្មល្អ:**

**ក.ប្រភេទប្រទេសដែលមានប្រតិកម្មល្អ:** ទី១: ប្រទេសជាមិត្តគេជូនពរសរសើរនិងអបអរចំពោះការចាត់តាំងថ្មីនៃអង្គការរដ្ឋបដិវត្តន៍របស់យើងយ៉ាងកក់ក្តៅ។ គេពេញចិត្ត ហើយគ្មានឃើញទិដ្ឋភាពអ៊ីគួរឲ្យសោកស្តាយចំពោះ សីហនុ ទេ។ ដូច្នោះគេឧបត្ថម្ភយើងពេញទី។ ទី២: ប្រទេសដែលពីមុនមិនសូវជិតស្និទ្ធដូចជាឥណ្ឌា សេរីលង្កា ភូមា ម៉ាឡាយូ ក៏អបអរសាទរចំពោះយើងដែរ ក្នុងន័យថាគេត្រូវការយើង។ គេឃើញច្បាស់ថា តាមរយៈការចាត់តាំងថ្មីនេះ កម្ពុជាពិតជាស្ថិតនៅក្នុងកណ្តាប់ដៃបដិវត្តន៍កម្ពុជា។ គេត្រូវការយកយើងធ្វើជាគូសន្ទនាជាគូទាក់ទងដើម្បីឧបត្ថម្ភគេទាំងប្រយោលទាំងចំពោះ។ នេះមកពីយើងមានឥទ្ធិពលលើសកលលោក។ ទី៣: ប្រទេសដែលតែងតែប្រឆាំងនឹងយើងក្នុងសម័យសង្គ្រាមនិងក្រោយសង្គ្រាម ដូចជាឥណ្ឌូនេស៊ី ក៏ឆ្លៀតអបអរយើងដែរ។ ការអបអរសាទរនេះជាការទទួលស្គាល់នូវអង្គការរដ្ឋថ្មីរបស់យើង។

**ខ.មូលហេតុដែលនាំឲ្យមានប្រតិកម្មល្អ:**

ទី១: មកពីសភាពការណ៍អត្តនោម័តិយើងល្អ ក្នុងន័យថាគ្មាននរណាគ្រប់គ្រងកម្ពុជាក្រៅពីខ្លួនយើងទៀតទេ។ អ្នកកាន់អំណាចពិតប្រាកដទាំងស្រុងនិងពេញលេញគឺជនបដិវត្តន៍កម្ពុជា។ ដូច្នោះបើចង់ទាក់ទងទាល់តែទាក់ទងអ្នកទាំងនេះ។ បញ្ហានេះនរណាក៏ឃើញច្បាស់ ។

ទី២: នយោបាយក្នុងប្រទេសនិងក្រៅប្រទេសរបស់យើងត្រឹមត្រូវ។ យើងស្រឡាញ់ឯករាជ្យ សន្តិភាព អព្យាក្រឹត អធិបតេយ្យភាព ហើយមិនចូលបក្សសម្ព័ន្ធណា។ យើងមិនសម្តែងគួយក្ស មិនគំរាមកំហែងគេឲ្យខ្លាច ឲ្យគេបារម្ភ។ យើងមិនរុកគួនគេ យើងចង់រួមរស់ដោយសន្តិភាពជាមួយប្រទេសទាំងអស់

ដើម្បីស្តារសេដ្ឋកិច្ចកសាងប្រទេស ពិសេសនយោបាយយើងជាមួយថៃ ។ ពីមុនថៃជាសត្រូវយើងយ៉ាងខ្លាំងយើងក៏នៅតែទាក់ទង ។ នេះបង្ហាញយ៉ាងជាក់ស្តែងនូវនយោបាយក្រៅប្រទេសរបស់យើង ។ នៅក្នុងសន្និសីទអន្តរជាតិផ្សេងៗយើងក៏បានបញ្ជាក់អំពីគោលជំហររបស់យើង ។ ពេលសង្គ្រាមតស៊ូក៏បានបញ្ជាក់ ពេលរំដោះហើយក៏បញ្ជាក់ទៀត រហូតដល់ពេលចាត់តាំងអង្គការរដ្ឋថ្មីក៏យើងបញ្ជាក់យ៉ាងច្បាស់លាស់ទៀត ។ សកលលោកស្តាប់សេចក្តីប្រកាសរបស់យើងឃើញថា យើងជាអ្នកស្លូតបូតត្រឹមត្រូវមិនមែនខូចកាចរករឿងគេឯង ។

ទី៣ៈ យើងដោះស្រាយបញ្ហាយើងដោយខ្លួនយើងដោយជំហរឯករាជ្យម្ចាស់ការខ្លួនឯងបត្តម្ភខ្លួនកម្រិតខ្ពស់បំផុត ហើយយើងដោះស្រាយបាន ។ ឧទាហរណ៍ៈ អាមេរិកថា ផ្កាយវិទ្យាសាស្ត្រវាថតឃើញថាស្រូវ យើងល្អ...រួចយើងផ្តល់ជាជំនួយស្រូវ ៣០០០តោនឲ្យលាវទៀតក្នុងលក្ខណៈដែលយើងទើបនឹងចេញពីសង្គ្រាមវិនាសកម្មផង ។ ចំណែកភូមាដែលល្បីថាមានស្រូវច្រើនជួយលាវតែ៣០០តោនទេ ។ ដូច្នោះសភាពការណ៍យើងខុសពីវៀតណាម និងខុសពីលាវឆ្ងាយណាស់ ។ ទូតបរទេសដែលមកធ្វើទស្សនកិច្ចក្នុងខែ១ ក្នុងខែ២ និងខែ៣ ក្នុងប្រទេសយើងក៏បានឃើញច្បាស់ហើយ ផ្សព្វផ្សាយក្នុងសកលលោកនូវការខិតខំរបស់យើងដើម្បីកសាងប្រទេសដោយខ្លួនយើងដោយឯករាជ្យម្ចាស់ការខ្លួនឯងបត្តម្ភខ្លួនបានមួយកម្រិតដែរ ។ ឥឡូវនេះគេជឿជាក់ថា យើងដោះស្រាយបាន ។

-ទី៤ៈ យើងអត់រណបនរណា ទាំងអស់គ្នាសន្និដ្ឋានថាយើងអត់រណបនរណា ។ សូវៀតក៏យើងមិនរណប ចិនក៏យើងមិនរណប ។ តែកុម្មុយនិស្តច្បាស់ហើយ តែបដិវត្តន៍ដាច់ខាតច្បាស់ហើយ ។ នេះជាសំណួមពរសំខាន់របស់បក្ស ។ បក្សចង់បានយ៉ាងនេះព្រោះវាជាដង្ហើមមួយ ជាព្រលឹងមួយ ។ ពីដើមគេនិយាយពីឥណ្ឌូចិនអីចេះអីចុះ ។ យើងខំវាយម្នាក់ឯងក្នុងឆ្នាំ៧៣ ដើម្បីចង់បានស្អាត ។ រួចមកយើងខំវាយរំដោះភ្នំពេញមុនគេក៏ចង់បានស្អាត ។ ក្រោយរំដោះក្នុងការកសាងប្រទេសយើងក៏ចង់បានស្អាតទៀត ។ យើងនិងវៀតណាមគឺច្បាស់ហើយ សូម្បីតែកាសែតវាដែលជេរយើងក៏ថាយើងអត់រណបវៀតណាមដែរ ។ **ច្បាស់មួយទៀតគឺថៃ ។ ថៃទាក់ទងជាមួយយើងព្រោះយើងមានឋានៈឯករាជ្យ ។ ឯវាមិនឯករាជ្យទេ ។ បើឥណ្ឌូចិនមួយផ្ទាំងជាកុម្មុយនិស្តវាភ័យណាស់ ។ ដល់មានកម្ពុជាឯករាជ្យវាចង់**



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

**ទាក់ទងឲ្យបានស្រួល ។ ប៉ុន្តែពួកចង់ទាក់ទងនៅតែចង់ ឯពួកអាខូចនៅតែខូច ។**

### ក.បញ្ហាដែលយើងចង់បានឯករាជ្យ និងរក្សាឯករាជ្យៈ

ចំណុចទី១ៈគឺយើងចង់បានឯករាជ្យ ប៉ុន្តែចក្រពត្តិអាមេរិកវាចង់វាយយើង ។ ពួកខាងកើតក៏ចង់វាយយើង ។ សូវៀតនិងវៀតណាមគេឈរលើទ្រឹស្តីអន្តរឯករាជ្យ គឺទ្រឹស្តីសេរីដែលថាប្រទេសតូចឯករាជ្យម្នាក់ឯងមិនបានទេ ទាល់តែមានប្រទេសសង្គមនិយមជួយគាំទ្រផង ។ តាមទ្រឹស្តីនេះទើបសូវៀតក្តាប់អឺរ៉ុបខាងកើត ។ ហេតុដូច្នេះហើយបានជាសូវៀតចង់វាយយូហ្គោស្លាវី

ព្រោះយូហ្គោស្លាវីចង់នៅឯករាជ្យ ។ យូហ្គោស្លាវីសេរីដែរ ។ រូម៉ានីក៏ដូច្នោះ ។ ពីមុននៅក្នុងដៃសូវៀតហើយរើមកចង់ឯករាជ្យ ។ សូវៀតចង់វាយរូម៉ានី ។ បញ្ហានេះគឺច្បាស់ណាស់ ។

ចំណុចទី២ៈ បើបានឯករាជ្យគឺល្អ ។ យើងធ្វើគំរូឲ្យសកលលោក ។ តើឯករាជ្យបានឬមិនបាន?

យើងកំពុងដំណើរការ ខ្មាំងក៏កំពុងវាយយើងដែរ ។ វារុកគួនយើងទាំងខាងលិចទាំងខាងកើត ។ ប៉ុន្តែយើងខំប្រយុទ្ធជាទស្សនៈអនាគតយើងទប់ទល់បាន យើងរក្សាឯករាជ្យបាន ។

យើងពិនិត្យយុទ្ធសាស្ត្រសូវៀតនិងវៀតណាមនៅសកលលោក ពិសេសនៅអាស៊ី-អគ្នេយ៍តើយ៉ាងម៉េច?



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

នៅអឺរ៉ុបខាងកើត រូម៉ានីចង់បានឯករាជ្យ សូវៀតចង់វាយ ។ រូម៉ានីនៅជាប់នឹងសូវៀតផងនៅតែសូវៀតធ្វើអីមិនបាន ។ អាល់បានីក៏ដូច្នោះ សូវៀតនៅតែធ្វើអីមិនបាន ។ **ឯយើងនិងវៀតណាម បើប្រៀបធៀបវៀតណាមតូចជាងសូវៀតឆ្ងាយណាស់ ។ លទ្ធភាពរបស់គាត់តិចណាស់ ។ សព្វថ្ងៃវៀតណាមកំពុងជួបការលំបាកខាងផ្ទៃក្នុង គាត់លំបាកទាំងសេដ្ឋកិច្ច ទាំងនយោបាយ ទាំងយោធា ពិសេសខាងសេដ្ឋកិច្ច** ។ គាត់ត្រូវការពេលវេលាច្រើនឆ្នាំទៀតដើម្បីដោះស្រាយ ។ ដូច្នេះ បើចង់ប្រើកម្លាំងបុកអាស៊ី-អគ្នេយ៍ ទៅមិនរួចទេ ។ បើមានកម្លាំង១០០សេះអាចបុកបានតែ១០សេះទេ ។ ប៉ុន្តែគាត់ជាប់ដៃនៅលាវ គាត់ត្រូវជួយលាវអស់៣ទៀត ។ ដូច្នេះកម្លាំងបុកអាស៊ី-អគ្នេយ៍ នៅតែ៧ ។ សូវៀតនិងវៀតណាមក្តាប់ថៃ ភូមា ម៉ាឡាយូ ឥណ្ឌូនេស៊ីអត់បានទេ ។ ផ្ទុយទៅវិញបក្សភូមា បក្សថៃ បក្សម៉ាឡាយូប្រឆាំងសេរីដាច់ខាត ហើយបក្សទាំងនេះកំពុងវាយខ្លាំង ។ ទិសវិវឌ្ឍន៍ទៅមុខគឺ បដិវត្តន៍អាស៊ី-អគ្នេយ៍កាន់តែរីកចម្រើន ។

ក្នុងសភាពនេះ យុទ្ធសាស្ត្រជាមូលដ្ឋានអនុគ្រោះឲ្យយើង ។ វៀតណាមវាយយើងមិនរបើកទេ ។ យើងមាននយោបាយជាមួយវៀតណាម គឺនយោបាយទូតរួមផ្សំនឹងយោធា ។ គាត់ដើរល្បឿន១ឆ្នាំ យើងដើរល្បឿន៣ឆ្នាំនេះជាមធ្យម ។ បើយើងដើរលឿន គាត់តាមកន្ទុយយើង ។ ដូច្នោះយើងឯក-រាជ្យបាន ។ សូវៀតខ្លាំងដងម៉េចនៅតែធ្វើអីអាល់បានី យូហ្គោស្លាវី និងរូម៉ានីមិនទាន់បាន ។ **ឯវៀតណាមជានាគខ្មៅព្រួសពិស យ៉ាងណាក៏ដោយ ក៏នាគនេះជានាគល្មោន ហើយនាគនេះមានពិសតែ៧ទេ ដែលត្រូវវាយយើងផងវាយអាស៊ី-អគ្នេយ៍ផង ។**

ចំណុចទី៣ៈ យើងដំណើរការឯករាជ្យយើងទៅបាន តែការលំបាកក៏នៅតែមាន ។ បើយើងរក្សាឯករាជ្យបានយើងមានឥទ្ធិពលនៅអាស៊ី-អគ្នេយ៍ និងសកលលោកកាន់តែខ្លាំង ។ បក្សមួយចំនួននៅអាស៊ី-អគ្នេយ៍ ពិសេសបក្សថៃ គេមានជំនឿជឿជាក់លើយើង ហើយឧបត្ថម្ភគាំទ្រយើង ។ គេឃើញច្បាស់ថាយើងមិនមែនឈ្នះដោយចៃដន្យទេ ។ គេឃើញច្បាស់ថា យើងឯករាជ្យតស៊ូស្មុគស្មាញ តែឧបត្ថម្ភខ្លួនបាន ។ ឥឡូវគេឃើញកាន់តែច្បាស់ថែមទៀត ។

**(នៅមានត)**



# អណ្តូងសាកសពជនរងគ្រោះ នៅក្នុងស្រុកកំណើត របស់ ប៉ុល ពត

បន្ទាប់ពីបុណ្យចូលឆ្នាំខ្មែរ ឆ្នាំ១៩៩៧ ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅកាន់ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ដែលជាស្រុកកំណើតរបស់ប៉ុល ពត ។ នៅក្នុងស្រុកស្ទឹងសែននេះមានមណ្ឌលប្រល័យពូជសាសន៍ដ៏ធំមួយឈ្មោះថា «វត្តក្តីដូង» ដែលឈ្មោះនេះត្រូវបានហៅតាមឈ្មោះភូមិគឺភូមិក្តីដូង ។

នៅក្នុងរបបខ្មែរក្រហមពុំមានឈ្មោះស្រុកស្ទឹងសែនទេ ។ ស្រុកស្ទឹងសែន ទំនងជារបបខ្មែរក្រហមចាត់តាំងជាផ្នែកមួយនៃទីរួមខេត្តកំពង់ធំ ដែលនៅក្រោមការទាក់ទងការងារជាមួយអគ្គការរដ្ឋផ្ទាល់ ។ យោងតាមសៀវភៅភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្នែកនយោបាយ ថ្នាក់ទី២ បោះពុម្ពលើកទី១ ឆ្នាំ១៩៧៧ របស់ក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ «ទីរួមខេត្តគឺកំពង់ធំ នៅកំពង់ធំមានស្រុកចំនួនតែ៥ទេ គឺស្រុកបារាយណ៍ ស្រុកសន្ទុក ស្រុកសណ្តាន់ ស្រុកកំពង់ស្វាយ និងស្រុកស្ទោង» ។ ថ្វីត្បិតតែខេត្តកំពង់ធំ នៅក្នុងភូមិភាគឧត្តរ សៀវភៅនេះសរសេរថា «តំបន់ និងទីក្រុងដែលចាត់តាំងដោយឡែកទាក់ទងការងារដោយផ្ទាល់ជាមួយអគ្គការរដ្ឋ» ។ ទីតាំងកាប់សម្លាប់ក្តីដូងនេះនៅមិនឆ្ងាយប៉ុន្មានពីទីរួមខេត្តឡើយ ។ ឧក្រិដ្ឋកម្មនិងអំពើឃោរឃៅនៅទីនេះរបស់ពួកខ្មែរក្រហម បានកន្លងផុតទៅអស់២០ឆ្នាំទៅហើយ ក៏ប៉ុន្តែស្ថិតនៅក្នុងការចងចាំយ៉ាងច្បាស់ក្រឡែតរបស់អ្នកភូមិមួយចំនួនដែលរស់រានមានជីវិតនៅឡើយ ។ ក្រុមស្រាវជ្រាវរបស់យើងបានជួបជាមួយនឹងអ្នកភូមិពីរនាក់ដែលបានដឹងរឿងរ៉ាវទាក់ទងនឹងឧក្រិដ្ឋកម្មនៅទីនេះរឿងរ៉ាវទាំងនោះបានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែង នូវអ្វីដែលបានកើតឡើងនៅភូមិក្តីដូង ។ ក្នុងរបបខ្មែរក្រហម

លោកតា ដូ អាយុ៨៣ឆ្នាំ រស់នៅក្នុងភូមិក្តីដូងនេះបាន



សាកសពជនរងគ្រោះដែល
មិនទាន់រលួយអស់

រៀបរាប់ថា គាត់មកដល់ភូមិនេះដំបូងគេបំផុត ក្រោយរំដោះនៅក្នុងឆ្នាំ ១៩៧៩ ហើយគាត់បានឃើញនូវ អណ្តូងពោរពេញទៅដោយសាកសព ហើយមានឆ្អឹងនៅរាយប៉ាយនៅក្បែរអណ្តូងទាំងនេះ ក្លិនស្អុយយ៉ាងខ្លាំង នៅពេលនោះ ប៉ុន្តែក្រោយមកបន្តិចមានមនុស្សមកគាស់រកមាសនៅតាមអណ្តូងដែលពោរពេញទៅដោយសាកសព ។ តាជូ បញ្ជាក់ថា គាត់រកបានខ្សែនីឡុងមួយបាច់ដែលប្រើសម្រាប់ចងអ្នកទោស ហើយគាត់បានប្រើប្រាស់ខ្សែទាំងនេះសម្រាប់ចងក្របីរបស់គាត់ទៀតផង ។ក្រោយមកទៀត នៅឆ្នាំ១៩៨០-១៩៨១ គណៈកម្មាធិការស្រាវជ្រាវឧក្រិដ្ឋកម្មរបបប៉ុលពតនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានមកជីក គាស់អដ្ឋិធាតុចេញពីអណ្តូងទាំង៤នេះ ។ តាជូ បានប៉ាន់ស្មានថាជនរងគ្រោះដែលត្រូវពួកខ្មែរក្រហមសម្លាប់នៅទីនេះ ប្រហែលជាង៦០០នាក់ អដ្ឋិធាតុទាំងនោះត្រូវបានតម្កល់ទុកនៅក្នុងបូជនីយដ្ឋានមួយនៅក្នុងវត្តក្តីដូងក៏ប៉ុន្តែទំហំនៃឆ្អឹងទាំងអស់នោះត្រូវបានបាត់បង់អស់មួយចំនួនធំដោយការរើចុះរើឡើងកន្ទុះការយកចិត្តទុកដាក់ថែរក្សានិងការពុកផុយក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ។ អណ្តូងតូចមានទំហំមាត់លើ២ម៉ែត្រ ជម្រៅ៦ម៉ែត្រ ហើយអណ្តូងធំមានជម្រៅ ១១ ម៉ែត្រ ទំហំមាត់លើ ២ ម៉ែត្រ ។ លោកតា ប៉ុង អាយុ៦២ ឆ្នាំរស់នៅក្នុង ភូមិក្តីដូងនេះដែរបានប្រាប់ថា ទីកន្លែងនេះពុំមានគុកទេនៅក្នុងសម័យ ប៉ុល ពត ។ ជនរងគ្រោះច្រើនជាមន្ត្រីរបបមុនស្ត្រីមនុស្សចាស់ និងកូនក្មេង ហើយត្រូវបានដឹកដោយឡានមកពីទីប្រជុំជន និងសហករណ៍ផ្សេងៗ គាត់បានឃើញ២-៣ដង ហើយម្តងៗមានឡាន២ដឹកមនុស្សពេញ ចូលមកក្នុងភូមិនេះ គឺសំដៅទៅអណ្តូងទាំងបួនដែលប្រជាជនក្នុងភូមិហៅថា «អណ្តូងខ្មោច» ។

**កុសល**

**(តមកពីលេខមុន)** ការបើកឲ្យភ្ញៀវចូលមកទស្សនាមន្ទីរស-២១ ត្រូវបានរៀបចំឡើងមុនដំបូងបង្អស់នៅខែមីនា ឆ្នាំ១៩៧៩ ប៉ុន្តែពេញមួយឆ្នាំ បន្ទាប់ពីសារមន្ទីរទួលស្លែងលេចចេញជារូបរាងឡើង មានតែជនបរទេសប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យចូលទស្សនា ពីព្រោះមានឯកសារមួយរបស់ក្រសួងវប្បធម៌ ឃោសនាការ និងពត៌មាននៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានអះអាងថា ទីកន្លែងនេះបើកដំបូងក្នុងបំណង «បង្ហាញ... ភ្ញៀវអន្តរជាតិអំពីឧក្រិដ្ឋកម្មដ៏យង់ឃ្នងរបស់ពួកក្បត់នឹងប្រជាជនខ្មែរ» ។ នៅពេលទន្ទឹមគ្នានេះដែរ លោក ម៉ៃ ឡាំ ព្រមទាំងសហការីរបស់គាត់ បានកែប្រែបន្តិចម្តងៗ ធ្វើឲ្យកន្លែងនេះក្លាយទៅជាសារមន្ទីរមួយ ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៨០ បំរាមមិនឲ្យជនជាតិកម្ពុជាចូលមើលសារមន្ទីរទួលស្លែងត្រូវបានដកចេញ ហើយពេលនោះមានប្រជាជនកម្ពុជារាប់ម៉ឺននាក់ចូលមកទស្សនាមន្ទីរស-២១នេះ ។ ភាគច្រើននៃប្រជាជនទាំងនោះគឺព្យាយាមស្វែងរកបងប្អូន សាច់ញាតិដែលបានបាត់ខ្លួន ។ ប្រជាជនបានចូលមកទស្សនាបន្តកន្ទុយគ្នា និងផ្សៀងផ្ទាត់រូបថតពាក់កណ្តាលខ្លួនដែលដាក់តាំងនៅជាន់ក្រោម ។ ដូចដែលប្រវត្តិវិទូ ដូឌី លិចវូដ បានសរសេរថា «អ្នកដែលមកទស្សនាជាច្រើនចូលមកគឺដើម្បីស្វែងយល់អំពីអត្ថន័យ និងការពន្យល់អំពីថាតើអ្វីខ្លះបានកើតឡើងក្នុងអតីតកាលកន្លងទៅ ។ ការដើរទស្សនានៅទីនោះមិនមែនជាការងាយស្រួលឡើយ ។ អ្នកមកទស្សនាកាលពីឆ្នាំដំបូងនិយាយថា នៅពេលដើរមើលក្នុងសារមន្ទីរមានធុំក្លិនអសោចខ្លាំងណាស់» ។

ពេលដែលសារមន្ទីរបើកដំបូងមានប្រជាជនកម្ពុជាមកទស្សនាប្រហែលជា៣២០០០នាក់ នៅក្នុងសប្តាហ៍ទី១ ។ នៅខែតុលា ឆ្នាំ១៩៨០ មានជនជាតិកម្ពុជាប្រហែលជាង ៣០០០០០នាក់ និងជនបរទេស ១១០០០នាក់ បានចូលទស្សនាសារមន្ទីរទួលស្លែង ។




**សម្លេងពីមន្ទីរ ស-២១**
**ខគ្គទី១: ការរកឃើញមន្ទីរ ស-២១**
**សាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ជានិច្ចកាល ម៉ៃ ឡាំ មានបំណងប្រាថ្នាខ្ពស់ណាស់ចំពោះមន្ទីរស-២១ ។ គាត់ចង់បង្កើតជាសារមន្ទីរមួយ និងរៀបចំជាបណ្ណសារដ្ឋានមួយ ដែលជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា និងកុំឲ្យប្រជាជនកម្ពុជាទាំងអស់ភ្លេចនូវរឿងរ៉ាវទាំងអស់ដែលបានកើតឡើងក្នុងរបបប៉ុលពត ។ ពិពណ៌មួយក្នុងចំណោមពិពណ៌ដែលមានលក្ខណៈជាឆាកល្ខោនជាងគេរបស់គាត់គឺ រូបផែនទីកម្ពុជាដ៏ធំមួយ ដែលមានគម្រៀបពេញដោយលលាដ៍ឆ្អឹងក្បាលខ្មោច និងទន្លេដែលត្រូវបានគូរក្នុងលក្ខណៈជាឈាមពណ៌ក្រហម ។ នៅដើមទសវត្សរ៍ឆ្នាំ៨០ ក្រោយពេលវាលពិឃាតជើងឯកនៃមន្ទីរ ស-២១ ដែលស្ថិតនៅខាងលិចរាជធានីភ្នំពេញត្រូវបានជីកកាស់ ក្រោមការដឹកនាំរបស់គាត់ ម៉ៃ ឡាំ បានត្រួតពិនិត្យដោយផ្ទាល់នូវការកាយយកសាកសពជនរងគ្រោះរាប់ពាន់ រួចហើយគាត់ក៏បញ្ជាឲ្យសង់បូជនីយដ្ឋាន ឬស្តូបមួយដែលហ៊ុំព័ទ្ធកញ្ចក់សម្រាប់តម្កល់អដ្ឋិធាតុទាំងអស់ដែលគាស់រួចហើយ ។ ស្តូបនោះពោរពេញទៅដោយលលាដ៍ក្បាលនៃជនរងគ្រោះ ។ នៅពេលនិយាយទៅកាន់អ្នកស្រីសារ៉ាខូម ក្នុងឆ្នាំ១៩៩៥ ម៉ៃ ឡាំ បាននិយាយថាៈ «ខ្ញុំរៀនអស់រយៈពេល៧ឆ្នាំ.... ទម្រាំតែនឹងចេះកសាងសារមន្ទីរនេះឡើងគឺដើម្បីជួយឲ្យប្រជាជនកម្ពុជាដឹងអំពីសង្គ្រាម និងទិដ្ឋភាពផ្សេងៗទៀតដែលទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម ។ ចំពោះប្រជាជនសាមញ្ញដែលមិនយល់ គឺមានតែសារមន្ទីរនេះហើយដែលអាចជួយគាត់ឲ្យយល់ ។ ថ្វីត្បិតតែប្រជាជនកម្ពុជាទាំងអស់

នោះធ្លាប់បានទទួលរងគ្រោះក្រោមរបប ប៉ុល ពត ក៏ដោយ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវម្នាក់ ខ្ញុំនៅតែចង់ឲ្យប្រជាជនកម្ពុជាទាំងនោះទៅទស្សនា «សារមន្ទីរនេះ» ហើយច្បិត្យិតតែធ្វើឲ្យប្រជាជនកម្ពុជាស្រក់ទឹកភ្នែកក៏ដោយ ។ ទោះបីជាប្រជាជនកម្ពុជាធ្លាប់រងគ្រោះដោយសារសង្គ្រាម ក៏ពួកគាត់មិនយល់ពីអ្វីដែលហៅថាសង្គ្រាមដែរ ហើយប្រជាជនជំនាន់ក្រោយៗទៀតក៏មិនយល់» ។

ប្រវត្តិវិទូ លិច្ចវូដ បានបង្ហុលបង្ហាញថា សម្រាប់ប្រជាជនកម្ពុជាជាច្រើនមានបញ្ហាច្រើនទាក់ទងនឹង «កសិណបញ្ហាក់» នៃសារមន្ទីរដែលត្រូវបានរៀបចំឡើងដោយជនបរទេសដើម្បីឆ្លុះបញ្ចាំងពីភាពស្របគ្នារវាង «របបប្រល័យពូជសាសន៍» នៃកម្ពុជាប្រជាធិបតេយ្យជាមួយនឹងរបបណាហ្ស៊ីហ៊ីត្លែ នៃប្រទេសអាល្លឺម៉ង់ ។ ទន្ទឹមនឹងគ្នានេះដែរភាគច្រើននៃអ្នកដែលនៅរស់រានមានជីវិតដែលធ្លាប់ទទួលរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អាចនិយាយរៀបរាប់យ៉ាងក្បោះក្បាយ ឥតមានការលំបាកឡើយ ហើយរឿងរ៉ាវទាំងអស់អាចនឹងរៀបរាប់សង្ខេបតាមរយៈការតាំងពិពណ៌នៅទួលស្លែងនោះ ។ លទ្ធិណាហ្ស៊ីហាក់ដូចជាគ្រាន់តែជាផ្លាកឈ្មោះមួយដូចជាលទ្ធិដទៃៗទៀត ដែលប្រជាជននៅសេសសល់ពីសេចក្តីស្លាប់បានទទួលរងនិងឆ្លងកាត់ភាពភ័យរន្ធត់នានា ។ ភាពមិនអើពើរបស់មន្ត្រីកម្ពុជាប្រជាធិបតេយ្យចំពោះជនរងគ្រោះដែលត្រូវបានតាំងបង្ហាញពីបន្ទប់មួយទៅបន្ទប់មួយនោះ ពិតជារំពុកឡើងវិញនូវអនុស្សាវរីយ៍ដ៏ជូរចត់ដល់អ្នកទោសដែលរួចផុតពីសេចក្តីស្លាប់ ។ ការបកស្រាយអំពីរឿងរ៉ាវនាសម័យប៉ុល ពត ក្លាយទៅជារឿងកម្មផលដែលជាឧបសគ្គបណ្តាលឲ្យការបង្កើតប្រវត្តិសាស្ត្រមួយពុំបានល្អ ប៉ុន្តែប្រជាជនដែលនៅរស់ពិតជាចងចាំយ៉ាងច្រើនសន្ធឹកសន្ធាប់នូវអ្វីដែលបានកើតឡើង ហើយអ្វីដែលប្រជាជនគ្រប់រូបនៅចងចាំមានលក្ខណៈដូចគ្នាពីមួយទៅមួយ ។ ចំណុចនេះត្រូវបានលើកឡើងដោយអ្នកចិត្តសាស្ត្របារាំងពីររូបគឺលោក ជីនពៀរ ហីហ្គែល និងលោក កូលែត ឡង់ជ្រាក់ ដែលធ្វើការនៅជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃនាទសវត្សរ៍ឆ្នាំ៨០ ។ លោកទាំងពីរបានមានប្រសាសន៍ថាៈ «ជានិច្ចកាល អ្នកដែលមានលោកទស្សនៈជឿលើកម្មផលរស់នៅបានស្ងប់សុខស្រួលជាង ព្រោះជំនឿនេះមិនធ្វើឲ្យយើងមានចម្ងល់ច្រើន ឬយ៉ាងហោចណាស់ក៏ឲ្យយើងមានចម្លើយក្នុងដៃរួចជាស្រេច ដើម្បីនឹងឆ្លើយគឺថាមកពីកម្មរបស់យើងម្នាក់ៗទើបទទួលពៀរវេរានេះ ។ ក្នុងទស្សនៈកម្មផលដោយចាត់ទុកថាខ្មែរក្រហមជាពួកជ្រុលនិយមដ៏ឆ្គួតលីលា និងជាការចាប់កំណើតនៃព្រលឹងបិសាចដែលទទួលខុសត្រូវចំពោះអពមង្គលរបស់ជនជាតិខ្មែរធ្វើឲ្យការមើលឃើញបាតុភូតពិតប្រាកដនិងការលំបាកស្មុគស្មាញ ប៉ុន្តែគឺជាទស្សនៈមួយដែលប្រជាជនយល់ថាល្អ និងធ្វើឲ្យខ្លួនពេញចិត្ត» ។



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ដោយសារក្របខ័ណ្ឌទស្សនៈផ្អែកលើកម្មផលនេះ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានពុះពារយ៉ាងខ្លាំងដើម្បីផ្តោតអារម្មណ៍របស់ប្រជាជនទៅលើការចងកំហឹងចំពោះបនប្រល័យពូជសាសន៍ដែលកាន់អំណាចពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។ ព្រោះតែរដ្ឋាភិបាលថ្មីផ្អែកភាពស្របច្បាប់ទៅលើការពិតដែលថា ខ្លួនជាអ្នកបានផ្តួលរំលំពួកខ្មែរក្រហមនោះ រដ្ឋាភិបាលនេះមិនប្រកាន់យកនូវជំហរផ្តន្ទាទោសចលនាទាំងមូលឡើយ ព្រោះឥស្សរជនសំខាន់ៗជាច្រើននៃរបបថ្មីនោះគឺខ្លួនឯងជាខ្មែរក្រហមដែលផ្តាច់ខ្លួនរត់ទៅប្រទេសវៀតណាមនៅឆ្នាំ១៩៧៧ និង ១៩៧៨។ វត្តមានជាបន្តរបស់ពួកមេដឹកនាំខ្មែរក្រហមព្រមទាំងកូនចៅប្រដាប់ដោយអាវុធរបស់ខ្លួនដែលរត់ទៅជ្រកកោននៅតាមព្រំដែនកម្ពុជា-ថៃ បានធ្វើឲ្យវៀតណាមមានហេតុផលដើម្បីរក្សាកម្លាំងទ័ពរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយបណ្តោយឲ្យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាលាបពណ៌គូបដិបក្ខនយោបាយរបស់ខ្លួនថាជាខ្មែរក្រហម។




ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ក៏ដូចជាបុព្វការីក្នុងរបបមុនៗដែរ អ្នកនាំពាក្យរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរៀបចំប្រវត្តិសាស្ត្រតម្រូវទៅតាមសេចក្តីត្រូវការនានាសម្រាប់មួយថ្ងៃៗរបស់ខ្លួនប៉ុណ្ណោះ។ នៅក្នុងការបង្កើតចលនាកុម្មុយនិស្តកម្ពុជា ចលនានេះគឺជាចលនាបដិវត្តន៍ពិតៗដ៏បរិសុទ្ធ រហូតមកដល់ និងរួមទាំងថ្ងៃរំដោះភ្នំពេញនាឆ្នាំ១៩៧៥ផង ដែលពេលនោះចលនានេះបានឡើងមកកាន់កាប់អំណាចមួយពព្រិចភ្នែក និងខ្លាំងក្លាស្ទើរតែមិនអាចពន្យល់បាន។ ការនិយាយបង្វែរសាច់រឿងនេះបានធ្វើឲ្យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មានហេតុផលប្រារព្ធពិធីរំឭក «ជ័យជម្នះលទ្ធិសង្គមនិយម» នៅថ្ងៃ១៧ មេសា ១៩៧៥ ហើយទន្ទឹមនឹងនោះធ្វើការថ្កោលទោសពួកខ្មែរក្រហមដែលជាអ្នកវាយយកជ័យជម្នះនេះផង។ វិធីសាស្ត្រក្នុងការធ្វើប្រវត្តិសាស្ត្ររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានសង្កត់ធ្ងន់ដែរទៅលើមិត្តភាពដ៏យូរអង្វែងរវាងចលនាតស៊ូកម្ពុជា-វៀតណាម និងរបបកម្ពុជានិងវៀតណាម ដែលពីមុនមកចំណងមិត្តភាពនេះពិបាកនឹង

ធ្វើបាននៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ ។

អត្ថបទអំណានដែលជាប់ទាក់ទងជាច្រើនអំពីអតីតកាល បានបង្ហាញពីភក្តីភាពចំពោះបក្ស ។ ហើយម្យ៉ាងវិញទៀតមានតែចលនាបដិវត្តន៍សុទ្ធសាធមួយប៉ុណ្ណោះដែលធ្វើឲ្យសហរដ្ឋអាមេរិកបរាជ័យ ហើយពេលដែលកង់ប្រវត្តិសាស្ត្រវិលប្រែក្រឡាស់ពុំមានចលនាបដិវត្តន៍ដែលមានលក្ខណៈឃោរឃៅមកលើប្រជាជនសាមញ្ញ ឬក៏ប្រឆាំងនឹងជនបដិវត្តន៍វៀតណាមទៀតឡើយ ។ ការពន្យល់អំពីហេតុការណ៍ដែលកើតឡើងទាំងអស់នេះ គឺមានប្រយោជន៍តិចតួចណាស់សម្រាប់ជនជាតិកម្ពុជាដែលមិនមែនជាជនបដិវត្តន៍ ។ ជនជាតិកម្ពុជាយល់ថាជាការងាយស្រួលជាងក្នុងការផ្តោតទៅលើការចងចាំរបស់ខ្លួនក្រោមរបប «អាពត» ។ ឧក្រិដ្ឋកម្មដ៏ចម្លែកនិងមិនអាចលើកទោសឲ្យបានរបស់ «អាពត» ពុំមែនដោយសារ ប៉ុល ពត បានតាំងខ្លួនជាជនកុម្មុយនិស្ត ឬ «ហ្វាស៊ីស» នោះទេ ប៉ុន្តែអ្វីដែលសំខាន់គឺ ប៉ុល ពត ជាអ្នកដែលទទួលខុសត្រូវចំពោះការបន្តការសម្លាប់ជនជាតិខ្លួនឯង ។ ប្រសិនបើវៀតណាមចង់ហៅ ប៉ុល ពត ថាជាជនហ្វាស៊ីស នោះប្រជាជនកម្ពុជានឹងអាចហៅតាមទាំងមិនសូវដឹងថា តើអត្ថន័យនេះស៊ីជម្រៅដល់កម្រិតណាឡើយ ។ ទាក់ទងនឹងបញ្ហានេះនៅក្នុងកិច្ចសម្ភាសន៍ជាមួយ លីអូនែល វៀរុង កាលពីឆ្នាំ១៩៩៥ អ្នកដែលនៅរស់រានមានជីវិតពីគុកទួលស្លែងម្នាក់ ឈ្មោះ ផា ថាចាន់ ដែលកាលពីជំនាន់ ប៉ុល ពត ជាឧត្តមសេនីយ៍នៃកងទ័ពកម្ពុជាបាននិយាយថាៈ «បាទ! អ្វីដែលបានកើតឡើងកាលពីជំនាន់ ប៉ុល ពត នោះ គឺការអនុវត្តន៍ «លទ្ធិកុម្មុយនិស្ត» ប៉ុន្តែវាជាប្រភេទ «ពួកហ្វាស៊ីស» ហើយខ្លាំងលើសហ្វាស៊ីសទៅទៀត ។ ជនហ្វាស៊ីសអាឡឺម៉ង់មិនដែលសម្លាប់ជនជាតិឯងទេ គេសម្លាប់ជនជាតិដទៃដូចជាបារាំង ប៉ូឡូញ ។ល។ ចំណែក ប៉ុល ពត វិញ វាសម្លាប់ជនជាតិឯងអស់បីលាននាក់ ។ ពួកហ្វាស៊ីសមិនធ្វើដូច្នេះឡើយ» ។

រៀងរាល់ឆ្នាំនៅក្នុង «ទិវាចងកំហឹង» រដ្ឋាភិបាលបានប្រមូលផ្តុំមហាជន ហើយរំឭកឡើងវិញនូវការចងចាំរបស់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងឱកាសទាំងនោះបាតុកម្មប្រឆាំងនឹង ប៉ុល ពត ត្រូវបានចាត់ចែងឡើងដោយមានការចូលរួមពីសំណាក់សិស្សសាលា និងមន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងនោះមានការថ្លែងសុន្ទរកថាថ្កោលទោសរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោក វ៉ាន់ ណាត ព្រមទាំងអ្នកដទៃទៀតដែលរួចផុតពីសេចក្តីស្លាប់នៅគុកទួលស្លែងក៏ត្រូវបានកោះហៅឲ្យមកនិយាយរ៉ាយរាប់អំពីរឿងរ៉ាវដែលគាត់ជួបប្រទះនៅក្នុងអតីតមន្ទីរស-២១ «គុកទួលស្លែង» ។

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ៨០ អ្នកដែលចូលមកមើលបណ្ណាសារដ្ឋានដែលស្ថិតនៅជាន់ទីពីរ នៅអាគារខាងលិចនៃគុកទួលស្លែង មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះឯកសារយ៉ាងច្រើនដែលបានប្រមូលផ្តុំនៅទីនោះ ។ ភាគច្រើននៃឯកសារទាំងនោះមានកម្រាស់ជាង១ហ្វូដ (ជាង ៣០សង់ទីម៉ែត្រ) ។ ឯកសាររាប់រយជាអត្ថបទវាយអង្គុយលីលេខ និងខ្លះជាឯកសារស្ទួន ។ ទូដែលមានកញ្ចក់ពីមុខនៅក្នុងបណ្ណាសារដ្ឋាននោះ ពេញទៅដោយសៀវភៅកំណត់ហេតុរបស់កម្មាភិបាលដែលមានសរសេរអំពីកំណត់ហេតុប្រជុំវគ្គសិក្សាយោធា និងវគ្គសិក្សាវិជ្ជាពេទ្យ ។ សេចក្តីសង្ខេបនៃចម្លើយសារភាពដែលគាបរួច ស្ថិតនៅគរជាគំនរ ខ្លះមានរហូតដល់រាប់រយសន្លឹក ។ អ្នកសារព័ត៌មានព្រមទាំងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ត្រូវបានទាក់ទាញចិត្តឲ្យថតចម្លងនូវអត្ថបទចម្លើយសារភាព និងអត្ថបទផ្សេងៗទៀត ។ នៅទសវត្សរ៍ឆ្នាំ៨០ សកម្មជនសិទ្ធិមនុស្សមួយរូបឈ្មោះ ដេវីដ ហក បានប្រមែប្រមូលនូវជម្រើសអត្ថបទជាច្រើននៅគុកទួលស្លែង ដែលផ្តល់នូវភ័ស្តុតាងបានយ៉ាងក្រាស់ក្រែលអំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការខិតខំព្យាយាមរបស់លោក ដេវីដ ហក និងអ្នកដទៃផ្សេងទៀតក្នុងការនាំយកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមកកាត់ទោសនៅពេលនោះ និងពេលក្រោយមកត្រូវបានបង្អាក់ដោយសារការសម្របសម្រួលរបស់ប្រទេសថៃ និងការពិចារណាផ្នែកនយោបាយដទៃទៀត ។ គំនិតផ្តួចផ្តើមនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសមានសន្ទុះម្តងទៀតនៅទសវត្សរ៍ឆ្នាំ៩០ គឺពេលដែលចលនាខ្មែរក្រហមចុះខ្សោយ ។

ក្រោយឆ្នាំ១៩៨៩ ពេលដែលវៀតណាមដកទ័ពចេញពីប្រទេសកម្ពុជា វាសនានៃបណ្ណាសារដ្ឋាន រួមទាំងសារមន្ទីរទាំងមូលផង មើលទៅដូចជាគ្មានភាពប្រាកដប្រជាឡើយ ។ នៅ


ពិធីបង្សុកូលចំពោះអដ្ឋិធាតុជនរងគ្រោះនៅវត្តល្វើន ឃុំដូនស ស្រុកស្វាយរៀង

ឆ្នាំ១៩៩១ សាកលវិទ្យាល័យ ខនែល នៅសហរដ្ឋអាមេរិក ដែលត្រូវបានកត់សម្គាល់ថាមានភាពសម្បូរបែបខាងផ្នែកឯកសារទាក់ទងប្រទេសអាស៊ី-អគ្នេយ៍ នៅបណ្ណាល័យរបស់ខ្លួននោះ បានស្នើសុំធ្វើកាតាឡុក និងថតចម្លងជាហ្វីល (ថតមីក្រូហ្វីល) នូវបណ្ណសារដ្ឋានក្នុងគុកទួលស្លែង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងវប្បធម៌កម្ពុជា ។ កិច្ចការទាំងនេះត្រូវបានបញ្ចប់ក្នុងរយៈពេលពីរឆ្នាំ ។ ឯកសារចម្លងជាមីក្រូហ្វីលមួយច្បាប់ត្រូវបានតម្កល់ទុកនៅសាកលវិទ្យាល័យខនែល ហើយមួយច្បាប់ទៀតត្រូវបានតម្កល់ទុកនៅឯសារមន្ទីរទួលស្លែង ។

ឯកសារថតចម្លងហើយមាន២១០ថាស «ហ្វីល» រួមទាំងហ្វីលដែលថតម្តងទៀតចំនួន១១ថាស ។ នៅក្នុងដុំឯកសារទាំងអស់នោះ គឺមានចម្លើយសារភាពទាំងអស់ដែលរកឃើញនៅទីងកន្លែងរួមទាំងឯកសារចម្លើយសារភាពរបស់អ្នកទោសជនបរទេសទៀតផង ។ ប៉ុន្តែ ឯកសារនេះត្រូវបានថតចូលហ្វីលដោយឡែក ។ ឯកសារជនបរទេសទាំងនោះមានមិនត្រឹមតែចម្លើយសារភាពជារបស់អ្នកទោសឈ្លើយសឹកវៀតណាមទេ តែមានទាំងចម្លើយរបស់អ្នកនេសាទត្រី ជនជាតិវៀតណាម ថៃ ព្រមទាំងជនស៊ីវិលវៀតណាមដទៃទៀត ។ ក្រៅពីនេះមានចម្លើយសារភាពមួយចំនួនតូចរបស់អ្នកនាវាចរ ជនជាតិអាមេរិកាំង អង់គ្លេស និងអូស្ត្រាលីដែលត្រូវបានចាប់ខ្លួននៅពេលដែលខ្លួនចូលមកជិតឆ្នេរសមុទ្រកម្ពុជា ។

ក្នុងចំណោមចម្លើយសារភាពដែលមានពត៌មានបញ្ជាក់យ៉ាងច្បាស់នោះរួមមានចម្លើយសារភាពរបស់អតីតបុគ្គលិកធ្វើការនៅគុកទួលស្លែង៧៩នាក់ ។ មាន២៨នាក់ជាអ្នកសួរចម្លើយ និង១២នាក់ទៀតជាអ្នកធ្វើឯកសារ ។ ហើយអ្នកក្រៅពីនោះគឺជាឆ្មាំ ។ ឯកសារទាំងអស់នោះផ្តល់ជាទិន្នន័យប្រវត្តិរូបអំពីបុគ្គលិកក្មេងៗធ្វើការនៅគុកទួលស្លែង ។ ទិន្នន័យទាំងនោះក៏រៀបរាប់ពីលក្ខខណ្ឌធ្វើការងារព្រមទាំងការធ្វើទារុណកម្មរបស់ពួកខ្លួនផងដែរ ។

**(នៅមានត)**



# គ្រោះថ្នាក់នៃអព្យាក្រឹតភាព
## ការបែកបាក់ទំនាក់ទំនងរវាងកម្ពុជា និងសហរដ្ឋអាមេរិក ឆ្នាំ១៩៦៥

វ៉ៃយនគុន ក្លែមម័រ

**(តពីលេខមុន)** *ក្នុងពេលបង្ហាញខ្លួនដើម្បីបញ្ឈប់ការធ្វើវិភាគរបស់អាមេរិក ទ្រង់សីហនុ បានប្រកាស២ថ្ងៃក្រោយបាតុកម្មនៅស្ថានទូតអាមេរិកនៅទីក្រុងភ្នំពេញថា ប្រតិភូកម្ពុជាមួយក្រុមនឹងត្រូវបញ្ជូនទៅកាន់ក្រុងហាណូយដើម្បីចរចាអំពីកិច្ចព្រមព្រៀងមិនឈ្លានពានទឹកដីទៅវិញទៅមក និងកិច្ចព្រមព្រៀងលើបញ្ហាព្រំដែន ។ ទ្រង់ សីហនុ មានព្រះរាជតម្រិះថា ប្រសិនបើការចរចាទាំងនោះទទួលបានជោគជ័យ ព្រះអង្គនឹងទទួលស្គាល់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។ ក៏ប៉ុន្តែការពិភាក្សាទាំងឡាយនៅក្រុងហាណូយទទួលផលអាក្រក់ ។ ទ្រង់ សិហនុ បានចោទវៀតណាមខាងជើងថាធ្វើដូចជាប្រទេសថៃអ៊ីចឹងដែរ ហើយគ្រោះថ្នាក់នៃការកាត់ផ្តាច់បំណងទំនាក់ទំនងទាំងស្រុងជាមួយសហរដ្ឋអាមេរិកក៏ចុះថយមកវិញ ។ នៅក្នុងខណៈនោះ ទ្រង់*

សីហនុ បានសម្រេចចិត្តធ្វើមិនអើពើចំពោះសេចក្តីប្រកាសនានា កាលពីមុនដែលគំរាមកំហែងថានឹងផ្តាច់ទំនាក់ទំនងកម្ពុជាជាមួយ អាមេរិក ។ ក្រឡាអុកផ្សេងៗទៀតរបស់ទ្រង់សីហនុបានទទួល បរាជ័យ ហើយទ្រង់ពេលនោះបានត្រៀមខ្លួនសម្ងំចាំមើល សភាពការណ៍វិញម្តង ។ វិបត្តិនេះក៏បានថយចុះភ្លាមៗនោះដែរ ។

ឥឡូវនេះមន្ត្រីក្រសួងការបរទេសអាមេរិកមួយចំនួន បានគិតថា វាជាការឈ្លាសវៃដែលពួកខ្លួនត្រូវសម្តែងឥរិយាបថ រាក់ទាក់ជាមួយកម្ពុជា ។ រដ្ឋមន្ត្រីការបរទេសគឺលោក រ៉ាស់ បានរៀបចំធ្វើលិខិតមិត្តភាពមួយទៅឲ្យរដ្ឋមន្ត្រីក្រសួងការ បរទេសកម្ពុជា ហើយថែមទាំងបានលើកឡើងអំពីលទ្ធភាពក្នុង ការអញ្ជើញទ្រង់ សីហនុ ដើម្បីយាងទៅបំពេញទស្សនកិច្ច នៅសហរដ្ឋអាមេរិក មុននឹងធ្វើដំណើរឆ្ពោះទៅប្រទេសបារាំង ។ ក៏ប៉ុន្តែដោយសារការជំទាស់នៅក្នុងរដ្ឋាភិបាលអាមេរិក សំបុត្ររបស់ រ៉ាស់ ត្រូវទុកកប់ចោលពុំដែលមានឱកាសបានផ្ញើចេញ ហើយជាលទ្ធផលទ្រង់ សីហនុ ពុំដែលត្រូវបានអញ្ជើញឲ្យ ទៅទស្សនកិច្ចនៅក្រុងវ៉ាស៊ីនតោនទេ ។

នៅត្រង់ចំណុចនេះពុំមានភាពប្រាកដថាតើសហរដ្ឋ អាមេរិកត្រូវមានឥរិយាបថបែបណានាពេលឆាប់ៗបន្ទាប់នោះ ដែលនឹងអាចស្រោចស្រង់ទំនាក់ទំនងនានារវាងកម្ពុជានិងសហរដ្ឋ អាមេរិកឲ្យមានភាពប្រសើរឡើងក្នុងស្ថានភាពនៃការសង្ស័យគ្នា ទាំងសងខាងបែបនេះ ។ ការវាយតម្លៃរបស់អាមេរិកថា ទង្វើ ទាំងឡាយរបស់ទ្រង់ សីហនុ ចេញមកពីការសិក្សាតុល្យភាព របស់ទ្រង់លើកម្លាំងនៅអាស៊ី និងវៀតណាម ត្រូវបានជ្រួតជ្រាប ក្នុងគំនិតរបស់មន្ត្រីអាមេរិកាំង ជាបន្ថែមទ្រង់ សីហនុ ធ្វើសកម្មភាព ឆ្លើយតបទៅនឹងនយោបាយផ្ទៃក្នុង ។ ទោះជាយ៉ាងណាក៏ដោយ មានឱកាសតិចតួចណាស់ដែលអាចធ្វើការដើម្បីសម្រាលមូលហេតុ ធំៗនានាដែលបង្កឲ្យមានភាពតានតឹងនេះ ។ ក្នុងខែឧសភា ឆ្នាំ ១៩៦៤ ទ្រង់ សីហនុ បានចោទប្រកាន់សហរដ្ឋអាមេរិកថា បានធ្វើវិទ្ធង្សនាបំផ្លាញគ្រឿងចក្រធ្វើផ្លូវដែលកម្ពុជាបានទិញ ដើម្បីជួសជុលមហាវិថីមិត្តភាពកម្ពុជា-អាមេរិក ហើយការ ស្រាវជ្រាវរុករកផ្នែកវិទ្យាសាស្ត្ររបស់សហរដ្ឋអាមេរិកដែល ស្វែងរកសត្វគោព្រៃ បានសម្លាប់សត្វព្រៃ និងបំផ្លិចបំផ្លាញព្រៃ នៅកម្ពុជា ។ ធ្ងន់ធ្ងរជាងនេះទៀត ការរំលោភបំពានលើព្រំដែន ពីរលើកទៀតបានកើតឡើងនៅភូមិតើយ និងភូមិធ្លក ។ សហរដ្ឋ អាមេរិកដដែលជាដដែល ចាត់ទុកឧប្បត្តិហេតុតាមព្រំដែន ទាំងនោះថាជាព្រឹត្តិការណ៍ដ៏គួរឲ្យសោកស្តាយ ក៏ប៉ុន្តែបានទម្លាក់ ការទទួលខុសត្រូវលើរណសិរ្សរំដោះជាតិរបស់វៀតណាមដោយ បានប្រើប្រាស់តំបន់ព្រំដែនជាជម្រកលាក់ខ្លួន ។

ដូចគ្នាដែរ ទ្រង់ សីហនុ បន្តបដិសេធដូចមុនៗដែលថា ពួកវៀតកុងពុំបានប្រតិបត្តិការធ្វើសកម្មភាពនៅតាមមូលដ្ឋាន កម្ពុជាទេ ។ ទ្រង់សីហនុ បានចាត់ទុកឧប្បត្តិហេតុនៅភូមិតើយនិង ភូមិធ្លក ជា «សកម្មភាពសង្គ្រាម» ហើយបានធ្វើការប្តឹងផ្តល់ជា ផ្លូវការមួយប្រឆាំងនឹងសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង ទៅកាន់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។ ក្រោយ មកនៅក្នុងរដូវក្តៅ (អំឡុងខែកក្កដា) ទ្រង់សីហនុបានធ្វើការចោទ ប្រកាន់សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង និងពួកខុទ្ទាម ខ្មែរសេរីថា បានបាចជាតិគីមីពុលមកលើតំបន់មួយចំនួនក្នុង ខេត្តរតនគិរី និងស្វាយរៀង អ្នកភូមិជាងមួយរយនាក់បានស្លាប់ ។

នៅចុងខែសីហា និងដើមខែកញ្ញា ឧបទ្ទវហេតុតាម ព្រំដែនដ៏សំខាន់មួយទៀតបានកើតឡើងដែលក្នុងឧបទ្ទវហេតុទាំង នោះយន្តហោះចម្បាំងរបស់វៀតណាមខាងត្បូងបានធ្វើការវាយ ប្រហារមកលើភូមិកោះនគរនិងទូកកម្ពុជានៅតាមដងទន្លេមេគង្គ ទ័ពជើងគោកក៏បានធ្វើការវាយប្រហារដែរ ។ ការវាយលុកទាំង នេះគួបផ្សំនឹងរបាយការណ៍ដែលទើបទទួលបានថ្មីៗអំពីការវាយ ប្រហារដោយជាតិពុលគីមី និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋ អាមេរិកលើកដំបូងមកលើវៀតណាមខាងជើងជាការតបតទៅនឹង ព្រឹត្តិការណ៍នៅឈូងសមុទ្រតុងកឹង បានធ្វើឲ្យទ្រង់សីហនុ មានការ ក្រេវក្រោធយ៉ាងខ្លាំង ។ ទ្រង់បានបដិសេធមិនព្រមទទួលឯកអគ្គរាជ ទូតអាមេរិកថ្មី រ៉ែនដហ្វ គីដដ័រ ។ រដ្ឋមន្ត្រីការបរទេស រ៉ាស់ បានបញ្ជាឲ្យឯកអគ្គរដ្ឋទូតគីដដ័ររបស់ខ្លួន ចាកចេញពីក្រុង ភ្នំពេញជាបន្ទាន់ ។ ឯកអគ្គរាជទូតថ្មី គីដដ័រ ពុំដែលត្រឡប់មក ភ្នំពេញវិញទេ ហើយការវាយលុកនៅតាមព្រំដែនចេះតែបន្ត ។

ដោយទំនាក់ទំនងដាំក្បាលចុះយ៉ាងលឿនជាថ្មីម្តងទៀត ឈានទៅរកវិបត្តិមួយ សហរដ្ឋអាមេរិកបានស្នើជូនយោបល់ឲ្យ មានការពិភាក្សារួមគ្នារវាងអាមេរិកនិងកម្ពុជានៅក្រុងញូវដែលី (ប្រទេសឥណ្ឌា) ហើយប្រជាជនកម្ពុជាបានទទួលយកយោបល់

នេះ «ភ្លាមៗគួរឲ្យភ្ញាក់ផ្អើល» ។ ការជួបគ្នានេះគឺជាកិច្ចខិតខំប្រឹងប្រែងក្នុងលក្ខណៈកែលម្អមួយ ដែលត្រូវធ្វើឡើងដើម្បីប្រឈមមុខដោះស្រាយនឹងបញ្ហានានានៅក្នុងអំឡុងពេលនោះ ។ ការពិភាក្សាទាំងនេះបានចាប់ផ្តើមនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៦៤ ហើយបានបញ្ចប់ក្នុងរយៈពេល១០ថ្ងៃ ក្រោយដោយពុំបានសម្រេចកិច្ចព្រមព្រៀងគ្នាណាមួយឡើយ ។ សហរដ្ឋអាមេរិកបានបន្ទោសលើភាពរឹងរូសរបស់ទ្រង់សីហនុ ។ ទ្រង់សីហនុមានបន្ទូលថា សហរដ្ឋអាមេរិកបានឯកភាពចំពោះការចរចានានាគ្រាន់តែដើម្បីកែលម្អជំហរទាក់ទងជាសាធារណៈរបស់ខ្លួនប៉ុណ្ណោះ ។ ទ្រង់មានបន្ទូលថា «យើងពុំមានមូលហេតុអ្វីទៀតដើម្បីនឹងចំណាយពេលវេលា និងថវិកាឥតប្រយោជន៍ក្នុងការបន្តលេងល្បែងកំប្លុកកំប្លែងនេះជាមួយមន្ត្រីអាមេរិកទៀតទេ» ។ មន្ត្រីអាមេរិកមានការភ័យខ្លាចថា ការបរាជ័យក្នុងការជួបពិភាក្សាទាំងនេះអាចនឹងបណ្តាលឲ្យមានការធ្វើបាតុកម្មហិង្សានានាមកលើស្ថានទូតអាមេរិក ឬប្រហែលជាអាចបណ្តាលឲ្យមានការបែកបាក់ផ្នែកការទូតមួយ ។ ទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាមានសភាពចុះខ្សោយយ៉ាងខ្លាំងរហូតដល់កម្រិតថា តំណាងមកពីគណៈកម្មការគ្រប់គ្រងអន្តរជាតិដែលជាជនជាតិប៉ូឡូញ រងរបួសយ៉ាងធ្ងន់ធ្ងរនៅក្នុងគ្រោះថ្នាក់រថយន្តនៅជិតព្រលានយន្តហោះក្រុងភ្នំពេញ ប្រជាជនតាមមូលដ្ឋានដំបូងបដិសេធពុំព្រមជួយគាត់ដោយគិតថា មន្ត្រីជាតិប៉ូឡូញនេះគឺជាជនជាតិអាមេរិកាំង ។ នៅចុងឆ្នាំ វត្តមានសហរដ្ឋអាមេរិកនៅក្នុងប្រទេសកម្ពុជាមានចំនួនតែ១២នាក់ប៉ុណ្ណោះ ធ្លាក់ចុះពី៣០០នាក់ក្នុងឆ្នាំកន្លងទៅ ។

ដោយទំនាក់ទំនងមិនទៀងទាត់បែបនេះ ដេម ថមសុន ដែលជាទីប្រឹក្សាសន្តិសុខជាតិមួយរូបបានទទូចក្នុងនាមគាត់ផ្ទាល់ទៅប្រធានាធិបតីអាមេរិកឲ្យកៀបសង្កត់វៀតណាមខាងត្បូងឲ្យចាត់វិធានការដើម្បីធ្វើឲ្យរំសាយភាពតានតឹងទាំងនេះជាមួយកម្ពុជា ។ ថមសុន បានសរសេរថា «តម្រូវការដ៏បន្ទាន់មួយដើម្បីដាក់ការប្រុងប្រយ័ត្នពិសេសជាមុននានា ដើម្បីជៀសវាងឧបទ្ទវហេតុបន្ថែមទៀតមកលើព្រំដែនខាងកម្ពុជា» ។

លោក ថមសុន បានព្រមានថា ឧបទ្ទវហេតុច្រើនជាងនេះទៀតកើតឡើង ទ្រង់សីហនុ អាចនឹងកាត់ផ្តាច់ទំនាក់ទំនងទាំងស្រុងតែម្តង ។

ដំបូន្មានរបស់លោក ថមសុន ពុំទទួលបានផ្លែផ្កាអ្វីឡើយ ។ លោក ថមសុន និង ឆែលស្ទ័រ គូបព័រ បញ្ជាក់ទៅកាន់លោក ចចប៊ុនឌី កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ១៩៦៤ ថា «យើងហាក់ដូចជាធាល់ច្រក ដោយខ្វះការយល់ដឹងអំពីការទុកចិត្តទូទៅនៃការគិតរបស់លោកប្រធានាធិបតី» ហើយ «ប្រហែលជាលោកអាចជួយបាន» ។ ពុំមានភស្តុតាងថា ប៊ុនឌី បានឆ្លើយតបនោះទេ នេះប្រហែលជាដោយសារទីប្រឹក្សាសន្តិសុខជាតិអាមេរិកមាននិន្នាការមិនចង់ផ្តល់យោបល់ឲ្យចាត់វិធានការនានាដើម្បីធ្វើឲ្យទំនាក់ទំនងកាន់តែប្រសើរឡើង ។ នៅថ្ងៃទី៦ ខែមករា លោក ប៊ុនឌី បានផ្ញើជូនលោកប្រធានាធិបតីនូវព្រះរាជសារមួយច្បាប់ដែលទ្រង់សីហនុ បានសរសេរទៅកាន់កាសែតឈ្មោះអ៊ីនធ័រនេសិនណលហ៊ីរល ទ្រីប៊ូន ជាភាសាអង់គ្លេស International Herald Tribune ដែលក្នុងកាសែតនោះទ្រង់បានចោទប្រកាន់មន្ត្រីអាមេរិកថាបានចូលប្រឡូកក្នុង «ការគំរាមកំហែង សកម្មភាពអមិត្ត ការឈ្លានពាន វិទ្ធង្សនា វិច្ឆេទកម្ម ការដាក់ផែនការ និងការប៉ុនប៉ងធ្វើរដ្ឋប្រហារឲ្យមានការបង្កើតតំបន់ឯករាជ្យ» ។ លិខិតនេះបានចង្អុលបង្ហាញអំពី «បញ្ហានៃការពាក់ព័ន្ធជាមួយទ្រង់សីហនុ» នេះបើតាមលោក ប៊ុនឌី ប្រាប់ទៅលោក ចនសុន ។ នៅប៉ុន្មានខែដំបូង ក្នុងឆ្នាំ១៩៦៥ ទាំងសហរដ្ឋអាមេរិកនិងប្រទេសកម្ពុជាពុំបានចាត់វិធានការសំខាន់ៗណាមួយដើម្បីធ្វើឲ្យទំនាក់ទំនងរវាងសហរដ្ឋអាមេរិក និងកម្ពុជាមានភាពប្រសើរឡើងនោះទេ ។ ទ្រង់សីហនុ បានបន្តការរិះគន់ចំពោះសហរដ្ឋអាមេរិកជារឿយៗដោយប្រើពាក្យខឹងសម្បាជាច្រើនលើក ដូចជាថា ឲ្យជំនួយមានចំណង រិះគន់ជំហរមិនចូលបក្សសម្ព័ន្ធរបស់ទ្រង់អនុញ្ញាតឲ្យអ្នកកាសែតអាមេរិកបោះពុម្ពសាច់រឿងបន្ទះបន្ទាប់អំពីទ្រង់និងកម្ពុជា និងការទម្លាក់គ្រាប់បែកមកលើវៀតណាមខាងជើងជាដើម ។ នៅក្នុងខែកុម្ភៈ ទ្រង់សីហនុបានប្រាប់អ្នកកាសែតជនជាតិឥណ្ឌាម្នាក់ថា សហរដ្ឋអាមេរិក «សព្វថ្ងៃត្រូវបានគេស្អប់ជាងបារាំងនៅក្នុងដំណាក់កាលនៃសង្គ្រាមអាណានិគមដ៏អាក្រក់បំផុត» ។

ការវាយលុកឆ្លងកាត់ព្រំដែនមកលើប្រទេសកម្ពុជាបានបន្តជាប្រភពដ៏ចម្បងមួយនៃការបញ្ឆេះភ្លើងកំហឹង ។ នៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៦៥ បន្ទាប់ពីការកើនឡើងនូវការឈ្លានពាន

ចូលជាច្រើនលើកពីវៀតណាមខាងត្បូងមក ទ្រង់សីហនុ បានមានព្រះរាជបន្ទូលថា ទ្រង់នឹងប្រកាសសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង ប្រសិនបើការទម្លាក់គ្រាប់បែកបន្ថែមទៀតមកលើភូមិលំនៅដ្ឋាននៃប្រទេសកម្ពុជាចេះតែបន្តកើតឡើងបែបនេះ ហើយទ្រង់បានគំរាមកំហែងថា នឹងអំពាវនាវសុំការគាំទ្រពីប្រទេសចិន ។ ទោះបីជាយ៉ាងណាក៏ដោយ មួយសប្តាហ៍ក្រោយមកមានឧបទ្ទវហេតុតូចៗប្រមាណ១៣ ហើយឧទ្ធម្ភាគចក្ររបស់សហរដ្ឋអាមេរិកមួយគ្រឿងបានចុះចតមួយរយៈខ្លីលើទឹកដីកម្ពុជា ។

នៅក្រុងភ្នំពេញ មន្ត្រីអាមេរិក ប៉ែចេសិន បានទាញហេតុផលថា ការវាយលុកទាំងនោះក៏ដូចជាបន្តសកម្មភាពខ្មែរសេរី គឺមានលទ្ធផលអវិជ្ជមានត្រឡប់មកវិញ ។ ទោះបីជាទ្រង់សីហនុមានអាកប្បកិរិយាឆាប់ប្រែក្រឡាស់ ហើយនឹងមានការគ្រេវគ្រោធប្រឆាំងនឹងអាមេរិកក៏ដោយ ក៏ ប៉ែចេសិន បានជឿថា ទ្រង់គឺជា «មេដឹកនាំខ្មែរដ៏មានប្រសិទ្ធិភាពបំផុត ដែលមិនអាចមានមន្ទិលសង្ស័យបាន» ហើយជឿទៀតថា ប្រទេសកម្ពុជាបានរុងរឿងថ្កុំថ្កើងក្រោមការដឹកនាំរបស់ទ្រង់ ។ ហេតុដូច្នេះសហរដ្ឋអាមេរិកគួរតែព្យាយាម «រក្សាមនុស្សព្រៃនៅក្រុងបាងកកនិងសៃហ្គន មិនឲ្យប្រព្រឹត្តជ្រុលហួសពីការគ្រប់គ្រងបានរបស់ខ្លួន ហើយនិងអ្វីដែលហៅថាការប៉ុនប៉ង «រំដោះ» ប្រទេសកម្ពុជា ។ យើងពុំជឿថា នៅក្នុងអនាគតដ៏វែងឆ្ងាយផលប្រយោជន៍ដ៏សំខាន់បំផុតនៃលោកសេរីនឹងត្រូវបានមកដោយការផ្តួលរំលំទ្រង់ពីតំណែងនោះទេ» ។

យោបល់ទាំងនេះ ពុំត្រូវបានយកចិត្តទុកដាក់ឡើយ ។ ទោះបីជាមានការព្រមានដ៏ទទូចកាន់តែច្រើនឡើងៗពីទ្រង់សីហនុក៏ដោយ ជារៀងរាល់សប្តាហ៍ឃើញមានការវាយលុកកាន់តែច្រើនមកលើភូមិលំនៅដ្ឋានរបស់ប្រជាជនកម្ពុជា ។

**(នៅមានត)**

## អំពីមីនរបស់ខ្មាំង
## មីនអឹម១៨ អា១ M18A1
## ហៅមីន ក្លេម៉រ៍

**(ដកស្រង់ចេញពីសៀវភៅកំណត់ហេតុរបស់សមមិត្តម៉ៅ សាម៉ន)**

### I. អត្ថប្រយោជន៍ និងប្រសិទ្ធិភាព

មីនអឹម១៨ អា១ <M18 A1> ធ្វើឡើងដោយប្រទេសចក្រពត្តិប្រើប្រាស់សម្រាប់កំទេចកងទ័ពថ្មើរជើង ដែលដើរលើដីនិងជិះឡាន នាវា រថក្រោះ ។

ក. ចម្ងាយផ្ទុះទៅមុខឆ្ងាយបំផុតបាន២០០ម៉ែត្រ
ចម្ងាយបំផ្លាញមានប្រសិទ្ធិភាពល្អពី៥០ម៉ែត្រចុះមក
ពេលផ្ទុះទៅមុខចម្ងាយ១៥ម៉ែត្រ មានកម្ពស់១ម៉ែត្រ ៤៧
ពេលផ្ទុះទៅមុខចម្ងាយ៣០ម៉ែត្រមានកម្ពស់១ម៉ែត្រ ៨០
ពេលផ្ទុះទៅមុខចម្ងាយ៤៨ម៉ែត្រមានកម្ពស់១ម៉ែត្រ ២៤៣

ខ. បណ្តោយមីនប្រវែង២០សង្ទីម៉ែត្រ៤០ <២០ស.ម៤០>
ទទឹងមីនប្រវែង៣សង្ទីម៉ែត្រ៤ <៣ស.ម៤>
កម្ពស់មីនប្រវែង១០សង្ទីម៉ែត្រ៥ <១០ស.ម៥>
មីនទម្ងន់ <១គ.ក្រ ៣៦០>

### II. ចំណែកពិសេសនៃមីន

មីនអឹម១៨ អា១ ចែកចេញជាៈ

១.សំបកមីន
២.ម៉ែត្រដំរុង
៣.រន្ធញាត់ឈ្នួន
៤.ជើង
៥.រំសេវសេ៤ <C4>
៦.គ្រាប់មីនចំនួន៧២២គ្រាប់ មូលដូចគ្រាប់កង់ ។ ទំហំ៥មីលីម៉ែត្រ <៥ម.ម>

**របៀបដាក់**

-កន្ទ្រែកជើងមីនទាំង៤ ហើយដោតជាប់ទៅនឹងដីឲ្យរឹង មុខមីនរាងកោងទៅរកខ្មាំង ។

-ញាត់ឈ្នួនចូល ហើយបន្ធាយខ្សែមកក្រោយដោតខ្សែឲ្យជាប់ទៅនឹងម៉ាស៊ីនច្របាច់ ។

**របៀបដោះ**

-បើយើងឃើញខ្មាំងដាក់ យើងមូលយកឈ្នួនផ្ទុះចេញមីនធានាប៉ះរងលែងផ្ទុះ ។ -មួយទៀតយើងហែកខ្សែចេញពីគ្នាហើយកាត់មួងមួយៗ ។

# គំរូមួយនៃភស្តុតាងឯកសារដែលធ្លាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់នៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

***(តពីលេខមុន)*** *នៅក្នុងកិច្ចសន្ទនាមួយកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ ១៩៩៩ ជាថ្មីម្តងទៀត អៀង សារី បានទទូចអះអាងថាគាត់ ពុំបានដឹងថា កម្មាភិបាលដែលត្រូវបានចាប់ខ្លួនកំពុងត្រូវបាន ប្រហារជីវិតជាប្រចាំ ហើយថាគាត់ពុំមានអំណាចអ្វីដើម្បីបញ្ឈប់ឲ្យ មានការចាប់ចង់ណាមួយនោះទេ។ អៀង សារី បានអះអាងថា*



*យោធាខ្មែរក្រហម*

*តួនាទីតែមួយគត់របស់គាត់នៅក្នុងបញ្ហាបែបនេះ គឺគាត់ធ្លាប់ បានទាញហេតុផលតវ៉ាយ៉ាងខ្លាំងប្រឆាំងនឹងការចាប់ខ្លួនប្រធាន នាយកដ្ឋានទាំងឡាយនៅក្រសួងការបរទេសដែលមន្ទីរស-២១ ចង់ចាប់ចេញទៅ ប៉ុន្តែគាត់សន្និដ្ឋានថា កម្មាភិបាលនោះត្រូវបាន នាំយកទៅ «អប់រំកែប្រែ» ប៉ុណ្ណោះ មិនមែនយកទៅសម្លាប់ នោះទេ។ មិនតែប៉ុណ្ណោះ អៀង សារី បានប្រៀបធៀបកន្ទុះ ការដឹងឮរបស់ ខៀវ សំផន ដែលជាផ្លូវការមានតួនាទីជាប្រធាន គណៈរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យកាលពីខែមេសា ឆ្នាំ ១៩៧៦ ទៅនឹងភាពកន្ទុះការដឹងឮរបស់គាត់ផ្ទាល់។ អៀង សារី បានបញ្ជាក់អំពីការឡើងឋានៈរបស់ ខៀវ សំផន ទៅក្នុងគណៈ កម្មាធិការមជ្ឈិមកាលពីខែមករា ឆ្នាំ១៩៧៦ និងការតែងតាំង ខៀវ សំផន កាលពីដើមឆ្នាំ១៩៧៧ ជាប្រធាន «មន្ទីរ៨៧០» ជាមន្ទីររដ្ឋបាលនៃគណៈកម្មាធិការមជ្ឈិម ដែលជាមុខងារដែល ត្រូវបានកំណត់ជាផ្លូវការសម្រាប់គណៈកម្មាធិការនេះគឺ «ដើម្បី តាមដានការអនុវត្តន៍» សេចក្តីសម្រេចលើបញ្ហានយោបាយនានា*

របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ។ អៀង សារី បានបញ្ជាក់ថា នៅក្រោមសមត្ថកិច្ចរបស់មន្ទីរ៨៧០ ខៀវ សំផន បានឃើញឯកសារដែលមានលក្ខណៈទូទៅច្រើនជាងគាត់ ក៏ប៉ុន្តែមិនមែនចាំតែឯកសារដែលទាក់ទងនឹងការប្រហារជីវិត និងទារុណកម្មនោះទេ ។ អៀង សារី បានទទួចថា ខៀវ សំផន ក៏ដូចជាគាត់ដែរចេះតែបន្តជឿថា កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាដែលត្រូវបានចាប់ខ្លួន គឺកំពុងតែត្រូវបាន «អប់រំកែប្រែ» មិនមែនយកទៅសម្លាប់ទេ ។ អៀង សារី បាននិយាយម្តងទៀតថា ការសម្រេចចិត្តចាប់ខ្លួន និងប្រហារជីវិតត្រូវបានធ្វើឡើងដោយ ប៉ុល ពត, នួន ជា និង សុន សេន ដោយម្តងនេះបន្ថែមថា ស-២១ក៏បានពាក់ព័ន្ធទៅនឹងការសម្រេចចិត្តបែបនេះដែរ ។

នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកកាសែត នេត ថេយ័រ កាលពីពាក់កណ្តាលខែតុលា ឆ្នាំ១៩៩៧ ប៉ុល ពត បានទទួលស្គាល់តួនាទីមួយក្នុងការមើលខុសត្រូវលើដំណើរការនានានៅ ស-២១ ហើយបានសារភាពថា បានសម្រេចចិត្តពីការសម្លាប់យ៉ាងហោចណាស់ប្រជាជនមួយចំនួនដែល «បានសារភាព» នៅទីនោះ ។ ហេតុដូច្នេះ ប៉ុល ពត ពុំបានបដិសេធទៅនឹងការអះអាងថា «ភាគច្រើននៃសមាជិកនៃគណៈកម្មាធិការមជ្ឈិមត្រូវបានសម្លាប់នៅក្នុងគុកទួលស្លែង» ទេ ។ ប៉ុល ពត ក៏ពុំបាននិយាយប្រឆាំងទៅនឹងសម្តីរបស់គាត់ថា បណ្ណាសារដ្ឋានមន្ទីរ ស-២១ មានឯកសារដែលបញ្ជាក់ថា «មនុស្ស១៦,០០០ នាក់ស្លាប់» នៅទីនោះ «ហើយអ្នកទាំងអស់បានសារភាពថា ពួកខ្លួនគឺជាភ្នាក់ងារសេ.អ៊ី.អា ភ្នាក់ងារយួន ក្នុងចំណោមនោះមានស្រី មានប្រុស ក្មេង និងចាស់» ។ នៅពេលដែលសួរថា «អ្នកទាំងអស់ពិតជាត្រូវសម្លាប់ ដូច្នេះហើយអ្នកឯងមានការទទួលខុសត្រូវចំពោះរឿងនេះដែរឬទេ?» ប៉ុល ពត បានឆ្លើយថា «ខ្ញុំធ្វើតែកិច្ចការខាងលើតែប៉ុណ្ណោះ» ហើយដូច្នេះខ្ញុំធ្វើការសម្រេចចិត្ត...អំពីកិច្ចការណាដែលសំខាន់ខ្លាំង ។ ទោះបីជាយ៉ាងណាក៏ដោយ ប៉ុល ពត បានអះអាងថា «ខ្ញុំពុំបានដឹងអំពីកិច្ចការថ្នាក់ក្រោមនោះទេ» ។

ទាក់ទងទៅនឹងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងសមាជិករដ្ឋាភិបាលដែលត្រូវបានប្រហារជីវិត ប៉ុល ពត បានប្រកាសថា «អ្នកទាំងនោះបានចូលបក្ស និងថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែសមាជិកទាំងនោះពុំមែនជាមនុស្សរបបកម្ពុជាប្រជាធិបតេយ្យ»ទេ ។ ប៉ុល ពត និយាយសំដៅទៅការដែលគាត់បានទទួលឯកសារអំពី «ការរៀបចំគម្រោងដោយសមាជិកទាំងអស់នេះ» នៅក្នុងឆ្នាំ១៩៧៦-៧៧ «ក្នុងការបង្កើតគណៈកម្មាធិការមួយ ដើម្បីធ្វើរដ្ឋប្រហារមួយប្រឆាំងនឹងមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យនោះមានន័យថា ដើម្បីសម្លាប់ខ្ញុំ» ។ ប៉ុល ពត និយាយថា «ខ្ញុំមិនចាំឈ្មោះទាំងអស់ទេ» ក៏ប៉ុន្តែ ប៉ុល ពត បានរំឭកអំពីឈ្មោះ យ៉ា ដែលជាលេខាភូមិភាគពាយ័ព្យ ដែលត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ ហើយ យ៉ា ជាអ្នកដែល ប៉ុល ពត ចាត់ទុកជា «មនុស្សរបស់យួន» ។

តាម៉ុក នៅក្នុងបទសម្ភាសន៍ដាច់ដោយឡែកមួយ កាលពីខែតុលា ឆ្នាំ១៩៧៧ ជាមួយ នេត ថេយ័រ បាននិយាយថា «បុគ្គលដ៏សំខាន់នៅក្នុងប្រទេសកម្ពុជាគឺ ប៉ុល ពត» ហើយទទួចទៀតថា «លេខាគណៈកម្មាធិការអចិន្ត្រៃយ៍ គឺទទួលខុសត្រូវដោយផ្ទាល់ លើមន្ទីរស-២១ ព្រមគ្នាជាមួយ ឌុច» ។ តាម៉ុក បានអះអាងថា គាត់ខ្លួនឯងបាន «ទទួលខុសត្រូវចំពោះជនបទ» ដែលនិយាយយោងជាភ័ស្តុតាងទៅសមាជបក្សខែវិច្ឆិកា ឆ្នាំ១៩៧៨ ដែលបានផ្តល់ភារកិច្ចបែបនេះដល់ តាម៉ុក រីឯ «ប៉ុល ពត ដែល...ទទួលខុសត្រូវ» ចំពោះមន្ទីរស-២១ «គឺជាបុគ្គលទី១» នៅក្នុងកម្ពុជា ។ ហេតុដូច្នេះ ទោះបីជាអ្នកបន្តបន្ទាប់ដទៃទៀតនៅក្នុងឋានានុក្រមគណៈកម្មាធិការអចិន្ត្រៃយ៍អស់រយៈពេលពាក់កណ្តាលឆ្នាំ៧៨ គឺ «នួន ជា ... បុគ្គលទី២, អៀង សារី បុគ្គលទី៣, សោ ភឹម បុគ្គលទី៤» ហើយនិង តាម៉ុក ខ្លួនឯង «បុគ្គលទី៥» ។

ភារកិច្ចទាំងអស់ក្នុងប្រទេសកម្ពុជា គឺជាភារកិច្ចរបស់បុគ្គលទី១ ។ សូម្បីតែ នួន ជា ពុំសូវបានដឹងអ្វីដង ។ ហើយជាងនេះទៅទៀត សុន សេន ដឹងកាន់តែតិចជាង នួន ជាទៅទៀត ហើយប្រពន្ធ សុន សេន គឺ យុន យ៉ាត កាន់តែអត់ដឹងអ្វីទាល់តែសោះ ។

នៅពេលសួរថា ប៉ុល ពត មានអំណាចគ្រប់គ្រងបែបណា

មកលើគណៈកម្មាធិការអចិន្ត្រៃយ៍ តាម៉ុក បានអះអាងថាៈ មានកិច្ចប្រជុំជាច្រើន មិនមែនថាពុំមានសោះនោះទេ ។ គណៈកម្មាធិការអចិន្ត្រៃយ៍បើកការប្រជុំ ហើយមានវត្តមាននៃការសិក្សារួមជាច្រើនទៀត ។ មានប្រជាធិបតេយ្យយើងពិតជាបានពិគ្រោះនិងពិភាក្សាកិច្ចការជាមួយគ្នា ។ ក៏ប៉ុន្តែនោះគ្រាន់តែជាប្រជាធិបតេយ្យមួយដែលត្រូវបានកំណត់មុនរួចជាស្រេច ។ ប៉ុល ពត បានសម្រេចអ្វីៗដោយខ្លួនឯងរួចហើយ រួចទើបអានអ្វីដែលគាត់បានសម្រេចនោះទៅឲ្យអ្នកដែលបានចូលរួមប្រជុំ ។ មូលហេតុនេះហើយដែលខ្ញុំនិយាយថា ប៉ុល ពត ពុំមានប្រជាធិបតេយ្យអ្វីទេ ។

ចំពោះគោលនយោបាយប្រហារជីវិត តាម៉ុក ប្រកាសថាៈ

*តើមានដែល ប៉ុល ពត ពិគ្រោះយោបល់អំពីបញ្ហាសម្លាប់មនុស្សដែរទេ? តើ ប៉ុល ពត ដែលមានសួរនរណាផ្សេងទេ? គឺ ប៉ុល ពត និងប្រធានគុក....តែ២នាក់គ្នាគេនោះឯង ។ នៅពេលដែលនរណាម្នាក់ត្រូវបានចាប់ខ្លួន ប្រធានគុកយកអ្នកនោះទៅសួរចម្លើយ បន្ទាប់មកយកអ្វីៗរាយការណ៍ទៅ ប៉ុល ពត ហើយ ប៉ុល ពត បានធ្វើការសម្រេចចិត្តនេះ ។ នៅក្នុងគណៈកម្មាធិការ (អចិន្ត្រៃយ៍) គ្មាននរណាយល់បានថាមានរឿងអ្វីខ្លះកើតឡើងនោះទេ ។ គណៈកម្មាធិការនេះពុំបានជ្រៀតជ្រែកក្នុងបញ្ហាសន្តិសុខទេ ។*

ទោះបីជាតាម៉ុក អះអាងថាគាត់ «ពុំច្បាស់ថាមនុស្សចំនួនប៉ុន្មានប្រាកដ» ដែលត្រូវសម្លាប់នៅមន្ទីរស-២១ក៏ដោយ ក៏គាត់បានអះអាងយ៉ាងទទូចថា បញ្ហានេះគឺជា «កិច្ចការរបស់ប៉ុលពត» ។

ជាទីបញ្ចប់នៅខែតុលា ឆ្នាំ១៩៩៧ នួន ជា បានសរសេររឿងរ៉ាវអំពីខ្លួនគាត់ ហើយពុំបានបញ្ជាក់ច្បាស់អំពីមេដឹកនាំជាន់ខ្ពស់ដទៃទៀតឡើយ ។

*យើងពុំបានដឹងអ្វីទាំងអស់អំពីការសម្លាប់រង្គាលក្នុងរបបនេះឡើយ ។ នេះជាកិច្ចការនៅថ្នាក់ក្រោម ដែលធ្វើឡើងដោយគ្មានការទទួលខុសត្រូវ ដូចជាថា បងប្អូនប្រុសស្រីសាច់ថ្លៃនិងបងប្អូនប្រុសស្រីបង្កើតរបស់ខ្ញុំក្មេងៗជាច្រើនទៀតក៏ត្រូវបានកម្ទេចអស់ដែរ ។ ថ្នាក់ក្រោមៗជាអ្នកអនុវត្តន៍ការកម្ទេចនេះ ហើយយើងពុំបានចុះរហូតទៅដល់កម្រិតក្រោមនោះឡើយ ។*

និយាយអំពីលេខាភូមិភាគបស្ចិម ជូ ជេត ហៅ ស៊ី និង កុយ ធួន ហៅ ធុច ហៅ ឃួន អតីតលេខាភូមិភាគឧត្តរចាស់ដែលបានស្លាប់ទៅ ក៏ដូចជាអំពីតំបន់របស់ តាម៉ុក នួន ជា បានចោទថា «ក្រុមអា ស៊ី និងធុច ធ្វើសកម្មភាពដោយគ្មានការទទួលខុសត្រូវ ហើយមិនមែនតិចទេស្លាប់នៅភូមិភាគនិរតី» ។ ហេតុដូច្នេះ ប៉ុល ពត បានគាំទ្រការអះអាងបញ្ជាក់របស់ អៀង សារី ថា លេខាបក្សបានកាន់អំណាចផ្តាច់មុខនៅក្នុងបញ្ហាសន្តិសុខ ហើយជាប្រយោលគាំទ្រការចង្អុលបង្ហាញរបស់ អៀង សារី ថាថ្នាក់ក្រោម ប៉ុល ពត ដូចជា នួន ជា ក៏មានការពាក់ព័ន្ធដែរ ។ ផ្ទុយទៅវិញ នួន ជា បានព្យាយាមទម្លាក់កំហុសចំពោះការសម្លាប់រង្គាលទាំងអស់ ដោយកងកម្លាំងសន្តិសុខទៅលើលេខាភូមិភាគទាំងអស់ ហើយនិងថ្នាក់ក្រោមៗដទៃទៀត រីឯតាម៉ុក បានព្យាយាមទម្លាក់ការទទួលខុសត្រូវទាំងអស់ទៅលើ ប៉ុល ពត តែម្នាក់ឯង ។ ការអះអាងរបស់ អៀង សារី ថាគាត់នៅខាងក្រៅរង្វង់សន្តិសុខទាំងស្រុងពុំត្រូវបានឆ្លើយប្រឆាំងដោយមេដឹកនាំខ្មែរក្រហមដទៃទៀតឡើយ ក៏ប៉ុន្តែការអះអាងដែលទំនងជាគាំទ្រចំពោះការអះអាងរបស់ អៀង សារី ប្រហែលជាស្តែងឲ្យឃើញថាចេញមកពីលទ្ធផលនៃការខំប្រឹងប្រែងរបស់ នួន ជា និង តាម៉ុក ដើម្បីបន្ទោសអ្វីៗទាំងអស់ទៅលើថ្នាក់ក្រោមនិងថ្នាក់លើរៀងៗខ្លួន ។

**(នៅមានតទៅជំពូក២) ស្ទីវ ហេឌ័រ**

## ពន្យល់ពាក្យ

**អចិន្ត្រៃយ៍ៈ** ប្រចាំការជាប់ ។

**គណៈកម្មការៈ** សមាជិកមួយក្រុមដែលចាត់តាំងឡើងដោយការជ្រើសរើស ដើម្បីបំពេញភារកិច្ចតាមផ្នែកនីមួយៗ ។

**គណៈកម្មាធិការៈ** សមាជិកមួយក្រុមដែលចាត់តាំងឡើងដោយការជ្រើសរើស ឬការបោះឆ្នោតដើម្បីទទួលខុសត្រូវ និងសម្រេចកិច្ចការផ្សេងៗតាមកន្លែងនីមួយៗ ។

(ដកស្រង់ចេញពីសៀវភៅភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យផ្នែកនយោបាយ ថ្នាក់ទី២ បោះពុម្ពលើកទី១ ឆ្នាំ១៩៧៧ ដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ)

# ដំណើរការច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយរបបខ្មែរក្រហម

ថូម៉ាស់ ហាម៉ាបឺក

តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

**ចំនុច៣០ -** បញ្ហានៃការកាត់ទោសឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហមដែលត្រូវបានប្រព្រឹត្តឡើងក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ត្រូវបានលើកយកមកពិភាក្សានៅក្នុងសម័យប្រជុំទី៥០ នៃគណៈកម្មការសិទ្ធមនុស្សនៅទីក្រុងហ្សឺណែវ ។



យោធាខ្មែរក្រហមក្នុងសមរភូមិ

នៅក្នុងសេចក្តីសម្រេចលេខ១៩៩៩/៧៦ ស្តីអំពីសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា គណៈកម្មការសិទ្ធិមនុស្សបានធ្វើការកត់ត្រាទាំងក្តីសរសើរ នូវរបាយការណ៍របស់ក្រុមអ្នកជំនាញការដែលតែងតាំងដោយលោកអគ្គលេខាអង្គការសហប្រជាជាតិ ក្នុងការឆ្លើយតបទៅនឹងសំណូមពររបស់អាជ្ញាធរប្រទេសកម្ពុជាដែលសុំជំនួយក្នុងការដោះស្រាយនូវការរំលោភបំពានទៅលើច្បាប់នៅក្នុងប្រទេសរបស់ខ្លួន ព្រមទាំងច្បាប់អន្តរជាតិដែលរំលោភបំពានដោយរបបខ្មែរក្រហម ហើយបានអំពាវនាវយ៉ាងទទូចឲ្យរដ្ឋាភិបាលកម្ពុជាចាត់វាល់វិធានការចាំបាច់ទាំងឡាយដើម្បីធានាឲ្យប្រាកដថា បុគ្គលដែលទទួលខុសត្រូវច្រើនជាងគេចំពោះការរំលោភសិទ្ធិមនុស្សត្រូវតែបាននាំយកមកវិនិច្ឆ័យទោសតាមគំរូស្តង់ដាយុត្តិធម៌អន្តរជាតិ និងគោរពតាមនីតិវិធីត្រឹមត្រូវ ។ គណៈកម្មការសិទ្ធិមនុស្សក៏បានជំរុញឲ្យរដ្ឋាភិបាលកម្ពុជា ព្រមទាំងសហគមន៍អន្តរជាតិបន្តធ្វើសហប្រតិបត្តិការជាមួយគ្នាក្នុងការងារនេះ ។

**ចំនុច៣១ -** សម្តេច ហ៊ុន សែន សម្តេចបានសរសេរលិខិតមួយច្បាប់ផ្ញើជូនលោកអគ្គលេខាអង្គការសហប្រជាជាតិ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ដោយមានការពន្យល់ថា ទោះបីជាការជំនុំជម្រះក្តីចំពោះ តាម៉ុក និងបុគ្គលដែលអាចពាក់ព័ន្ធដទៃៗទៀតប្រព្រឹត្តទៅដោយតុលាការដែលមានក្នុងស្រុកស្រាប់ក៏ដោយ ក៏ចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិអាចត្រូវបានអញ្ជើញឲ្យចូលរួមយ៉ាងពេញលេញដើម្បីធានាឲ្យប្រាកដថាការជំនុំជម្រះក្តីនេះពិតជាមានលក្ខណៈអន្តរជាតិ ។ ពង្រាងច្បាប់នឹងត្រូវបានដាក់ឲ្យរដ្ឋសភាជាតិកម្ពុជាធ្វើការអនុម័តដើម្បីឲ្យមានចៅក្រមនិងព្រះរាជអាជ្ញាបរទេសចូលរួមក្នុងដំណើរការកាត់ក្តី ។

**ចំនុច៣២ -** នៅក្នុងកិច្ចជំនួបជាមួយតំណាងពិសេសរបស់លោកអគ្គលេខាអង្គការសហប្រជាជាតិកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីបានពិភាក្សាអំពីលទ្ធភាពនៃការបង្កើតតុលាការចម្រុះមួយ ហើយក្នុងពេលនោះដែរសម្តេចនាយករដ្ឋមន្ត្រីបានលើកយកមកពិភាក្សានូវបញ្ហានៃយន្តការក្នុងការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិ ។ សម្តេចនាយករដ្ឋមន្ត្រីបានសួរថា តើលោកអគ្គលេខាអាចធ្វើការតែងតាំងសមាសភាពទាំងនោះដែរឬទេ ។ ក្នុងការឆ្លើយតបវិញ លោកតំណាងពិសេសបានសង្កត់ធ្ងន់ថា ការចូលរួមរបស់អង្គការសហប្រជាជាតិក្នុងកិច្ចការនេះ គឺអាស្រ័យទៅលើបញ្ហា

ថាតើមានការធានាពេញលេញដើម្បីឲ្យដំណើរការជំនុំជម្រះនេះប្រព្រឹត្តដោយមានការគោរពទៅតាមស្តង់ដារយុត្តិធម៌អន្តរជាតិដែរឬទេ ។ ការធ្វើច្បាប់តម្រូវតាមស្តង់ដារអន្តរជាតិដែលនឹងត្រូវបានពង្រាង និងអនុម័តនោះ នឹងត្រូវតែឆ្លើយតបចំពោះការព្រួយបារម្ភដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានសរសេរក្នុងសំបុត្រមួយច្បាប់ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ទៅមហាសន្និបាតអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ។

**ចំនុច៣៣–** លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការបានមានប្រសាសន៍នៅក្នុងកិច្ចប្រជុំជាមួយសម្តេចនាយករដ្ឋមន្ត្រីថា របាយការណ៍របស់ក្រុមអ្នកជំនាញការច្បាប់ពិតជាផ្តល់នូវមាគ៌ាបំភ្លឺមួយយ៉ាងសំខាន់ចំពោះលក្ខណៈសម្បត្តិដែលចាំបាច់ក្នុងការបង្កើត «ច្បាប់រៀបចំអង្គការ» (ច្បាប់មួយដែលអនុម័តដោយរដ្ឋសភា ព្រឹទ្ធសភា និងឆ្លងក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យធម្មនុញ្ញភាព) និងទិដ្ឋភាពផ្សេងៗនៃនីតិវិធី ។ កម្រិតស្តង់ដារអន្តរជាតិផ្សេងៗដែលមានទំនាក់ទំនងគ្នាត្រូវតែបានបញ្ចូលក្នុងច្បាប់នេះ ហើយភាពដែលអាចអនុវត្តទៅបាននៃនីតិបញ្ញត្តិដែលមាននាពេលនេះគួរតែត្រូវបានបញ្ជាក់ឲ្យច្បាស់លាស់ ។ ទាក់ទងនឹងបញ្ហានីតិវិធីនេះមានចំណុចជាច្រើន គួរតែមានការបញ្ជាក់ឲ្យបានច្បាស់ដូចជាជំហានក្នុងការធានាឲ្យប្រាកដថា ការប្រព្រឹត្តទៅនៃអង្គតុលាការ ពិតជាគ្មានស្ថិតនៅក្រោមការកៀបសង្កត់ ការរៀបចំចាប់ខ្លួនជនជាប់ចោទមកឡើងតុលាការពិតជាធ្វើឡើងបានយ៉ាងហ្មត់ចត់ការវាយតម្លៃភស្តុតាង ដំណើរការប្តឹងឧទ្ធរណ៍ យន្តការនៃការតែងតាំងអង្គចៅក្រមមានលក្ខណៈសមស្របអាចទទួលយកបាន ព្រះរាជអាជ្ញា និង បុគ្គលិកអាជីព ព្រមទាំងបញ្ហាផ្សេងៗដែលទាក់ទងនឹងការបង្កើតនូវអង្គតុលាការមួយនិងការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុចំពោះអង្គការនេះ ។

**ចំនុច៣៤–** សម្តេចនាយកមន្ត្រីបានមានប្រសាសន៍ថា ជាការសមរម្យណាស់ដែលអ្នកជំនាញការគួរតែជួយប្រទេសកម្ពុជាក្នុងការធ្វើពង្រាងច្បាប់ដើម្បីធានាឲ្យច្បាស់ថា ច្បាប់ដែលចេញមកហ្នឹងត្រឹមត្រូវតាមតម្រូវការចាំបាច់ផ្សេងៗដែលស្របទៅតាមស្តង់ដារអន្តរជាតិ ។ លោកតំណាងពិសេសបាននាំនាំប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីទៅជំរាបជូនលោកអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ និងស្នើឲ្យមានការផ្តល់នូវជំនាញការបែបនេះ ។ លោកតំណាងបានបញ្ជាក់ទៀតថា ការចូលរួមរបស់អង្គការសហប្រជាជាតិជាបន្ត ក្រោយពីដំណាក់កាលធ្វើពង្រាងច្បាប់នឹងផ្អែកទៅលើបញ្ហាថា តើមានការព្រមព្រៀងគ្នាឬទេអំពីការបញ្ចូលទៅក្នុងច្បាប់នោះនូវការធានាថា កម្រិតស្តង់ដារអន្តរជាតិសមរម្យមួយនឹងត្រូវបានគោរព ។

**ចំនុច៣៥–** លោកតំណាងពិសេសបានធ្វើសេចក្តីរាយការណ៍ស្តីអំពីការវិវឌ្ឍន៍ទាំងនេះក្នុងកិច្ចប្រជុំនៅឯអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិចន្លោះថ្ងៃទី២៤ ខែឧសភា និងថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៩ ។ ការិយាល័យកិច្ចការច្បាប់នៃអង្គការសហប្រជាជាតិបានធ្វើការវិភាគអំពីតម្រូវការផ្លូវច្បាប់ផ្សេងៗ ដែលទាក់ទងនឹងការបង្កើតតុលាការចម្រុះមួយ ។ សមាជិករបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ត្រូវបានជូនដំណឹងនៅចុងខែកក្កដា អំពីការពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជាលើបញ្ហាអង្គជំនុំជម្រះក្តីមួយ ។ បេសកកម្មដឹកនាំដោយជំនួយការអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់បានមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៩ ។

**ចំនុច៣៦–** រដ្ឋាភិបាលកម្ពុជាបានតែងតាំងក្រុមការងារមួយដែលមានឯកឧត្តម សុខ អាន រដ្ឋមន្ត្រីជាន់ខ្ពស់ឲ្យជួបជំនុំជាមួយគណៈប្រតិភូអង្គការសហប្រជាជាតិនេះ ។ លទ្ធភាពនានាអំពីការបង្កើតអង្គជំនុំជម្រះក្តីមួយ នៅក្នុងប្រទេសកម្ពុជាដែលមានការចូលរួមពីសំណាក់អន្តរជាតិត្រូវបានលើកយកមកពិភាក្សា ។ មុនពេលចាកចេញពីប្រទេសកម្ពុជា គណៈប្រតិភូរបស់អង្គការសហប្រជាជាតិបានប្រគល់ជូនរដ្ឋាភិបាលកម្ពុជាដើម្បីពិចារណានូវពង្រាងច្បាប់មួយស្តីអំពីការបង្កើតអង្គជំនុំជម្រះនោះ ។ នៅខែកញ្ញា ឆ្នាំ១៩៩៩ នៅទីក្រុងញូវយ៉កមានការពិភាក្សាបន្ថែមទៀតរវាងលោកអគ្គលេខាអង្គការសហប្រជាជាតិនិងសម្តេចនាយករដ្ឋមន្ត្រី ក៏ដូចជារវាងជំនួយការអគ្គលេខាធិការនិងឯកឧត្តម សុខ អាន រដ្ឋមន្ត្រីជាន់ខ្ពស់កម្ពុជា ។

**ចំនុច៣៧–** បញ្ហានេះក៏ត្រូវបានលើកយកមកពិភាក្សា

ក្នុងកិច្ចប្រជុំរវាងសម្តេចនាយករដ្ឋមន្ត្រី និងលោក ថូម៉ាស់ ហាម៉ាបឺក តំណាងពិសេសរបស់អគ្គលេខាអង្គការសហប្រជាជាតិ នាថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៩ ។ សម្តេចនាយករដ្ឋមន្ត្រីបាន ធ្វើការពន្យល់ថា រដ្ឋាភិបាលកម្ពុជាមានបំណងពិគ្រោះជាមួយអ្នកជំនាញការផ្នែកច្បាប់មកពីប្រទេសនានាដទៃទៀត រួមទាំងប្រទេស បារាំង រុស្ស៊ី និងឥណ្ឌា ហើយក្រោយមកមុនដំណាច់ខែវិច្ឆិកា នឹងដាក់ជូននូវពង្រៀងច្បាប់ដែលដែលរួមបញ្ចូលនូវសំណើរបស់ គណៈប្រតិភូផ្នែកច្បាប់អង្គការសហប្រជាជាតិ ។ សម្តេចនាយក រដ្ឋមន្ត្រីបានស្នើឲ្យមានការឆ្លើយតបយ៉ាងឆាប់ពីសំណាក់អគ្គ លេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិដើម្បីដាក់ជូនសភា ជាតិធ្វើការអនុម័តមុនដំណាច់ឆ្នាំ១៩៩៩ ។

**ចំនុច៣៨–** សម្តេចនាយករដ្ឋមន្ត្រីបានសម្តែងនូវការ ព្រួយបារម្ភចំពោះអធិបតេយ្យភាពជាតិ និងយល់ថាសំណើ របស់សហគមន៍អន្តរជាតិក្នុងការតែងតាំងចៅក្រមលើសលប់ថា



គណៈប្រតិភូអន្តរជាតិរបស់តុលាការប្រជាជនបដិវត្តន៍កម្ពុជាទស្សនកិច្ចសារមន្ទីរទួលស្លែង ឆ្នាំ១៩៧៩

ជាការរំលោភទៅលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏សម្តេចនាយករដ្ឋមន្ត្រីបាន សម្តែងការយល់ព្រមទៅនឹងយោបល់ឲ្យរៀបចំលក្ខខណ្ឌ «មតិ ភាគច្រើនលើសលប់មួយ» ដែលមានន័យថា ទោះបីជាភាគ ច្រើននៃចៅក្រមអាចជាជនជាតិកម្ពុជា ប៉ុន្តែសម្លេងភាគច្រើន លើសលប់មួយក៏នឹងចាំបាច់ផងដែរ មុននឹងមានការចេញសាល ក្រមណាមួយហើយ ដំណើរការរបៀបនេះនឹងបញ្ជាក់ថា មតិ ភាគច្រើននឹងត្រូវបានគោរព ។

**ចំនុច៣៩–** ដូចជាលើកមុនៗដែរ តំណាងពិសេសរបស់ លោកអគ្គលេខាអង្គការសហប្រជាជាតិ ថូម៉ាស់ ហាម៉ាបឺក បានបញ្ជាក់យ៉ាងច្បាស់ថា អង្គការសហប្រជាជាតិនឹងមិនចូលរួម ក្នុងដំណើរជំនុំជម្រះក្តីពួកខ្មែរក្រហមនេះទេ បើសិនជាលោក អគ្គលេខាមិនត្រូវបានធ្វើឲ្យមានជំនឿទុកចិត្តថា ដំណើរការកាត់ ក្តីនឹងត្រូវធ្វើឡើងតាមស្តង់ដាយុត្តិធម៌អន្តរជាតិ និងតាមនីតិវិធី ត្រឹមត្រូវនោះទេ ។ ត្រូវមានការធានាឲ្យប្រាកដថា នឹងគ្មានការ ជ្រៀតជ្រែកផ្នែកនយោបាយ ហើយដំណើរការជំនុំជម្រះចាប់ពី ដើមដល់ ចប់នឹងមានលក្ខណៈឯករាជ្យ ។

**ចំនុច៤០–** នៅទន្ទឹមពេលកំពុងតែសរសេររបាយ- ការណ៍នេះ «ពាក់កណ្តាលខែធ្នូឆ្នាំ១៩៩៩» សំណើចុងក្រោយ របស់រដ្ឋាភិបាលកម្ពុជា មិនទាន់ត្រូវបានដាក់ ជូនសភាជាតិនៅឡើយ ទេ ។ នៅក្នុងសេចក្តី សម្រេចចិត្តរបស់ខ្លួន លេខ៥៤-១៧១ មហាសន្និបាតអង្គការ សហប្រជាជាតិបាន ស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ អគ្គលេខាធិការដ្ឋាន អង្គការសហប្រជាជាតិ និងសកម្មជនសហគមន៍ អន្តរជាតិក្នុងការជ្រោមជ្រែងដល់រដ្ឋាភិបាលកម្ពុជា ក្នុងបញ្ហា តុលាការព្រមទាំងបានជម្រុញឲ្យរដ្ឋាភិបាលកម្ពុជាបន្តធ្វើកិច្ច សហប្រតិបត្តិការថែមទៀតជាមួយអង្គការសហប្រជាជាតិក្នុង គោលគំនិតឈានទៅរកកិច្ច ព្រមព្រៀងសមស្របមួយ ។

**(បកប្រែក្រៅផ្លូវការៈ ស្វ ប៊ុនស៊ូ)**




# ហេតុអ្វីត្រូវតែមានការចូលរួមពីអង្គការសហប្រជាជាតិ ក្នុងអង្គជំនុំជម្រះក្តីខ្មែរក្រហម?

មនុស្សមួយចំនួនបានទាញហេតុផលថា មានបញ្ហាសំខាន់ៗជាច្រើនសម្រាប់អនាគតប្រទេសកម្ពុជាដែលត្រូវខ្វល់ខ្វាយជាជាងបញ្ហាអង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ បុគ្គលទាំងនោះមានហេតុផលថា ប្រជាជនកម្ពុជា និងនរណាក៏ដោយក្នុងពិភពលោកដែលស្រវាស្រទេញអំពីការកាត់ទោសពួកខ្មែរក្រហមគួរតែខ្វល់ខ្វាយអំពីការផ្តល់អង្ករឲ្យប្រជាជនកម្ពុជាក្រីក្រប្រកន្ថាំងជាជាងខ្វល់ខ្វាយពីបញ្ហានាំយកមេដឹកនាំខ្មែរក្រហមដែលមានវ័យចំណាស់អស់លក្ខណ៍រួចមកហើយនោះមកកាត់ទោស ។ សម្រាប់មនុស្សដែលមានទស្សនៈបែបនេះ បញ្ហាអភិវឌ្ឍន៍សេដ្ឋកិច្ច និងការធ្វើសមាហរណកម្មប្រទេសកម្ពុជាទៅក្នុងពិភពលោក គឺជាបញ្ហាដ៏សំខាន់បំផុត ហើយក្រុមនេះចង់ឲ្យបញ្ហាកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងស្រុង ឃ្លាតចេញឆ្ងាយពីការចាប់អារម្មណ៍ពីគ្រប់មជ្ឈដ្ឋាន ។ អ្នកដែលចង់ឃើញការធ្វើសមាហរណកម្មប្រទេសកម្ពុជាកាន់តែបានជិតស្និតទៅក្នុងសហគមន៍ពិភពលោកគួរតែពិចារណាផ្តោតឲ្យបានជិតដល់ទៅលើដំណើរការអង្គជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនេះ ។ សំខាន់ត្រូវដឹងថា ការអភិវឌ្ឍន៍សេដ្ឋកិច្ច ការធ្វើសមាហរណកម្មប្រទេសកម្ពុជាចូលទៅក្នុងសហគមន៍ពិភពលោក និងការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់នេះ គឺជាបញ្ហាពាក់ព័ន្ធគ្នាយ៉ាងស្អិតល្មួត ។ ដើម្បីឲ្យការអភិឌ្ឍន៍សេដ្ឋកិច្ចរីកធំធាត់នៅក្នុងប្រទេសកម្ពុជា ជាចាំបាច់ណាស់ប្រទេសកម្ពុជាធ្វើសមាហរណកម្មខ្លួនឯងចូលនៅក្នុងសេដ្ឋកិច្ចពិភពលោក ។ នេះជាភាពពិតនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចពិភពលោកនាពេលបច្ចុប្បន្នកាលនេះ ។ ហើយដើម្បីឲ្យប្រទេសកម្ពុជាធ្វើសមាហរណកម្មចូលទៅក្នុងពិភពលោកបាន «ពិភពលោក» ត្រូវតែមានជំនឿជាមុនថា ប្រទេសកម្ពុជាគឺជាសង្គមដ៏រឹងប៉ឹងមួយ ហើយជាប្រទេសដែលដំណើរការក្រោមរបបដែលប្រកាន់ធម្មាធិបតេយ្យ «យកច្បាប់ជាធំ» ។ ការធ្វើដូច្នេះបានអ្នកវិនិយោគទុនបរទេស និងដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជាអាចមានសេចក្តីទុកចិត្តថាកិច្ចការពាណិជ្ជកម្មរបស់ពួកខ្លួននៅក្នុងប្រទេសកម្ពុជានឹងត្រូវបានការពារដោយច្បាប់ ។ ឥឡូវនេះអ្នកវិនិយោគទុន និងដៃគូពាណិជ្ជ

កម្មទាំងនោះមានការធានាបែបនេះដ៏តិចតួចស្តួចស្តើង ហើយជាផលពិបាក មានតែពាណិជ្ជករធំៗតិចតួចប៉ុណ្ណោះដែលសុខចិត្តប្រថុយប្រថានចូលមកធ្វើពាណិជ្ជកម្មជាមួយនឹងកម្ពុជា ។

ការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលអនុវត្តន៍ដោយតុលាការកម្ពុជា ដោយគ្មានជំនួយពីអង្គការសហប្រជាជាតិដូចដែលប្រជាជនកម្ពុជាជាច្រើនបានចងចាំរួចមកហើយអំពីការកាត់ទោសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នៅឆ្នាំ១៩៩៨ ជាឧទាហរណ៍ស្រាប់ គឺប្រថុយប្រថានទៅនឹងការទទួលរងការគាបសង្កត់ផ្នែកនយោបាយ ។ ហើយការកាត់ទោសបែបនេះនឹងបង្ហាញភ្លាមៗដល់អ្នកវិនិយោគទុន និងពាណិជ្ជករជុំវិញពិភពលោកថា កម្ពុជានៅតែជាតំបន់គ្រោះថ្នាក់សម្រាប់ធ្វើពាណិជ្ជកម្ម ដោយពុំមានមូលដ្ឋានរឹងមាំផ្អែកលើច្បាប់ជាធំ ។ ផ្ទុយទៅវិញ ការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលចាត់ចែងបានយ៉ាងល្អមួយដោយធ្វើឡើងសហការជាមួយនឹងអង្គការសហប្រជាជាតិនឹងមានឥទ្ធិពលជាងអ្វីទាំងអស់ក្នុងការបង្ហាញដល់អ្នកវិនិយោគទុនអន្តរជាតិថា ប្រទេសកម្ពុជាបានផ្លាស់ប្តូរហើយកំពុងតែនៅក្នុងដំណើរការក្លាយខ្លួនជាដៃគូដ៏មាំទាំគួរជាទីទុកចិត្តនិងអាចជឿជាក់បានសម្រាប់សហគមន៍អន្តរជាតិ ។ សំណួរនៅចំពោះមុខយើងក្នុងពេលបច្ចុប្បន្ននេះគឺថា តើលទ្ធផលមួយណាដែលរដ្ឋសភាជាតិ ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលកម្ពុជា នឹងជ្រើសរើសនៅទីបញ្ចប់? កិច្ចចរចានៅក្នុងខែមីនាកន្លងទៅនេះរវាងរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិអំពីការកាត់ទោសមេដឹកនាំខ្មែរក្រហមបានទទួលលទ្ធផលជាច្រើន ។ ក្រុមចរចាទាំងសងខាងទំនងជាបានកាត់បន្ថយនូវភាពខុសប្លែកគ្នាដ៏ស្មុគស្មាញជាច្រើនដោយបន្សល់ទុកនៅត្រឹមបញ្ហាដ៏សំខាន់តែមួយគត់ គឺបញ្ហាប្រើសិទ្ធិវេតូ (សិទ្ធិជំទាស់) របស់សហព្រះរាជអាជ្ញា ។ ខ្ញុំសូមបញ្ជាក់ថាបញ្ហានេះគឺស្ថិតត្រង់ថា អ្នកណាជាអ្នកសម្រេចថាតើមេខ្មែរក្រហមណាខ្លះត្រូវនាំយកមកកាត់ទោស ។ សំណួរនៅត្រង់ថា គណបក្សប្រជាជន ឬក៏ចៅក្រមជំនាញឯករាជ្យនិងមិនលម្អៀងម្នាក់ដែលត្រូវបានជ្រើសតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ និងជាអ្នកមានសិទ្ធិអំណាចបែបនេះ ។

មកទល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាជំហរមួយថា ព្រះរាជអាជ្ញាកម្ពុជានិងបរទេសនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ត្រូវតែឯកភាពរួមគ្នាទើបអាចចេញដីកាចោទប្រកាន់មេដឹកនាំខ្មែរក្រហមណាមួយទៅបាន ។ ឧទាហរណ៍ថា ព្រះរាជអាជ្ញាមួយដែលមានសម្ព័ន្ធភាពជាមួយគណបក្សប្រជាជនត្រូវបានជ្រើសតាំងជាព្រះរាជអាជ្ញាកម្ពុជាពេលនោះ ។ រូបមន្តនេះនឹងអនុញ្ញាតឲ្យរដ្ឋាភិបាលកម្ពុជាបង្អាក់ដំណើរការចេញដីកានាំខ្លួនបុគ្គលណាមួយដែលគណបក្សប្រជាជនចង់ការពារ ។ ទ្រឹស្តីនេះអាចក្លាយជាការពិត ហើយគឺជាការប្រថុយប្រថានមួយដែលអង្គការសហប្រជាជាតិបដិសេធមិនព្រមទទួលយក ពីព្រោះនេះជាការប្រឆាំងទៅនឹងគោលការណ៍ «ច្បាប់ជាធំ» ។ ផ្ទុយទៅវិញការរៀបចំបែបនេះ គឺបញ្ជាក់អំពីសញ្ញាណនៃការប្រើប្រាស់អំណាចជាធំ ជាជាងការប្រើច្បាប់ ។

បញ្ហាសិទ្ធិវេតូរបស់សហព្រះរាជអាជ្ញាទំនងក្លាយជាបញ្ហាដ៏សំខាន់បំផុតមួយដែលនៅសេសសល់សម្រាប់ភាគីទាំងសងខាង ។ គួរចាប់អារម្មណ៍ថា នៅថ្ងៃសៅរ៍ទី១៨ ខែមីនា សម្តេច ហ៊ុន សែន បានបដិសេធពុំធ្វើការអធិប្បាយអំពីកិច្ចចរចានានាជាមួយនឹងអង្គការសហប្រជាជាតិ ប៉ុន្តែសម្តេចបានមានប្រសាសន៍ថា «សង្គ្រាមបានបញ្ចប់ទៅហើយ ដូច្នេះបញ្ហាដែលនៅសេសសល់គឺធ្វើសមាហរណកម្មប្រទេសរបស់យើងទៅក្នុងសហគមន៍ពិភពលោក» ។ សម្តេច ហ៊ុន សែន គឺពិតជាអ្នករៀបចំយុទ្ធសាស្ត្រដែលមានទស្សនវិស័យច្បាស់ ហើយសម្តេច ហ៊ុន សែន ប្រាកដជាបានយល់យ៉ាងច្បាស់ថា តើកិច្ចព្រមព្រៀងជាមួយអង្គកាសហប្រជាជាតិលើការកាត់ទោសនេះ មានសារៈសំខាន់បែបណាចំពោះកេរ្តិ៍ឈ្មោះរបស់កម្ពុជា និងការទទួលស្គាល់នៅក្នុងសហគមន៍អន្តរជាតិ ។ ការជឿជាក់ និងទំនុកចិត្តរបស់សហគមន៍អន្តរជាតិមកលើកម្ពុជា អាស្រ័យទៅលើថាតើបញ្ហាតុលាការនេះនឹងត្រូវបានសម្រេចយ៉ាងដូចម្តេច ។ ក៏ប៉ុន្តែនៅពីក្រោយនៃបញ្ហាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺការជំទាស់យ៉ាងខ្លាំងនៅក្នុងគណបក្សប្រជាជនចំពោះការព្រមព្រៀងផ្តល់ការគ្រប់គ្រងដល់កម្រិតបែបនេះដល់បរទេសលើបញ្ហាដ៏សំខាន់នេះ ។ ក៏ប៉ុន្តែនៅក្នុងអតីតកាល សម្តេច ហ៊ុន សែន ពុំធ្លាប់មានបញ្ហាក្នុងការសម្រេចជួសគណបក្សប្រជាជនជាមុននោះទេ

ហើយពេលខ្លះរហូតដល់ទៅសម្រេចកិច្ចការរំលងជួរបក្សទៀតផង ។ ក៏ប៉ុន្តែអាកប្បកិរិយានយោបាយរបស់សម្តេច ហ៊ុន សែន ហាក់បីដូចជាមានសណ្ឋានដូចៗគ្នាមួយ គឺថាសម្តេចជានិច្ចកាលព្យាយាមរក្សាការបើកជំហរជម្រើសទាំងអស់របស់សម្តេច រហូតដល់សម្តេចមានអារម្មណ៍ថា កាលៈទេសៈបង្ខំឲ្យសម្តេចត្រូវតែជ្រើសរើសនូវជម្រើសណាមួយ ។ សំណួរសួរថាតើនៅពេលណាទើបសម្តេចបង្ខំចិត្តឲ្យត្រូវតែជ្រើសរើសថាតើកម្ពុជាត្រូវសហការ ឬមិនសហការជាមួយអង្គការសហប្រជា-ជាតិ? សម្តេចមានរយៈពេលជាច្រើនឆ្នាំក្នុងការគិតគូសវាសលើការសម្រេចចិត្តនេះ ។ ក្រុមចរចារបស់អង្គការសហប្រជាជាតិថ្នាក់កំពូល រួមមានអគ្គលេខាធិការរងរបស់អង្គការសហប្រជាជាតិជំនួយការអគ្គលេខាធិការអង្គការសហប្រជាជាតិ និងនាយកការិយាល័យអង្គការសហប្រជាជាតិ បានបញ្ជាក់ជូនភាគីកម្ពុជាថាក្រុមរបស់ខ្លួនមានការយកចិត្តទុកដាក់យ៉ាងពេញលេញពីអង្គការសហប្រជាជាតិដើម្បីធ្វើជាតំណាងលើការចរចានេះ ។ បន្ទាប់ពីការដាក់ជូនរបាយការណ៍របស់ក្រុមអ្នកជំនាញផ្នែកច្បាប់របស់ខ្លួន និងការចរចាអស់រយៈពេលជិតបីឆ្នាំកន្លងមកនេះ អង្គការសហប្រជាជាតិ ឥឡូវនេះស្ថិតនៅក្រោមការគាបសង្កត់យ៉ាងតឹងតែងពីសំណាក់រដ្ឋជាសមាជិកដែលមានឥទ្ធិពលជាច្រើនឲ្យសម្រេចបានលទ្ធផលលើបញ្ហាកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សំខាន់លើសពីការគាបសង្កត់ពីសំណាក់រដ្ឋជាសមាជិកនេះ មូលហេតុមួយគឺថាវាជាការសំខាន់របស់អង្គការសហប្រជាជាតិ ដូចដែលតំណាងពិសេសរបស់លោកអគ្គលេខាធិការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ថូម៉ាស ហាម៉ាបឺក បានបញ្ជាក់រួចមកហើយ គឺថាវាជាបញ្ហាកិត្តិយស ។ របាយការណ៍របស់អង្គការសហប្រជាជាតិពីកម្ពុជានៅក្នុងទសវត្សរ៍ឆ្នាំ៨០ បានស្រែកទាមទារឲ្យបើកទំព័រថ្មីមួយ គិតគូរឡើងវិញចំពោះការយកចិត្តទុកដាក់របស់ខ្លួនពីអតីតកាល ។ ការខកខានរបស់អង្គការសហប្រជាជាតិក្នុងការចាត់វិធានការឲ្យបានទាន់ពេលវេលាប្រឈមមុខនឹងអំពើប្រល័យពូជសាសន៍ដែលបានលាតត្រដាងនៅចំពោះមុខខ្លួននៅក្នុងអតីតកាលថ្មីៗ ដូចដែលបានបញ្ជាក់យ៉ាងល្អិតល្អន់នៅក្នុងរបាយការណ៍ថ្មីៗនេះដោយអគ្គលេខាធិការ កូហ្វី អាណាន់ ជារបាយការណ៍ដែលមិនទុកមុខ សូម្បីតែសម្រាប់លោកអគ្គលេខាធិការខ្លួនឯង បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងស្ថាប័ននេះទាំងមូលឲ្យអង្គការសហប្រជាជាតិត្រូវតែចាត់វិធានការដ៏មានកិត្តិយសនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលបច្ចុប្បន្ននេះ ប្រសិនបើអង្គការសហប្រជាជាតិចង់ស្តារឡើងវិញនូវការផ្តល់ជំនឿទុកចិត្តផ្នែកសីលធម៌របស់ខ្លួន ។ ជាអកុសលទោះបីជាមានការត្អូញត្អែរជាប្រចាំពីសំណាក់សម្តេច ហ៊ុន សែន ថាអង្គការសហប្រជាជាតិពុំដំណើរការឲ្យបានឆាប់រហ័សគ្រប់គ្រាន់លើបញ្ហាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយទោះបីជាមានការបញ្ជាក់ច្បាស់ថា ប្រជាជនកម្ពុជាចង់ឲ្យអង្គការសហប្រជាជាតិបានចូលរួមជាសំខាន់នៅក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម រដ្ឋាភិបាលកម្ពុជាទំនងជាពុំមានអារម្មណ៍ទទួលការគាបសង្កត់ស្រដៀងគ្នានេះដើម្បីឈានដល់កិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិលើបញ្ហានេះឡើយ ។ មានទស្សនៈមួយដែលកំពុងតែវិវត្តន៍ខ្លាំងឡើងថា រាជរដ្ឋាភិបាលកម្ពុជាគ្រាន់តែបណ្តែតបណ្តោយមិនចង់ឈានដល់កិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ដោយចង់ធ្វើឲ្យអង្គការសហប្រជាជាតិអស់ការអត់ធ្មត់ ។ រដ្ឋាភិបាលកម្ពុជាប្រហែលជាឈានជិតដល់ការទទួលជោគជ័យក្នុងគោលដៅនោះហើយ ក៏ប៉ុន្តែមកទល់ពេលនេះ អង្គការសហប្រជាជាតិនៅតែរក្សាជំហរយ៉ាងមាំលើបញ្ហានេះដដែល ។

សម្តេច ហ៊ុន សែន អាចទទួលបានផលប្រយោជន៍ច្រើនដោយគ្រាន់តែព្រមព្រៀងជាមួយនឹងអង្គការសហប្រជាជាតិ ហើយផ្ទុយទៅវិញ សម្តេចក៏អាចខាតបង់ច្រើនទៅវិញដែរ ប្រសិនបើពុំព្រមឈានដល់កិច្ចព្រមព្រៀងនេះ ។ ប្រសិនបើសម្តេច ហ៊ុន សែន ព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ កេរដំណែលប្រវត្តិសាស្ត្ររបស់សម្តេចនឹងក្លាយទៅជាប្រមុខរដ្ឋដែលបានវាយផ្តួលរំលំរបបខ្មែរក្រហមទាំងស្រុង ហើយនៅទីបញ្ចប់បាននាំយកឧក្រិដ្ឋជនទាំងនេះមកកាត់ទោសដែលត្រូវបានគ្រប់មជ្ឈដ្ឋានផ្តល់ការជឿទុកចិត្ត ។ ប្រសិនបើសម្តេចមិនព្រមព្រៀងជាមួយអង្គការសហប្រជាជាតិកេរដំណែលដែលសម្តេចបន្សល់ទុកនឹងខុសប្លែកពីនេះយ៉ាងខ្លាំង ហើយមនុស្សភាគច្រើន

មុខជាពុំសូវសប្បាយចិត្តឡើយ ។ ការព្រួយបារម្ភដ៏ធំបំផុតរបស់សម្តេច ប្រហែលជាពុំមែនបញ្ហាកិត្តិសព្ទរបស់សម្តេចផ្ទាល់លើអន្តរជាតិ ឬសូម្បីតែកិត្តិសព្ទរបស់កម្ពុជាលើឆាកអន្តរជាតិក៏សម្តេចមិនបារម្ភដែរ ក៏ប៉ុន្តែការព្រួយបារម្ភណ៍ធំបំផុតរបស់សម្តេចគឺជាផលវិបាកនយោបាយក្នុងស្រុកដែលផុសចេញពីការសម្រេចចិត្តលើបញ្ហាតុលាការនេះ ។ នៅក្នុងគណបក្សប្រជាជនយោបល់លើបញ្ហាថាតើត្រូវដោះស្រាយមេដឹកនាំខ្មែរក្រហមយ៉ាងដូចម្តេចនោះ មានភាពច្របូកច្របល់ ។ នៅម្ខាងមានការជំទាស់បីប្រភេទទៅនឹងតុលាការនេះ ឬយ៉ាងហោចណាស់ជំទាស់ទៅនឹងការចូលរួមយ៉ាងច្រើនលើសលប់របស់អង្គការសហប្រជាជាតិក្នុងតុលាការនេះ ។ យើងអាចហៅក្រុមមួយថាជា «ក្រុមជាតិនិយម» ដែលប្រឆាំងទៅនឹងការចូលរួមរបស់អង្គការសហប្រជាជាតិទោះក្នុងលក្ខខណ្ឌណាក៏ដោយ នៅក្នុងតុលាការនេះ ។ ក្រុមនេះបង្ហាញអំពីការស្អប់ខ្ពើម ចំពោះការជ្រៀតជ្រែកពីខាងក្រៅនៅក្នុងកិច្ចការរបស់ប្រទេសកម្ពុជា ដោយកម្ពុជាធ្លាប់បានរស់នៅក្រោមលក្ខខណ្ឌនៃការជ្រៀតជ្រែកដោយបរទេសនៅក្នុងកិច្ចការរបស់កម្ពុជាអស់រយៈពេលច្រើនសតវត្សរ៍មកហើយ ។ ក្រុមមួយទៀតគឺ «ក្រុមជំទាស់» ដែលប្រឆាំងនឹងគំនិតបង្កើតតុលាការនេះទាំងស្រុង ដោយឈរលើហេតុផលថា តុលាការបែបនេះអាចនឹងបង្កគ្រោះថ្នាក់ដល់ការបង្រួបបង្រួមជាតិ ។ ក្រុមទីបី គឺក្រុមដែលយើងហៅថា «ក្រុមការពារ» ដែលមានអារម្មណ៍ថា ក្បាលខ្មោចជនរងគ្រោះរាប់មិនអស់នៅចំពោះមុខគណបក្សប្រជាជនដែលធ្វើឲ្យគណបក្សកម្ពុជាក្រុមនេះយល់ថាមិនត្រូវសុខចិត្តឲ្យការកាត់ទោសមេដឹកនាំខ្មែរក្រហមដោយឯករាជ្យ និងយុត្តិធម៌ដោយសេរីរបូតទៅបាត់ ។ និន្នាការប្រឆាំងទាំងបីនេះ នៅក្នុងគណបក្សប្រជាជនចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានប្រឈមមុខជាមួយក្រុមបីដទៃទៀត នៅក្នុងគណបក្សនេះដែលមានគំនិតគាំទ្រឲ្យមានការចូលរួមពីអន្តរជាតិយ៉ាងខ្លាំងក្លា នៅក្នុងតុលាការប្រល័យពូជសាសន៍នេះ ក្រុមមួយដែលយើងហៅថា «ក្រុមអន្តរជាតិនិយម» យល់ថា កិច្ចសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិលើបញ្ហាតុលាការនេះអាចនាំមកនូវផលប្រយោជន៍ជាច្រើនផ្នែក រាប់តាំងពីជំនួយហិរញ្ញវត្ថុទ្វេភាគី និងពហុភាគី រហូតដល់ទំនុកចិត្តផ្នែកនយោបាយកាន់តែខ្លាំងឡើងលើឆាកអន្តរជាតិ ដូចជាពីសំណាក់ក្រុមប្រទេសអាស៊ានជាដើម ។ ក្រុមមួយទៀតដែលអាចហៅថា ជាក្រុម «ទំនើបនិយម» សម្លឹងមើលច្រើនជាងលើផលប្រយោជន៍ក្នុងស្រុកដែលនឹងកើតចេញពីតុលាការដែលរៀបចំបានយ៉ាងល្អមួយ ។ ផលប្រយោជន៍ទាំងនោះរួមមានកម្ចាត់វប្បធម៌នៃភាពរួចទោស ហើយផ្តល់នូវគំរូដ៏ល្អមួយដែលជាតម្លៃនៃតុលាការឯករាជ្យមួយ ។ ក្រុមចុងក្រោយហើយប្រហែលជាក្រុមដែលធំជាងគេបំផុតនៅក្នុងចំណោមក្រុមដទៃទៀតនៅក្នុងគណបក្សប្រជាជនដែលយើងអាចហៅថាជាក្រុម «ជ័យជម្នះនិយម» ។ ក្រុមដ៏ធំនេះចង់ឃើញតុលាការទ្រង់ទ្រាយធំមួយសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមហើយចង់ឲ្យតុលាការនោះត្រូវបានផ្តល់នូវភាពស្របច្បាប់ពេញលេញដោយសហគមន៍អន្តរជាតិដើម្បីជាការសងសឹកចុងក្រោយមួយប្រឆាំងនឹងជនទាំងឡាយ ដែលបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជានិងបង្កមហន្តរាយដ៏សន្ធឹកសន្ធាប់ ក៏ដូចជាដើម្បីផ្តល់ «ភ័ស្តុតាង» ចុងក្រោយអំពីភាពត្រឹមត្រូវនៅក្នុងការយល់ឃើញរបស់បក្សចំពោះកេរដំណែលប្រវត្តិសាស្ត្ររបស់ខ្លួន ។ ក្នុងខណៈជាដៃគូមានប្រៀបជាងនៅក្នុងរដ្ឋាភិបាលចម្រុះនាពេលបច្ចុប្បន្ន និងដែលមានមតិភាគច្រើននៅក្នុងស្រទាប់រដ្ឋសភាជាតិ គណបក្សប្រជាជនប្រហែលជាមានអំណាចក្នុងការសម្រេចពីលទ្ធផលលើបញ្ហានេះ ។ សំណួរសួរថា តើតុល្យភាពនៃឥទ្ធិពលក្នុងចំណោមនិន្នាការដែលប្រទាញប្រទង់គ្នាខាងលើនៅក្នុងគណបក្សប្រជាជនស្ថិតនៅត្រង់ណា? នេះជាការសាកល្បងនៅក្នុងស្ថានភាពដ៏ស្មុគស្មាញមួយរបស់សម្តេច ហ៊ុន សែន ដើម្បីរកឲ្យឃើញនូវចម្លើយចំពោះសំណួរនេះ ហើយជាការសាកល្បងដ៏សំខាន់បំផុតរបស់សម្តេច ក្នុងនាមជាអ្នកនយោបាយម្នាក់ ។

ការវិភាគលើសមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិចមានការងាយស្រួលជាងបញ្ហានេះស្ទើរតែគ្រប់គ្នាអាចប្រាប់ថាសមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិចស្ទើរតែទាំងអស់ទំនងជាគាំទ្រការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងតុលាការនេះ ។ ករណីលើកលែងតែមួយគត់គឺថា សមាជិកគណបក្សហ្វ៊ុនស៊ិនប៉ិចមួយចំនួន

អាចខ្លាចមិនហ៊ានប្រឆាំងជាមួយសម្តេច ហ៊ុន សែន ក៏ប៉ុន្តែ សំណួរសួរថា តើសមាជិកគណបក្សហ៊ុនស៊ិនប៉ិចប៉ុន្មាននាក់ ដែលមានការភ័យខ្លាចបែបនេះ ការពិតនឹងត្រូវបានដឹងក្នុងពេល ឆាប់ៗនេះ? ។

ការចូលរួមដោយអង្គការសហប្រជាជាតិនៅក្នុងការ កាត់ទោសមេដឹកនាំខ្មែរក្រហម នឹងផ្តល់សញ្ញានៃការវិលត្រឡប់ យ៉ាងពេញលេញរបស់កម្ពុជាចូលទៅក្នុងសហគមន៍ប្រជាជាតិ ក្នុងនាមជាដៃគូស្មើភាពមួយ និងជារដ្ឋក្នុងសមាជិកស្ថាបនាមួយ បន្ទាប់ពីកម្ពុជាត្រូវបានដាក់ក្នុងឋានៈលំដាប់ទីពីរ ឬក៏ឋានៈលំដាប់ ទីបី ជាប្រទេសក្រោមអាណាព្យាបាលរបស់សហគមន៍អន្តរជាតិ មួយ និងជាប្រទេសដែលមិនគោរពច្បាប់មួយ អស់រយៈពេល ជាច្រើនឆ្នាំមកហើយ ។ នេះជាពេលសមគួរដែលកម្ពុជាត្រូវ ចាត់វិធានការសហការជាមួយអង្គការសហប្រជាជាតិក្នុងការ កាត់ទោសនេះ ។ ការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុង តុលាការខ្មែរក្រហម និងមិនត្រឹមតែចង្អុលបង្ហាញថា ប្រជាជន កម្ពុជាសមនឹងទទួលនូវសិទ្ធិទទួលបានយុត្តិធម៌ ដូចជាប្រជាពលរដ្ឋ នៅតាមបណ្តាប្រទេសអ៊ឺរ៉ុប ដែលកំពុងទទួលបាននូវយុត្តិធម៌ពី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែរ ។ ការ ផ្តល់នូវតុលាការដែលពុំអាចផ្តល់នូវយុត្តិធម៌កម្រិតនេះនឹងទម្លាក់ ប្រទេសកម្ពុជាជាថ្មីទៅក្នុងឋានៈបន្ទាប់បន្សំនៅក្នុងសហគមន៍អន្តរ ជាតិយ៉ាងតិចបំផុតអស់រយៈពេលមួយជំនាន់ទៀត ។ ប្រជាជន ជាច្រើននៅក្នុងពិភពលោកនឹងសន្និដ្ឋានថា កម្ពុជានឹងទទួលរងនូវ ការខូចខាតជាដំណៅដោយវិបត្តិអំពើប្រល័យពូជសាសន៍ដែលពួក ខ្លួនមិនអាចទុកចិត្តធ្វើជាដៃគូសម្រាប់ធ្វើពាណិជ្ជកម្ម ឬសម្រាប់ ទិដ្ឋភាពដទៃទៀតនៅក្នុងសហគមន៍អន្តរជាតិនាសម័យថ្មី ប្រសិន បើប្រទេសកម្ពុជាពុំព្រមទទួលយកការចូលរួមពីសំណាក់អង្គការ សហប្រជាជាតិ ។ ការដែលអង្គការសហប្រជាជាតិខកខានពុំបាន ចូលរួមនៅក្នុងតុលាការនេះនឹងសបញ្ជាក់ថា នៅពេលដែលជន ជាតិបូស្នៀរាប់រយពាន់នាក់ ត្រូវបានសម្លាប់យ៉ាងឃោរឃៅឬ នៅពេលដែលជនជាតិរ៉ាន់ដា ប្រមាណ៨០,០០០នាក់ ត្រូវបាន កាប់សម្លាប់ សហគមន៍អន្តរជាតិស្ទុះស្ទារទៅដាក់ទោសជនដៃដល់ ទាំងនោះ ក៏ប៉ុន្តែដល់ពេលប្រជាជនកម្ពុជាប្រមាណ២លាននាក់ ស្លាប់ក្រោមកណ្តាប់ដៃរបបខ្មែរក្រហម បែរជាបណ្តែតបណ្តោយ ការគិតថា ប្រជាជនកម្ពុជាទាំងនោះគ្រាន់តែជាជនជាតិអាស៊ី ហើយរដ្ឋាភិបាលរបស់ប្រជាជនកម្ពុជាពុំខ្វល់ខ្វាយគ្រប់គ្រាន់អំពី ជនរងគ្រោះរបស់ខ្លួនក្នុងការផ្តល់ជូននូវយុត្តិធម៌កម្រិតស្តង់ដា អន្តរជាតិ ដូចដែលជនរងគ្រោះអ៊ឺរ៉ុប និងនៅអាហ្វ្រិកបានទទួល ។ យុត្តិធម៌បែបនេះ ប្រជាជនកម្ពុជាមិនគួរទទួលយក ហើយក៏មិន ស័ក្តិសមទទួលយកដោយសហគមន៍អន្តរជាតិដែរ ។ ប្រជាជនកម្ពុជា ស័ក្តិសមទទួលយកនូវយុត្តិធម៌ថ្នាក់លេខមួយ ចំពោះឧក្រិដ្ឋកម្មដ៏ សាហាវឃោរឃៅបំផុតនៅចុងសតវត្សរ៍ទី២០ កន្លងទៅថ្មីៗនេះ ហើយប្រជាជនកម្ពុជាក៏ដឹងដែរថា ពុំអាចទទួលបាននូវយុត្តិធម៌ ថ្នាក់លេខមួយនេះបានទេ ប្រសិនបើអង្គការសហប្រជាជាតិពុំ ចូលរួម ។ មូលហេតុដែលប្រជាជនជាច្រើននៅជុំវិញពិភពលោក មិនមែនត្រឹមតែប្រជាជនកម្ពុជាប៉ុណ្ណោះទេមានការរំជួលចិត្តអំពី បញ្ហាកាត់ទោសមេដឹកនាំខ្មែរក្រហម គឺថាអំពើដែលខ្មែរក្រហម បានធ្វើគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សូមឲ្យយើង យល់ឲ្យច្បាស់អំពីបញ្ហានេះ គឺថាឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវ បានប្រព្រឹត្តដោយរបបខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជាដែល ប្រជាជនកម្ពុជាភាគច្រើនជាជនរងគ្រោះក្រោមអំពើឧក្រិដ្ឋទាំង នេះ គឺមានកម្រិតធ្ងន់ធ្ងររហូតដល់ក្លាយជាឧក្រិដ្ឋកម្មក្នុងប្រភេទ ពិសេសមួយហៅថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ នេះមាន ន័យថា សមាជិកទាំងអស់នៃគ្រួសារមនុស្សជាតិ ទោះបីជាមាន សញ្ជាតិ ឬពូជសាសន៍អ្វីក៏ដោយ គឺជាជនរងគ្រោះនៃរបបខ្មែរ ក្រហម ដូច្នេះសមាជិកទាំងអស់នៃពូជសាសន៍មនុស្សមានសិទ្ធិ និងការទទួលខុសត្រូវមួយត្រូវមើលឃើញឲ្យច្បាស់ថា យុត្តិធម៌ ត្រូវបានផ្តល់ជូនដល់ជនរងគ្រោះនៅក្នុងការប្រល័យពូជសាសន៍ ដោយរបបខ្មែរក្រហម ។ ការសម្រេចចិត្តរបស់សហគមន៍អន្តរជាតិ ដើម្បីមើលឲ្យឃើញច្បាស់ថា យុត្តិធម៌ត្រូវបានផ្តល់ជូនជនរងគ្រោះ ដោយឧក្រិដ្ឋកម្មបែបនេះ ហើយនិងដើម្បីអនុវត្តន៍ច្បាប់អន្តរជាតិ ដែលកំពុងបានវិវឌ្ឍន៍ឆ្លងកាត់សតវត្សរ៍មុនត្រូវបានឃើញដំបូង បង្អស់នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិពីរ គឺតុលាការសម្រាប់ អតីតយូហ្គូស្លាវី និងរ៉ាន់ដា ។ នៅក្នុងពេលអនាគតឧក្រិដ្ឋកម្មបែប នេះនឹងត្រូវបានដាក់ទោសនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិមួយ

ប៉ុន្តែនៅពេលឥឡូវនេះវាជាការចាំបាច់បន្ទាន់មួយដែលមេដឹកនាំខ្មែរក្រហមត្រូវប្រឈមមុខនឹងយុត្តិធម៌ដែលមានកម្រិតស្តង់ដាអន្តរជាតិ ហើយដើម្បីឲ្យមានយុត្តិធម៌កម្រិតអន្តរជាតិបែបនេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ត្រូវមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិ ។ បើមិនដូច្នោះទេ យុត្តិធម៌ប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា នឹងក្លាយជាបញ្ហានយោបាយជាជាងបញ្ហារកយុត្តិធម៌មួយ ។ មកទល់ពេលនេះអ្វីដែលប្រជាជនកម្ពុជាចង់បានគឺមានភាពច្បាស់លាស់គ្មានមន្ទិលសង្ស័យ ។ ការស្ទាបស្ទង់ជាច្រើនត្រូវបានធ្វើឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះលើបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយជានិច្ចកាលលទ្ធផលដែលចេញមកគឺដូចគ្នាប្រជាជនកម្ពុជាដ៏ច្រើនលើសលប់ចង់បានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយប្រជាជនកម្ពុជាដ៏ច្រើនលើសលប់បានគាំទ្រតួនាទីជាអន្តរជាតិដ៏មាំទាំមួយនៅក្នុងតុលាការនោះ ។ នៅក្នុងរបបប្រជាធិបតេយ្យរដ្ឋាភិបាលត្រូវបម្រើសុឆន្ទៈរបស់ប្រជាជន ។ នៅពេលឆាប់ៗខាងមុខនេះយើងនឹងបានដឹងថា តើរបបបែបណាដែលគ្រប់គ្រងប្រទេសកម្ពុជា ។

**ក្រេក អ៊ិចឆេសាន់**



កងយុទ្ធជនដឹកជញ្ជូនគ្រាប់រំសេវ

# ម្ភៃប្រាំឆ្នាំក្រោយស្រមោលនៃការពិត

## ការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនៅក្នុងបរិបទអន្តរជាតិ

នៅក្នុងរយៈពេលប៉ុន្មានថ្ងៃបន្ទាប់ពីពួកខ្មែរក្រហមបានឈានជើងចូលទីក្រុងភ្នំពេញអ្នកយកព័ត៌មានឲ្យកាសែត ញូវយក ថែម គឺលោក ស៊ីដនី ស្គែនបឺក បានសម្ងំពួននៅក្នុងស្ថានទូតបារាំង រួមជាមួយជនបរទេសប្រមាណ៨០០នាក់ទៀត ដើម្បីស្វែងយល់ពីឥទ្ធិពលបដិវត្តន៍របស់ពួកខ្មែរក្រហម ។ នៅក្នុងពេលដែលប្រជាជនប្រមាណជា ២លាននាក់ នៅរាជធានីភ្នំពេញនិង ប្រជាជនរាប់មិនអស់នៅតាមបណ្តាទីប្រជុំជនដទៃទៀតបានចាកចេញពីលំនៅដ្ឋានរបស់ខ្លួន ឆ្ពោះទៅកាន់បណ្តាភូមិនានានៅតាមទីជនបទដាច់ស្រយាល ប្រជាជាតិដទៃទៀតក្នុងពិភពលោក បានស្ទិតស្ទាញក្នុងការស្វែងយល់អំពីព្រឹត្តការណ៍ដែលកំពុងបានកើតឡើងនាពេលនោះតាមរយៈអ្នកកាសែតអន្តជាតិមួយចំនួនតូចបំផុត ដែលក្នុងពេលនោះជាប់នៅក្នុងប្រទេសកម្ពុជានៅឡើយ ។ ព័ត៌មានដែលចេញផុតពីប្រទេសកម្ពុជាទៅតាមទំព័រកាសែតនានាជុំវិញពិភពលោកនាពេលនោះ គឺគ្រាន់តែជាស្រមោលនៃការពិតប៉ុណ្ណោះ ។ កាលណោះ «ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥» កាសែតញូវយ៉ក ថែមចុះផ្សាយថា «កាលពីម្សិលមិញនេះ ជនស៊ីវិលកម្ពុជារាប់ពាន់នាក់ ត្រូវបានរាយការណ៍មកថា បាននឹងកំពុងត្រូវបង្ខំចាកចេញពីក្រុងភ្នំពេញក្រោមបញ្ជាពីពួកកុម្មុយនិស្ត ដែលបានទទួលជ័យជម្នះ» ។ ទីភ្នាក់ងារសារព័ត៌មានបារាំង បានរាយការណ៍ថា «កាលពីយប់ម្សិលមិញកងល្បាតរបស់ពួកកុម្មុយនិស្តខ្មែរក្រហមកាន់មេក្រូដើរតាមផ្លូវស្រែកប្រាប់ប្រជាជនទាំងអស់ឲ្យចាកចេញពីក្រុងភ្នំពេញទៅទីជនបទជាង២០គីឡូម៉ែត្រ ។ ក៏ប៉ុន្តែទំហំពេញលេញនៃអំពើឃោរឃៅព្រៃផ្សៃ ដែលកំពុងចាប់ផ្តើមនាពេលប៉ុន្មានថ្ងៃនោះស្ទើរតែពុំអាចស្រមៃស្មានដល់ ។ សូម្បីតែអ្នកកាសែតដែលនៅក្នុងប្រទេសកម្ពុជា ក្នុងប៉ុន្មានថ្ងៃនោះក៏ពុំនឹកស្មានដល់ថា អំពើប្រល័យពូជសាសន៍លើប្រជាជនមួយភាគបួននៃប្រជាជនទាំងមូលអាចកើតឡើងទៅរួចដែរ ។ ប៉ុន្មានសប្តាហ៍ក្រោយមកអ្នកកាសែតស៊ីដនី បានរាយការណ៍ថា «មន្ត្រីជនជាតិអាមេរិកបានទស្សន៍ទាយថា ពួកកុម្មុយនិស្តនឹងអនុវត្តការសម្លាប់រង្គាលមួយនៅពេលដែលពួកនេះឡើងកាន់អំណាចដោយសម្លាប់គ្មានត្រាប្រណីនូវមន្ត្រីជាន់ខ្ពស់ និងបញ្ញវ័ន្តនៃរបបសាធារណរដ្ឋអស់ប្រមាណជាង២០០០០នាក់ ។ មានរបាយការណ៍អំពីការសម្លាប់មន្ត្រីយោធា និងស៊ីវិលជាន់ខ្ពស់ដែលពុំមានភស្តុតាងបញ្ជាក់ជាច្រើន ហើយក្នុងចំណោមអ្នកដែលបានឃើញផ្ទាល់ភ្នែកនូវការឡើងកាន់អំណាចរបស់ពួកកុម្មុយនិស្តគ្រប់គ្នាគ្មានមន្ទិលសង្ស័យទេថា មន្ត្រីកំពូលៗនៃរបបចាស់ មុខជានឹងត្រូវបានឬត្រូវបាន



កុមារដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវ

ដាក់ទោស និងប្រហែលជាត្រូវបានយកទៅសម្លាប់ចោលរួចអស់ទៅហើយ ឬអ្នកដែលបានឃើញព្រឹត្តិការណ៍ផ្ទាល់ភ្នែកនាពេលនោះពិតជាសង្ស័យថា ប្រជាជនមួយចំនួនធំនឹងស្លាប់ដោយការលំបាកវេទនានៅក្នុងអំឡុងពេលនៃការដើរឆ្ពោះទៅកាន់ទីជនបទដាក់ជាមិនខាន ។ ក៏ប៉ុន្តែគ្មានអំពើណាមួយដែលមានសណ្ឋានដូចទៅនឹងការសម្លាប់ទាំងហ្វូងៗដែលត្រូវបានទស្សន៍ទាយទុកដោយពួកបស្ចិមប្រទេសនោះទេ» ។

តាមពិតអំពើទាំងឡាយនៃរបបខ្មែរក្រហមពុំមានសណ្ឋានដូចទៅនឹងការទស្សន៍ទាយរបស់ពួកបស្ចិមប្រទេសមែនៗ ក៏ប៉ុន្តែអំពើទាំងនោះសាហាវហួសពីការភ័យខ្លាចរបស់ពិភពលោកទៅទៀត ។ ព្រឹត្តិការណ៍នៅក្នុងសប្តាហ៍នោះបានប្រែក្លាយរបបកម្ពុជាប្រជាធិបតេយ្យជារបបមួយដ៏យង់ឃ្នងបំផុតនៅក្នុងទសវត្សរ៍ទី២០ និងបង្កឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដ៏ធ្ងន់ធ្ងរបំផុត ។ ប្រជាជនប្រមាណជា ១,៥ ទៅ២លាននាក់ត្រូវបានសម្លាប់ដោយរបបខ្មែរក្រហមដែលបានបង្ខំឲ្យប្រជាជនភាគច្រើនជម្លៀសទៅរស់នៅក្នុងជំរំធ្វើការងារនានា ហើយបានបង្អត់អាហារពុំផ្តល់ថ្នាំសង្កូវ និងផ្តាច់សិទ្ធិជាមូលដ្ឋានភាគច្រើនរបស់ប្រជាជនទាំងនោះ ។ នៅពេលនោះ សហគមន៍អន្តរជាតិបានដឹងត្រឹមតែស្រមោលមួយនៃអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ។ ម្ភៃប្រាំឆ្នាំក្រោយមកនៅក្នុងពេលប្រារព្ធបុណ្យខួបនៃការផ្តួលរំលំរបបខ្មែរក្រហមចេញពីក្រុងភ្នំពេញ ជិតឈានមកដល់ប្រទេសកម្ពុជាបានចាប់ផ្តើមប្រឈមមុខនឹងប្រវត្តិសាស្ត្ររបស់ខ្លួនចាប់ផ្តើមគាស់រំលើងនូវការពិតដែលត្រូវបានបិទបាំងក្នុងចំណោមស្រមោលព្រាលៗដែលបន្សល់ទុកដោយបដិវត្តន៍នោះ ។ ការបញ្ចប់នៃសង្គ្រាមក្នុងឆ្នាំ១៩៩៨ បាននាំ អៀង សារី ខៀវ សំផន និង នួន ជា ចេញពីព្រៃជាទីជម្រកនៅភាគខាងជើងនៃប្រទេស ហើយវិលត្រឡប់មករួមរស់ក្នុងសង្គមជាតិកម្ពុជាវិញ ដែលជាមូលហេតុបញ្ឆេះឲ្យមានការពិភាក្សាជាតិ និងអន្តរជាតិមួយថាតើត្រូវដោះស្រាយបញ្ហាអតីតកាលនេះតាមរបៀបណា ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការពិភាក្សាដ៏ផុលផុស និងក្តៅគគុកមួយបានកើនឡើងដោយមានភាគីជាច្រើនដាក់ការគាបសង្កត់មកលើរដ្ឋាភិបាលកម្ពុជា ឲ្យចាត់វិធានការតាមមធ្យោបាយជាច្រើនដើម្បីដោះស្រាយបញ្ហាមេដឹកនាំជនបដិវត្តន៍ខ្មែរក្រហមទាំងនោះ ។ នៅពេលនោះកម្ពុជាបានពើបប្រទះនឹងវត្តមានរបស់ខ្លួនលើឆាកអន្តរជាតិ នៅត្រង់ចំណុចរបត់ដ៏ចម្រូងចម្រាស់នៃច្បាប់សិទ្ធិមនុស្ស និងបទដ្ឋានច្បាប់អន្តរជាតិនានា ។

ការពិភាក្សារបស់កម្ពុជា គឺជាផ្នែកមួយនៃការពិភាក្សាជាបន្តបន្ទាប់ជាច្រើន ដែលធ្លាប់បានកើតឡើងរួចមកហើយនៅក្នុងបណ្តាប្រទេសមួយចំនួន ដែលកំពុងឆ្លងកាត់អន្តរកាលឆ្ពោះទៅការប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យ និងដំណើរការនៃសន្តិភាពក្នុងអំឡុង២០ឆ្នាំ កន្លងទៅនេះ ។ ចាប់តាំងពីប្រទេសអាហ្សង់ទីន បានសម្រេចចិត្តនាំយកមកកាត់ទោសឥស្សរជនសំខាន់ៗទាំងប្រាំ នៃរដ្ឋាភិបាលយោធាដែលបានកាន់អំណាចដោយរបបផ្តាច់ការឃោរឃៅមួយអស់រយៈពេល៧ឆ្នាំ នៅក្នុងទសវត្សរ៍ឆ្នាំ៧០ និង៨០ ប្រទេសជាច្រើនទៀតបានអនុវត្តតាម ដោយជ្រើសរើសចេញពីជម្រើសមួយចំនួនអំពីថាតើត្រូវដោះស្រាយបញ្ហាអតីតកាលរបស់ខ្លួនយ៉ាងដូចម្តេច ។

ការពិភាក្សាភាគច្រើន បានផ្តោតលើថាតើប្រទេសទាំងនោះគួរទទួលស្គាល់ជាផ្លូវការ ហើយចាត់វិធានការចំពោះការរំលោភបំពានសិទ្ធិមនុស្សនៃរបបអតីតកាល ឬយ៉ាងណា ។ ក្រុមបណ្ឌិត អ្នកវិភាគ និងភាគីដែលចាប់អារម្មណ៍ទាំងឡាយបានទាញហេតុផលយ៉ាងទូលំទូលាយថា វាជាកំហុសមួយដែលរដ្ឋាភិបាលមួយរាំងខ្ទប់ការពិភាក្សានានាអំពីការចងចាំ ផ្ទុយទៅវិញគួរតែទុកឲ្យប្រវត្តិសាស្ត្រវិវត្តន៍ទៅតាមផ្លូវរបស់វា ហើយកុំឲ្យប្រវត្តិសាស្ត្រដ៏អាក្រក់នោះវិលត្រឡប់មកវិញសាជាថ្មីទៀត ។ ជារឿយៗអ្នកវិភាគច្រើនទាញហេតុផលថា ការដែលប្រទេសមួយយកបញ្ហា ការរំលោភបំពានសិទ្ធិមនុស្សក្នុងអតីតកាលមកពិភាក្សា ហើយបកអាក្រាត ឬលាតត្រដាងអំពីរំលោភបំពានទាំងនោះទាំងស្រុងដល់សាធារណជនអាចនឹងសាបព្រោះនូវការបែកបាក់ជាបន្ត ហើយរហូតដល់ទៅអាចបង្កឲ្យមានការវាយប្រហារសងសឹកគ្នាទៅវិញទៅមក ។ លើសពីនេះមានអ្នកខ្លះទៀតទាញហេតុផលថា ការផ្សព្វផ្សាយពត៌មានបែបនេះទាំងស្រុងនឹងធ្វើឲ្យមនុស្សស្រករក្រោយបែកបាក់គ្នា ព្រោះអ្នកទាំងនោះប្រហែលជាមិនបានឆ្លងកាត់ទុក្ខវេទនាក្នុងសង្គ្រាម ឬរស់នៅក្រោមរបបកាលពីអតីតកាល ។ **ម៉ៃឃើល ស៊ីញ៉ូរ *(នៅមានត)***

# មាស សារិន បានដឹងអំពីជោគវាសនារបស់បងប្អូនជីដូនមួយ តាមរយៈទស្សនាវដ្តី "ស្វែងរកការពិត"

ទស្សនាវដ្តី «ស្វែងរកការពិត»លេខ១ បានផ្សព្វផ្សាយចម្លើយសារភាពរបស់ឈ្មោះ ទីវ មុី ហៅ សន្តិភាព ដែលត្រូវជាប្អូនរបស់ឈ្មោះ ទីវ អុល ហៅ ពេញ ដែលត្រូវបានពួកខ្មែរក្រហមចាប់ និងយកទៅសម្លាប់ដោយចោទថាជាខ្មែរសេរី សេ-អុី-អា និងក្បត់ជួរបក្សនៅភូមិភាគបូព៌ (យោងឯកសារ D០០០៤៩ ដែលមានចំណងជើងថា ប្រវត្តិរូប សមមិត្ត ទីវ អុល ហៅពេញ ចាប់ពីឆ្នាំ១៩៥០ ដែលមានចំនួន ១០៣ទំព័រ សរសេរចាប់ពីថ្ងៃទី១៤ ខែកក្កដា ដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៧ នៅមន្ទីរស-២១) ។ ទីវ មុី ក៏ទទួលជោគវាសនាមិនខុសពីបងរបស់គាត់ ទីវ អុល ដែរ ។ ទីវ មុី ហៅ សន្តិភាព និយាយរៀបរាប់ក្នុងចម្លើយសារភាព J០០៦៤២ថា «នៅល្ងាចថ្ងៃមួយ ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៧ ខ្ញុំបានសុំប្រធានកងយកស្លឹកទៅត្រាំដើម្បីប្រក់ផ្ទះ ។ ប្រហែលជាម៉ោង៤ល្ងាច នៅពេលដែលខ្ញុំកំពុងតែរៀបចំស្លឹកដាក់រទេះស្រាប់តែប្រធានសហករណ៍និងគ្នាពីរបីនាក់ទៀត ដែលមិនស្គាល់បានមកប្រាប់ខ្ញុំថាអង្គការស្នើភ្ជាម ៗ» ក្រោយមក ទីវ មុី ត្រូវបានចាប់បញ្ជូនមកមន្ទីរស-២១ ហើយវាយសួរចម្លើយនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧ ក្រោមការសួរចម្លើយរបស់សមមិត្តអឿន រួចក៏យកទៅសម្លាប់ចោល ។

ក្នុងចំណោមទស្សនាវដ្តីស្វែងរកការពិតលេខ១ដែលចែកផ្សាយយ៉ាងទូលំទូលាយទៅគ្រប់ស្រុក ទីប្រជុំជន និងក្រុងទូទាំងប្រទេស អ្នកមីង មាស សារិន បានទទួលទស្សនាវដ្តីមួយច្បាប់ ហើយមានការរន្ធត់ក្នុងចិត្តយ៉ាងខ្លាំងបន្ទាប់ពីបានអានចម្លើយសារភាពរបស់ ទីវ មុី ។ ពិព្រោះជនរងគ្រោះ ទីវ មុី នេះត្រូវជាប្អូនជីដូនមួយរបស់គាត់ ។ គាត់ក៏បានទូរស័ព្ទមកសួរមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានបញ្ជាក់ប្រាប់ពីទំនាក់ទំនងរវាង ទីវ មុី និងរូបអ្នកមីងផ្ទាល់ ព្រមទាំងនិយាយប្រាប់ត្រួសៗពីសាច់រឿងដែលអ្នកមីងបានដឹងអំពី ទីវ មុី កាលនៅឯសហករណ៍ភូមិគរ ឃុំតាកែវ ស្រុកគ ស្ថិតក្នុងខេត្តកំពង់ចាម កាលពីជំនាន់ប៉ុលពត ជាមួយគ្នា ។ ថ្វីត្បិតតែសំណួមពរធ្វើបទសម្ភាសន៍ចំថ្ងៃទី៨ មីនា ជាទិវាសិទ្ធិនារី ដែលជាថ្ងៃឈប់សម្រាកយ៉ាងណាក៏ដោយ ក៏អ្នកមីង មាស សារិន មិនមានការថ្នាំងថ្នាក់អ្វីឡើយ ប៉ុន្តែបែរជាសម្តែងទឹកចិត្តចង់ដំណាលប្រាប់អំពីរឿងនេះយ៉ាងខ្លាំង ។ បទសម្ភាសន៍ទាំងស្រុងមានដូចតទៅ ÷

សួរ (ស)៖ អ៊ំឈ្មោះអីដែរ?

ឆ្លើយ (ឆ)៖ នៅផ្ទះគេហៅខ្ញុំ កេន ដល់ពេលឈ្មោះនៅក្នុងបញ្ជីជាតិ ឈ្មោះ មាស សារិន ។

ស៖ អ៊ំអាយុប៉ុន្មានឆ្នាំហើយឥឡូវហ្នឹង?

ឆ៖ ខ្ញុំអាយុ៦០ឆ្នាំ ខ្វះតែមួយខែទេ ។

ស៖ មុនសម័យប៉ុលពតអ៊ំនៅឯណា?

ឆ៖ នៅភ្នំពេញ ។

ស៖ សង្កាត់ប៉ុន្មាន? ហើយនៅពីឆ្នាំណាមក?

ឆ៖ ពីឆ្នាំ៥៨មកណ៎ ខ្ញុំនៅសង្កាត់ផ្សាររដេប៉ូ... ហ្នឹងដល់ពេលថ្ងៃក្រោយមកខ្ញុំលក់ផ្ទះហ្នឹង ខ្ញុំមកនៅខាងឫស្សីកែវជិតហាងសាំងរហូតដល់ឆ្នាំ១៩៧៥ ។

ស៖ អ៊ំត្រូវជាយ៉ាងម៉េចនឹង ទីវ មុី ដែរ?

ឆ៖ជីដូនមួយ...ម៉ែវានិងម៉ែខ្ញុំត្រូវជាបងប្អូនបង្កើត ពេលជម្លៀសទៅជាមួយ...មិនជាមួយគ្នាទេទៅមុនក្រោយគ្នាប៉ុន្មានថ្ងៃអ៊ីចឹងទៅ ប៉ុន្តែជួបគ្នាក្រោយមកអ៊ីចឹង ប៉ុន្តែម្តាយ ទីវ មុី ស្អប់ខ្ញុំណាស់ ។

ស៖ ហេតុអីបានស្អប់?

ឆ៖ គ្រួសារ ទីវ អុល ស្អប់ពួកខ្ញុំ ព្រោះគាត់(ម្តាយទីវអុលដែលត្រូវជាបងទីវមុី) គេនិយាយឡើងរបៀបសមមិត្តកូន មិត្តចៅហ្នឹងណ៎ គ្រួសារទីវ អុល ចូលបដិវត្តន៍ច្បាស់លាស់ យើងពួកថ្មីទៅពីភ្នំពេញ ខ្ញុំនិយាយមិនគប្បីម្តាយ ទីវ អុល ខ្លាចដាប់ខ្សែជាមួយគាត់ ខ្ញុំនិយាយអាក្រក់ៗណាស់ ខ្ញុំសំណាង ខ្ញុំមិនស្លាប់

ខ្ញុំដេរគេណា៎ ។ ខ្ញុំដេរថា «ជម្លៀសមកម៉ែវាអីរកតែស្រូវស៊ីគ្មាន រកតែអីនៅគ្មាន យើងជម្លៀស ពាក្យថាចោលផ្ទះសម្បែងណា៎» ចេះតែដេរគេអីចឹង រួចទៅគេអត់ប្រកាន់ខ្ញុំទេ ដល់តែយប់អីចឹងទៅ នាំគ្នានិយាយលេងសើចសប្បាយអីចឹងទៅ ប៉ុន្តែអ្នកស្រុក អ្នកភូមិប្រាប់ខ្ញុំ អាណិតខ្ញុំ ណែ៎រើយ! កូនច្រើនណាស់ណា៎ ប្រយ័ត្នផាប់ មួយម៉ាត់ផាប់ មួយម៉ាត់រស់ អ្នកភូមិប្រាប់ខ្ញុំថាឲ្យមើលភ្លើងទៅ ក្រោយផ្ទះយប់ៗឃើញភ្លើងភ្លឺៗអីចឹងហ្នឹងសុទ្ធតែយកមនុស្សទៅវៃចោលទាំងអស់ ។

សៈ ហេតុអ្វីបានជាអ្នកភូមិប្រាប់អ៊ំ?

ឆៈ អ្នកភូមិ អ្នកស្រុកហៅ អ្នកមូលដ្ឋាន គាត់មករករបស់របរអី ខ្ញុំចេះតែឲ្យគាត់ ។ យើងមានថ្នាំពេទ្យលួចលាក់ជាប់ទៅជាមួយអីចឹង គាត់មករកថ្នាំអីចឹង គាត់ទូន្មានយើង គាត់ជាប់ដូចរបៀបបងប្អូនខាងម្តាយទីវ ម៉ី ហ្នឹងដែរណា៎ ឃុំតាកែវ ស្រុកគរ ខេត្តកំពង់ចាម យើងហ្នឹងតំបន់ហ្នឹងខ្លាំងណាស់ប្អូនអើយ...គ្មានសល់ទេជម្លៀសទៅឲ្យកកកុញនៅក្រោមដើមឈើសុទ្ធតែលោកជំទាវ លោកស្រី ប្រពន្ធឯកឧត្តម ពូជស្តេច សូម្បីតែកូនសម្តេចទៅលើកទំនប់ទៅលើកដីមានអ្នកនៅក្នុងសហករណ៍ប្រាប់ខ្ញុំថាឃើញ...កោរសក់ ។

សៈ អ៊ំដែលជួប ទីវ អុល ទេ?

ឆៈ ពេលដែលខ្ញុំជម្លៀសពីភ្នំពេញទៅដល់ស្រុកគាត់គឺភូមិគរ គាត់ទុកសំបុត្រមួយសរសេរបិកក្រហម ។ ពេលនោះខ្ញុំពាក់កណ្តាលឆ្នាំ១៩៧៥ ។

សៈ សរសេរថាម៉េច?

ឆៈ ដាក់ឲ្យខ្ញុំថា ណែ៎ ប្តីបងឯង និងបងឯងនិយាយអីចឹងដាក់ឈ្មោះឲ្យមនុស្សមកយកតាំងពីជំនាន់គេដាច់ខេត្តមួយៗ ម៉េចក៏មិនព្រមទៅ បើចូលមកដល់ក្នុងទឹកដីនេះត្រូវតែបត់ខ្លួនទៅតាមចង្វាក់កងចក្រប្រវត្តិសាស្ត្រ ឲ្យខ្ញុំហ្នឹងលត់ដំឲ្យដូចគេ ខ្ញុំក៏លត់ដំការងារឲ្យពួកអាពតពេញចិត្តខ្ញុំ ប៉ុន្តែត្រង់ថា ការវៃចោលរបស់វារន្ធាលពេក រហូតដល់នៅសល់តែជប់គ្រួសារជាងមកវិញក្រោយរំដោះ (មួយសហករណ៍មានប្រមាណ ១០០០គ្រួសារតាមសៀវភៅភូមិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យផ្នែកនយោបាយ) ហើយកាលដែលទៅកកកុញសុទ្ធតែអ្នកថ្មីៗ ពីភូមិនេះថា ទៅនៅភូមិនោះយកទៅវៃចោល គេដាក់នៅទួលពង្រមួយ សុទ្ធតែពួកម៉ាកខ្ញុំ ប្រពន្ធសក្តិប្រាំ កូនមេស្រុកណា៎ អ្នកគ្រូអី អ្នកមានការងារអីប៉ុន្មានគេយកទៅដាក់នៅហ្នឹងម៉្តុំ នៅប្រហែលជាប្អូន-ប្រាំមួយឆ្នាំចេះតែបាត់ទៅៗ អាលីងទាំងអស់បន្ទំ បញ្ចូលក្នុងឆ្នាំដែលបញ្ជូនទៅអើយ...ទាំងឡានហ្នឹងហើយប្រពន្ធ ទីវ ម៉ី អីហ្នឹងណា៎ ប្រពន្ធ និងកូន និងម្តាយ និងឪពុក និងបងថ្លៃយកទាំងពូជយកទាំងខ្សែអស់តែម្តង ។

ក្នុងជំនាន់នោះ គាត់ជាអនុរដ្ឋមន្ត្រីក្រសួងឃោសនាការនៅភ្នំពេញ ។ ប្រពន្ធ ទីវ អុល ជាប្រធានពេទ្យរុស្ស៊ី ។ កូនរបស់ ទីវ អុល មានពីរ ខ្ញុំចង់ឲ្យគេស្រាវជ្រាវរកផង ។ កូនស្រីកាលពីតូចគេហៅ សីលា ដល់ពេលមកជម្លៀសចូលបដិវត្តន៍ប្រើមិត្ត សោម មិត្តអីចឹងទៅដូរឈ្មោះ អ៊ំអត់បានចាំច្បាស់ទេ ។ ហើយកូនប្រុសមួយទៀតឈ្មោះ បូព៌ា បើឥឡូវវាស្រករប្រហែលកូនខ្ញុំ ប្រហែលខ្ទង់៤០ឆ្នាំ ។ ប៉ុន្តែពួកសួរគេនិយាយល្បៀងៗថា នៅម៉្តុំប្រហែលជាតាកែវ ធ្វើនឹងគេ ពេល ទីវ អុល ធ្វើបដិវត្តន៍ហ្នឹង គាត់ខ្វាចអស់ខ្សែ ។

សៈ ទីវ ម៉ី មានបងប្អូនប៉ុន្មាននាក់?

ឆៈ មុនដំបូងបំផុតបងស្រីនោះឈ្មោះ បងឈុំ បងស្រីបង្អស់ណា៎ ។ ទីវ អុល រួចបងឈុំ ។ បងឈុំរួច បានទីវ អ៊ីន បន្ទាប់មកមាន ទីវ ទ្រី ជាគ្រូកីឡា មួយទៀតស្លាប់ដោយឈឺតាំងពីសង្គម ។ ទីវ ទ្រី ធ្លាប់នៅស្រុកក្រៅទៅប្រទេសឆេកូ ។ បន្ទាប់មកបាន ទីវ សន្តិភាព (ទីវ ម៉ី) បន្ទាប់មកទៀតគឺ ទីវ អោក រួច ទីវ សន្តិវី ប្រុស ។ ខ្ញុំពួកគេនិយាយប្រាប់ខ្ញុំ ទីវ សន្តិវី ប្អូនពៅហ្នឹងជំនាន់នោះធ្វើគណៈស្រុកនៅថ្មស ចិត្តល្អ អត់ធ្វើបាបប្រជាជនទេ គ្រាន់តែថា តាមកងចក្ររបស់គេប៉ុន្តែអត់ចេះសម្លាប់គេទេ ដល់ទៅនៅគេហ្នឹង ប្រជាជនគេស្រឡាញ់ដល់វៀតណាមចូល នេះថាពួកសួរអារកផាងគ្នោតអីនោះ ទីវ សន្តិវី រត់ទៅមិនដឹងចូលព្រៃផាប់ក៏មិនដឹង នៅរស់ក៏មិនដឹង បាត់សូន្យតែម្តងណា៎ អត់ពួ សួរអីសោះអីចេះ ចំណែកបងប្អូនទាំងអស់ស្លាត់ឈឹង ស្លាត់ទាំងអស់ ។ ខ្ញុំឆ្ងល់យកតាំងពីសាច់ថ្លៃបងស្រីបងឈុំហ្នឹង ក៏យកប្តីគាត់ទៅដែរ មានក្មួយនៅជាមួយក៏ផាប់ដែរ ឈ្នួលក៏យកទៅផាប់ដែរ យកទៅទាំងអស់ ទាំងពូជទាំងខ្សែ

ថាចុះតែផ្ទះទទេ អ៊ីចឹងហួស ប៉ុន្តែខ្ញុំដឹងថា ពួកហ្នឹងស្លាប់នៅម្តុំ បើមិនភ្នំប្រុសភ្នំស្រីហ្នឹងទេ ម្តុំគេហៅថា ព្រៃកុងយើងស្គាល់ហ្នឹង ណា៎គឺមានតែពីរហ្នឹងទេ ខ្ញុំដឹងច្បាស់មកពីខ្ញុំមានការរាប់អានហើយ ល្បួងសួរប្រជាជន ហ្នឹងស្និទ្ធទៅនឹងកូនប្រជាជនហ្នឹងគេធ្វើការជាមួយយោធាណា៎ ធ្វើយោធាអាពតហ្នឹងគេ...គេនាំខ្សែឡានហ្នឹងទៅ ទៅដាក់ត្រង់ណោះ ទៅដាក់ត្រង់ណោះ ។

សៈ ចុះ ទីវ ម៉ី ហ្នឹងអ៊ំស្គាល់ច្បាស់ធ្លាប់ទៅនៅជាមួយគ្នាអី..?

ឆៈ ចាស៎ ពេលចាប់ទីវម៉ីគឺចាប់នៅមុខខ្ញុំតែម្តង អូនឯងគួរព្រឺក្បាលណា៎ ម៉ីថាអ្ហីនៃខ្ញុំទៅយកស្លឹកទៅត្រាំនៅស្ទឹង (នៅភូមិគរ) ។ នៅភូមិគរហ្នឹង នៅមុខផ្ទះហ្នឹងចាំស្តាប់ខ្ញុំនិយាយណា៎ ទីវ ម៉ី ទៅសុំរទេះគេបានមកអ៊ីចឹងលើកស្លឹកទើបបានមួយកងដាក់ ខ្ញុំក៏ដាក់មួយកងដែរ ខ្ញុំថា «អឺម៉ីឯងដាក់ខាងណោះ អញ៉ដាក់ខាងណោះដាក់ទៅ អញ៉ធ្វើយកទៅដែរ» ។ ខ្ញុំក៏ទៅត្រាំនឹងគេដែរ ត្រាំស្លឹកយកប្រក់ខ្ទមយើងនៅផ្ទេរស្លឹកហ្នឹងរួច ទៅនោះទើបតែបានមួយកងម្នាក់យកទៅដាក់លើស្លឹកហ្នឹងទទួលអាប្រធានភូមិឈ្មោះមិត្តតែម ហ្នឹងមកហួស (ហ្នឹងស្លាប់ហើយ) ។ បន្ទាប់ពីមិត្ត តែមយកមិត្តម៉ីទៅអ៊ីចឹង ខ្ញុំខំធ្វើការដឹងខ្លួនថាគេសម្លាប់ បើអ៊ីចឹងខំធ្វើការ បន្តិចអ៊ំ បើប្រុសឥតដូរទេណា៎ ខ្ញុំគិតថា បើស្លាប់នឹងរែកដីល្អជាងស្លាប់ហ្នឹងគេ សម្លាប់ណា៎ ខ្ញុំរែកឲ្យណាណីនិយាយពីអ្នកភូមិហ្នឹងដែលគេហៅថា អ្នកមូលដ្ឋានចាស់គេស្រឡាញ់ខ្ញុំថា ខ្ញុំអត់ទុនទំនុក ត្រង់ថា ពេលមានប្រជុំ ខ្ញុំទៅដល់មុនគេថារែកដីរែកពេញកម្លាំងដូចប្រុស បើស្លាប់ៗនឹងរែកដីចុះ អ៊ីចឹងអត់ទេលែងគិតកូន ខំធ្វើការវាពេញចិត្តខ្ញុំ ។

សៈ អ៊ំអាចប្រាប់ឲ្យបានលម្អិត ពេលព្រឹត្តិការណ៍មិត្តតែមចាប់



វិធីបង្សុកូលនៅសារមន្ទីរទួលស្លែងដល់ជនរងគ្រោះក្រោមរបបខ្មែរក្រហម

យកទៅហ្នឹងយ៉ាងម៉េចដែរ?

ឆៈ ពេលចាប់ទីវ ម៉ី យកទៅដល់ក្លាមហ្នឹង វាថាឈប់សិនខ្ញុំចូលផ្ទះមួយភ្លែត ចូលទៅក្នុងផ្ទះប្រាប់ប្រពន្ធកូនក្លាម មុខស្លាំងអូនអ្ហើយ ស្លាំងគ្មានឈាមទេ គេដឹងខ្លួនគេណា៎...យកទៅដាក់ក្នុងសាលាសន្តិសុខ កន្លែងសួរចម្លើយធំ ទុកមួយយប់អញ្ចឹង

ល្ងាចបន្តិច គេដឹករ៉ឺម៉កយកចេញពីភូមិគរ ប៉ុន្តែយើងអត់ដឹងថា យកមកទួលស្លែងទេពេលហ្នឹង គ្រាន់តែដឹងថា ដឹកចេញ ។ យើងមើលឃើញតែពេលដឹកចេញមកចេះតែស្រែកថា បងប្អូនអើយ ជួយខ្ញុំផងខ្ញុំអាម៉ីណា ខ្ញុំអាម៉ី កូនអ៊ឹមឃីម ខ្ញុំអាម៉ី កូនអ៊ឹមឃីម ជួយខ្ញុំផង! ខ្ញុំអត់មានខុសអីទេ ជួយខ្ញុំផង ខ្ញុំអាម៉ី លោកអើយជួយខ្ញុំផង ប្រាប់ឪម៉ែខ្ញុំផងគេចាប់ខ្ញុំហើយ ស្រែកអញ្ចឹងខ្លាំងពេក អ្នកស្រុកមកប្រាប់នៅតែមានខ្សឹបខ្សៀវគ្នាអីចឹងថា អួយគេចាប់អាម៉ីយកទៅហើយ អាម៉ីយំស្រែកស្ទើរធ្លាក់ពីលើរ៉ឺម៉កឯណោះ វាស្រឡាញ់កូនវាណាស់ណា ។

សៈ ហើយអ៊ំមានបានឃើញគេពេលដឹកហ្នឹងទេ?

ឆៈ ពេលហ្នឹងខ្ញុំអត់មានបានទៅឈរមើលទេអូន រួញដូចនេះអីចឹង ចំណែកប្អូនខ្ញុំបង្កើតគេយកទៅវាយបាក់ឆ្អឹង ហើយឆ្អឹងជំនីណា វាដាក់នៅឲ្យដេកក្រោមគ្រែវា ហើយវានោមដាក់លើក្បាលប្អូនខ្ញុំទៀត អត់មានកំហុស ។

សៈ ពេលគេមកដល់ចាប់ ទីវ ម៉ី ហ្នឹងអ៊ំនៅជាមួយ? ហើយគេមកតាមមានថាម៉េចទេ គេចោទថាម៉េចទេ?

ឆៈ ចាំស្តាប់ លើកស្លឹកដាក់លើរទេះហើយ គេថាអី..មិត្តម៉ីអា្អ! អន្តការស្នើទៅប្រជុំមួយភ្លែត ប៉ុន្តែវា១ដឹងខ្លួនវា ខ្ញុំអត់ដឹងទេ ខ្ញុំបកក្បាលក្អឹងមកវិញថាមកប្រាប់គ្នាយើង ហើយម្តាយ ទីវ ម៉ី ស្ទេកស្ទាំងទាំងអស់ រួញទាំងអស់នៅក្នុងផ្ទះអត់ហ៊ានស្រែកយំទេ ហ៊ានតែអ្នកណាយំ យកអ្នកហ្នឹងទៀត ហ៊ានតែយកប្តី ប្រពន្ធយំថាសុំទៅជាមួយប្តី យកទៅសម្លាប់ទាំងអស់ អូនឯងសួរទៅគ្រប់មនុស្ស ម្លោះហើយរួញតែម្តង ប្អូនខ្ញុំគេបាក់ដៃហ្នឹងណា ដែលខ្ញុំនិយាយហ្នឹងណាឲ្យវែកដីឲ្យបាន វែកឲ្យរួច ហើយវាថាស្អែកឲ្យទៅសមរភូមិមុខជាមួយចល័ត...ស្អីគេហៅថាស្រួចនោះណាឈានមុខឲ្យទៅគ្នាអរចង់ឆាប់យប់ហ្នឹងវាយកទៅសម្លាប់ចោល គិតមើល ។

សៈ អ៊ំអញ្ចឹង ទីវ ម៉ី គេឈ្មោះ សន្តិភាព តាំងពីសង្គមមុនមក?

ឆៈ តាំងពីសង្គមចាស់ តាំងពីនៅរៀននៅភ្នំពេញអីនៅកំពង់ត្រាំដល់ដាច់កំពង់ត្រាំហ្នឹង គ្នាចេះតែរត់១មកនៅភ្នំពេញ ខ្ញុំចេះតែមិនដែលជួប ។

សៈ អញ្ចឹងយ៉ាងម៉េចតទៅទៀត?

ឆៈ ដល់ដាច់ទៅទៅជុំគ្នាហ្នឹង

សៈ ជុំគ្នាហ្នឹង? អញ្ចឹងគាត់អ្នកថ្មីដែរ?

ឆៈ អ្នកថ្មី ។

សៈ ហើយ ទីវ អុល ចូលបំរើបដិវត្តន៍យូរហើយ?

ឆៈ តែបដិវត្តន៍ហ្នឹងបើតាមខ្ញុំស្មានមើលណា គាត់មិនក្រហមប្រាលទេ គាត់ត្រឹមតែផ្កាឈូកទេ ព្រោះគាត់អ្នកភ្នំពេញតាំងពីអើយនៅបង្រៀននៅហ្នឹងមកណោះ ។ **(នៅមានត)**

## លិខិតស្វែងរកឪពុកម្តាយ និងបងប្អូន

នាងខ្ញុំឈ្មោះ ចាន់ នី មានបំណងស្វែងរកឪពុកម្តាយ បងប្អូន ដែលមានឈ្មោះដូចខាងក្រោមៈ

១-លោកឪពុកឈ្មោះ ទឹម

២-អ្នកម្តាយឈ្មោះ ខុម

៣-បងស្រីឈ្មោះ ខឿន

៤-បងស្រីឈ្មោះ ខា

៥-ប្អូនប្រុសឈ្មោះ និត

៦-ប្អូនស្រីឈ្មោះ ណាក់

ក្នុងរបបខ្មែរក្រហម ក្រុមគ្រួសារ នាងខ្ញុំប្រហែលជារស់នៅក្នុងខេត្តពោធិសាត់ ឬបាត់ដំបង ។

នាឆ្នាំ១៩៧៩ (នាងខ្ញុំអាយុប្រហែល ៥ ឬ៦ឆ្នាំ) ពេលប្រទេសជាតិត្រូវបានរំដោះ ក្រុមគ្រួសាររបស់នាងខ្ញុំ បានធ្វើដំណើរចាកចេញពីទីនោះឆ្ពោះមកកាន់ស្រុកកំណើត ។ ក្នុងដំណើរតាមផ្លូវ (ប្រហែលជានៅក្បែរស្ទឹងពោធិសាត់) នាងខ្ញុំបានបែកវង្វេងពីក្រុមគ្រួសារ ហើយក៏បែកគ្នារហូតមកទល់សព្វថ្ងៃនេះ ។

សូមទំនាក់ទំនង និងការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ឬទូរស័ព្ទលេខ ០១២ ៨១៦ ៥២២ ។

# លិខិតស្វែងរកដំណឹងអំពីឪពុកដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម

***ព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ (តាមប្រព័ន្ធអ៊ិនធឺណែត)***

គោរពជូនលោក ឆាំង យុ

ខ្ញុំបាទឈ្មោះ ទូច វណ្ណារិទ្ធ ជាកូនប្រុសរបស់ ទូច ខាំឌឿន ដែលជាអតីតអ្នកការទូតម្នាក់ ។ ឪពុករបស់ខ្ញុំកើត នៅថ្ងៃទី១៩ ឆ្នាំ១៩៣៥ នៅខេត្តកំពង់ធំ ។ គាត់ជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំនៅប្រទេសគុយបា ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧២ ហើយប្រចាំនៅប្រទេសចិនពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ ។ ម្តាយរបស់ខ្ញុំឈ្មោះ នូ វណ្ណា កើតនៅឆ្នាំ១៩៣៧ នៅក្រុងភ្នំពេញ ។ ទាំងម្តាយ និងឪពុករបស់ខ្ញុំរៀននៅក្រុងប៉ារីស ប្រទេសបារាំង ។ គ្រួសារខ្ញុំទាំងមូលត្រឡប់មកប្រទេសកម្ពុជាវិញ នៅឆ្នាំ១៩៧៥ ។ គ្រួសាររបស់ខ្ញុំបានស្លាប់ទាំងអស់នៅសល់តែខ្ញុំម្នាក់គត់ ។ ឪពុកម្តាយរបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួន ហើយសម្លាប់នៅគុកទួលស្លែង ។ ខ្ញុំបានដឹងពត៌មានតែប៉ុណ្ណេះ ។ ខ្ញុំចង់ដឹងថាតើមជ្ឈមណ្ឌលឯកសាររបស់លោកមានឯកសារណាមួយ ឬពត៌មានបន្ថែមទាក់ទងទៅនឹងឪពុកម្តាយរបស់ខ្ញុំ ឧទាហរណ៍ ថ្ងៃចាប់ខ្លួនឪពុកម្តាយរបស់ខ្ញុំលេខបន្ទប់ក្នុងគុក ថ្ងៃសម្លាប់ ជាពិសេសចម្លើយសារភាពរបស់ឪពុកម្តាយខ្ញុំជាដើម ។ល ។ ប្រសិនបើមានខ្ញុំសុំថតចម្លងមួយច្បាប់ ហើយប្រសិនបើលោកអនុញ្ញាតខ្ញុំសុំទៅទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមានបំណងធំបំផុតទៀត គឺសូមឲ្យលោកមេត្តាចុះផ្សាយពត៌មានទាក់ទងនឹងឪពុកម្តាយរបស់ខ្ញុំនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» លេខក្រោយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាផង ។ ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនដ៏ច្រើនជាអនេកប្បការ ។ **អំពីខ្ញុំ វណ្ណារិទ្ធ**

---

មកដល់វណ្ណារិទ្ធ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាយើងខ្ញុំមានឯកសារឪពុករបស់លោក ។ ខ្ញុំមានការសោកស្តាយ និងសូមចូលរួមរំលែកទុក្ខរបស់ក្រុមគ្រួសាររបស់លោក ។ សូមលោកមេត្តាអញ្ជើញមកយកឯកសារនៅវេលាល្ងាចថ្ងៃដដែលនេះតាមការគួរ ។

ដោយក្តីរាប់អានអំពីខ្ញុំ ។ **ឆាំង យុ**

---

***រសៀលថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០***

គោរពជូនលោក ឆាំង យុ

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងដ៏ធំធេងរបស់លោកក្នុងការជួយជនរងគ្រោះកម្ពុជាតាមរយៈទស្សនាវដ្តី «ស្វែងរកការពិត» និងជាពិសេសបំផុតគឺឯកសារដ៏មានតម្លៃបំផុតដែលលោកបានផ្ញើមកឲ្យខ្ញុំនៅល្ងាចមិញនេះ ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដែលខ្ញុំព្យាយាមរកឯកសារដែលពាក់ព័ន្ធទៅនឹងឪពុកម្តាយរបស់ខ្ញុំ ។ តាមពិតខ្ញុំធ្លាប់ផ្ញើការឲ្យអង្គការគណៈកម្មការកាកបាទក្រហមអន្តរជាតិ ដែលមានការិយាល័យស្រាវជ្រាវមួយនៅចន្លោះឆ្នាំ១៩៩៣ និង១៩៩៥ ហើយនៅពេលនោះខ្ញុំអាចទទួលបានតែពត៌មានថា ឪពុកម្តាយខ្ញុំត្រូវបានពួកខ្មែរក្រហមចាប់ដាក់គុកនៅមន្ទីរស-២១តែប៉ុណ្ណោះ ។ ខ្ញុំក៏ធ្លាប់បានព្យាយាមរករូបថតរបស់ឪពុកម្តាយខ្ញុំ និងពត៌មានដទៃទៀតដែលអាចមាននៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងជាច្រើនលើកច្រើនសារួចមកហើយ ក៏ប៉ុន្តែជាអកុសល ខ្ញុំពុំដែលរកឃើញនូវរូបថត ឬពត៌មានបែបនេះទេ ។ ២៣ឆ្នាំបានកន្លងផុតទៅហើយ ទើបតែថ្ងៃនេះខ្ញុំបានទទួលពត៌មានដ៏មានតម្លៃទាំងនេះតាមរយៈជំនួយការដ៏មានសមត្ថភាពរបស់លោក ។

ជាថ្មីម្តងទៀត ខ្ញុំសូមអរគុណលោកនិងសហការីរបស់លោកដែលបានជួយខ្ញុំដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ ហើយសង្ឃឹមថាមជ្ឈមណ្ឌលឯកសារកម្ពុជានឹងទទួលបានជោគជ័យក្នុងការស្វែងរកការពិតសម្រាប់ជនរងគ្រោះកម្ពុជាទាំងអស់ ហើយនិងសម្រាប់ប្រជាជនកម្ពុជាជំនាន់ក្រោយឲ្យបានដឹងនូវអ្វីៗដែលបានកើតឡើងនៅកម្ពុជាក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ មានមិត្តភក្តិខ្ញុំជាច្រើនដែលបានបាត់បង់គ្រួសារក្នុងរបបខ្មែរក្រហម ក៏ប៉ុន្តែមិត្តភក្តិរបស់ខ្ញុំទាំងនោះពុំដឹងថា ត្រូវធ្វើយ៉ាងដូចម្តេចទើបអាចរកពត៌មានទាំងនេះបាន ។ ជាពិសេសមិត្តរបស់ខ្ញុំម្នាក់ឈ្មោះ សៀន សីលា ដែលជាកូនប្រុសរបស់ឯកអគ្គរដ្ឋទូតកម្ពុជា ប្រចាំនៅប្រទេសវៀតណាម គឺឯកអគ្គរដ្ឋទូត សៀន អាន ។ ភរិយារបស់លោកឯកអគ្គរដ្ឋទូត សៀន អាន ត្រូវបាននិយាយជាច្រើនលើកនៅក្នុងឯកសារចម្លើយសារភាពរបស់ឪពុកម្តាយរបស់ខ្ញុំជូនអង្គការដែរ ។ មិត្តរបស់ខ្ញុំម្នាក់នេះប្រាកដជាចង់ដឹងខ្លាំង អំពីអ្វីដែលបានកើតឡើងចំពោះឪពុកម្តាយរបស់គាត់នៅមន្ទីរស-២១ ។ សូមលោកមេត្តាអនុញ្ញាតឲ្យខ្ញុំបានដឹងផងនៅពេលណាដែលលោកអាចរករូបថតឪពុកម្តាយខ្ញុំឃើញ ។ ដោយសេចក្តីដឹងគុណជាអនេកប្បការ ។ **អំពីខ្ញុំ វណ្ណារិទ្ធ**

# គ្រួសាររបស់ខ្ញុំក្រោមរបប ប៉ុល ពត

**(តពីលេខមុន)** ប្អូនប្រុសពៅរបស់ខ្ញុំដែលជាអាកាសយានិករបបខ្មែរសាធារណរដ្ឋបានស្លាប់ក្នុងការបើកយន្តហោះទៅទម្លាក់គ្រាប់បែកនៅសមរភូមិវិហារសួគ៌ ក្នុងឆ្នាំ១៩៧៤ ។ ឪពុកមារបស់ខ្ញុំធ្លាប់បានដាស់តឿនគាត់ថា «តើបងឯងនឹងទទួលបានអ្វីពីពួកខ្មែរក្រហម នៅពេលដែលវាឈ្នះសង្គ្រាមបានជាបងឯងគាំទ្រពួកវា» ។ ចាប់ផ្តើមពីពេលនោះមកគ្រួសាររបស់ខ្ញុំបានផ្ទុកនូវការឈឺចាប់និរាសព្រាត់ប្រាសកាន់តែធ្ងន់ធ្ងរទៅៗ ពោលគឺមានតែខ្ញុំនិងម៉ាក់ខ្ញុំប៉ុណ្ណោះដែលនៅជុំគ្នា ចំណែកឯបងប្រុសខ្ញុំវិញ គឺបាត់ឈឹងរហូត ដោយមិនដឹងថាតើនៅទីណា ស្លាប់ឬរស់ក៏មិនដឹងទាល់តែសោះរហូតដល់សព្វថ្ងៃនេះក្នុងមួយពព្រិចភ្នែក ម្តាយខ្ញុំបាត់បង់ប្តី និងកូនពីរនាក់ទៀត ។ នៅពេលយប់មួយនោះ ម៉ាក់ខ្ញុំនិងខ្ញុំ ត្រូវបានឈ្លបភូមិហៅឲ្យទៅកាន់សាលាស្រុក ដើម្បីរើទៅនៅកន្លែងថ្មី ប៉ុន្តែពួកវាបានប្រាប់ថាមិនបាច់យកឥវ៉ាន់អីទៅច្រើនពេកទេ ព្រោះមានអ្នករៀបចំឲ្យអស់ហើយ ។ យប់នោះម៉ាក់ខ្ញុំនិងខ្ញុំត្រូវបានដាក់តាមរទេះគោមួយ ឆ្ពោះទៅកាន់សាលាស្រុក ដោយយប់ងងឹត ហើយខ្ញុំនៅតូចផងនោះ ខ្ញុំមិនអាចចាំបានថាគេដឹកទៅតាមផ្លូវណាទេ ។ ពេលទៅដល់មន្ទីរស្រុកមានមនុស្សប្រុសម្នាក់ប្រាប់ម៉ាក់ខ្ញុំថា «មីងឯងនៅសម្រាកទីនេះមួយយប់សិនទៅ! ចាំជិតភ្លឺមានគេមកយកមីងឯងទៅហើយ» ។ ព្រឹកឡើងនៅក្នុងសាលាស្រុកនោះទាំងមូលគ្មានមនុស្សណាក្រៅតែអំពីម៉ាក់ខ្ញុំ, ខ្ញុំ ព្រមទាំងពួកខ្មែរក្រហម៣-៤នាក់តែប៉ុណ្ណោះ ។ ហើយទន្ទឹមនឹងគ្នានោះដែរ អាម្នាក់រាងចំណាស់ជាងគេបន្តិចបានដើរតម្រង់មករក ម៉ាក់ខ្ញុំ ហើយនិងខ្ញុំរួចនិយាយដោយសម្តីដាច់ៗថា «ទៅភូមិវិញទៅ! គេរវល់ណាស់គ្មានអ្នកណាមកយកទេ ចាំថ្ងៃក្រោយទៅ ។ បន្ទាប់ពីវានិយាយចប់ ម៉ាក់ខ្ញុំ និងខ្ញុំបានលាវាចេញពីសាលាស្រុកនោះមកដោយថ្មើរជើង តាំងពីព្រឹករហូតដល់យប់ងងឹតទើបយើងមកដល់ភូមិវិញ ។ ពេញមួយយប់ម៉ាក់ខ្ញុំមិនគេងទាល់តែសោះ គាត់នៅតែអង្គុយបញ្ឈរក្បាលជង្គង់តែម្នាក់ឯងក្នុងរោងរនាបឫស្សី ។ លុះព្រឹកឡើងគាត់បានលីចបកាប់មួយ និងកាន់កាំបិតផ្គាក់មួយទៅធ្វើចម្ការ ហើយព្រមនិយាយផ្តាំខ្ញុំថា «ពេលបើកបបរ កូនបើករបបម៉ាក់ហូបទៅ! ពេលល្ងាចបានម៉ាក់ត្រឡប់មកផ្ទះ» ។ លុះដល់ពេលល្ងាចពេលម៉ាក់ខ្ញុំត្រឡប់មកវិញ ខ្ញុំឃើញទឹកមុខគាត់ស្រពាប់ស្រពោនយ៉ាងខ្លាំង ហើយមិននិយាយ



អ្នកយាមគុកទួលស្លែង

មួយម៉ាត់ណាទាល់តែសោះ ។ ខ្ញុំឃើញគាត់មានអង្ករប្រហែលជាពីរ-បីកំប៉ុងយកមកដាំបាយ ។ ក្រោយពេលបាយឆ្អិនគាត់បានហៅខ្ញុំមកហូបបាយជាមួយគាត់ នៅពេលកំពុងហូបម៉ាក់ខ្ញុំសម្លឹងមើលមុខខ្ញុំជាញឹកញាប់ រំពេចនោះមានឈ្លបភូមិម្នាក់បានមកហៅម៉ាក់ខ្ញុំឲ្យទៅប្រជុំនៅមន្ទីរភូមិ ។ ពេលនោះម៉ាក់ខ្ញុំគាត់បានប្រាប់ខ្ញុំថា «ពេលហូបបាយហើយ គេងទៅបន្តិចទៀតម៉ាក់មកវិញហើយ» ។ អស់រយៈពេលមួយយប់ដែលខ្ញុំបានរង់ចាំម៉ាក់ខ្ញុំវិលត្រឡប់មកវិញ ។ ខ្ញុំហាក់ដូចជាគ្មានវិញ្ញាណក្នុងខ្លួនបន្តិចណាទាល់តែសោះ ខ្ញុំគិតថា ម៉ាក់ខ្ញុំប្រាកដជាត្រូវពួកវាយកទៅសម្លាប់ ។ លុះព្រឹកឡើងខ្ញុំបានរត់ទៅផ្ទះប្រធានភូមិដើម្បីសាកសួរអំពីរឿងម៉ាក់របស់ខ្ញុំ ។ ពេលនោះប្រធានភូមិគាត់បាននិយាយថាៈ ម៉ែអ្អែង គេយកទៅឃុំ នៅទួលគោគគ «បើអ្អែងចង់ជួប អ្អែងទៅសួរគេនៅទីនោះទៅដឹងហើយ ។ ទួលគោគគគឺជាទួលមួយដែលមានស្ទឹងព័ទ្ធជុំវិញ សម្រាប់ដាក់ឃុំស្ត្រីវ័យកណ្តាលណាដែលធ្វើខុសនឹងបទបញ្ជារបស់ពួកវាដូចជាម៉ាក់របស់ខ្ញុំ ។ វាចោទថាម៉ាក់ខ្ញុំ និងអ្នកដែលនៅទីនោះ គឺជាអ្នកលួចជីកដំឡូង លួចបូតស្រូវ នៅមានសតិអារម្មណ៍សង្គមចាស់ច្រើន ជាពិសេសមានជាប់ពាក់ព័ន្ធជាមួយប្តី ។ ខ្ញុំត្រូវស្ថិតក្នុងវាលល្ហល្ហេវដ៏ធំធេងមួយតែម្នាក់ឯង ។ មួយសប្តាហ៍ក្រោយមកទើបខ្ញុំបានទទួលដំណឹងពីម៉ាក់ខ្ញុំតាមរយៈអ្នកនៅក្បែរខ្ញុំមកប្រាប់ថាម៉ាក់របស់ខ្ញុំមិនទាន់ស្លាប់ទេ ហើយពេលនេះគាត់ចង់ជួបមុខខ្ញុំណាស់ ។ ពីកន្លែងដែលខ្ញុំនៅទៅកន្លែងដែលគេឃុំម៉ាក់របស់ខ្ញុំត្រូវចំណាយពេលជាងកន្លះថ្ងៃទើបទៅដល់ទីនោះ ។ ពេលទៅដល់ទីនោះខ្ញុំត្រូវហែលឆ្លងទឹកស្ទឹងទើបអាចទៅដល់ទួលគោគគបាន ។ ស្ត្រីចំណាស់រាប់រយនាក់នៅទីនោះ ខ្លះកាប់ឆ្ការព្រៃ ខ្លះគាស់គល់ឈើ ខ្លះដញ្ជូនមែកឈើដុត ក្រៅតែពីស្នូរកាប់គាស់ឈើ គឺពុំមានសម្លេងមាត់មនុស្សនិយាយគ្នាទេ ។ ខណៈនោះខ្ញុំខំសម្លឹងរកម៉ាក់របស់ខ្ញុំយ៉ាងហ្មត់ចត់បំផុត អស់រយៈពេលប្រហែលជិតមួយម៉ោងក្នុងការរកម៉ាក់ខ្ញុំ ពុំបានទទួលលទ្ធផលអ្វីសោះ ។ ក្តីអស់សង្ឃឹមនិងភាពវិលវល់បានកំពុងស្ថិតក្នុងខ្លួនខ្ញុំ ពេលនោះខ្ញុំរត់ជុំ យំជុំ ស្ទើរតែពេញមួយទួលនោះទៅហើយ តែថៃជន្យអ្វីខ្ញុំបានជួបនឹងស្ត្រីចំណាស់ម្នាក់ដែលមានអាយុស្រករនឹងម៉ាក់របស់ខ្ញុំ កំពុងតែអង្គុយក្រោមដើមឈើធំមួយក្បែរផ្លូវ គាត់សួរមកខ្ញុំថា «រត់ទៅណាហ្នឹងកូន? រកអ្នកណាឬ?» ខ្ញុំឆ្លើយតបទៅគាត់វិញថា «រកម៉ាក់របស់ខ្ញុំអ៊ំ» ហើយគាត់ក៏សួរមកវិញថា «ម៉ាក់កូនឈ្មោះអី? មកពីភូមិណា?» ក្រោយពីខ្ញុំបានប្រាប់ឈ្មោះនិងភិនភាគរបស់ម៉ាក់ខ្ញុំទៅគាត់រួចមក ខ្ញុំក៏បានដឹងថាម៉ាក់ខ្ញុំត្រូវបានពួកខ្មែរក្រហមចាប់បញ្ជូនទៅកាន់ការដ្ឋានជីកប្រឡាយវិញតាំងតែពីម្សិលមិញម្ល៉េះ ។ បានដឹងដំណឹងនេះភ្លាមខ្ញុំហាក់ដូចជាបានធូរស្បើយក្នុងចិត្តបន្តិច ខ្ញុំក៏ធ្វើដំណើរត្រឡប់មកភូមិវិញ ។

## ៤-ការគេចខ្លួនដើម្បីជីវិតរស់

ក្នុងភាពជាកុមារដែលត្រូវតែបានទទួលនូវការថ្នាក់ថ្នមនិងការមើលថែទាំចិញ្ចឹមបីបាច់យ៉ាងកក់ក្តៅបំផុតពីឪពុកម្តាយនោះ ត្រូវបានរលាយបាត់បង់អស់ ។ ខ្ញុំត្រូវរស់នៅតែម្នាក់ឯងក្នុងខ្ទមស្លឹកត្នោតមួយក្បែរជើងភ្នំ ។ ខ្ញុំចេះតែគិតក្នុងចិត្តថាតើខ្ញុំនឹងមានជីវិតរស់នៅរហូតដល់ត្រឹមណា? តើខ្ញុំត្រូវរស់តាមរបៀបនេះរហូតឬ? ថ្ងៃមួយ នៅពេលដែលខ្ញុំកំពុងតែដើរមកពីកាប់ដើមទន្រ្ទានខេត្រនិងកើបលាមកគោធ្វើជីវិញ ក៏មានស្ត្រីចំណាស់ម្នាក់ដែលជាអ្នកមូលដ្ឋានបានប្រាប់ខ្ញុំថាគាត់បានជួបនឹងម៉ាក់របស់ខ្ញុំនៅឯការដ្ឋានទំនប់មួយនៅខាងកើតភ្នំឯណោះ ប៉ុន្តែគាត់មិនបានប្រាប់ថានៅទីនោះឈ្មោះអ្វីទេ គឺគ្រាន់តែប្រាប់ថាដើរឆ្ពោះទៅទិសខាងកើតទៅនឹងជួបហើយ ។

បន្ទាប់ពីបានទទួលដំណឹងនេះ ព្រលឹមឡើងខ្ញុំក៏បានធ្វើដំណើរទៅតាមទិសដូចដែលគេបានប្រាប់ខ្ញុំ ។ អស់រយៈពេលពេញមួយថ្ងៃខ្ញុំក៏បានទៅដល់ការដ្ឋាននោះ ទីនោះមានមនុស្សប្រុស-ស្រីវ័យកណ្តាលរាប់រយនាក់ និងមានសង់រោងមួយយ៉ាងវែងលើខ្នងទំនប់មួយខ្ពស់ ។ ក្នុងរោងនោះមនុស្សទាំងអស់ត្រូវសម្រាកជាពីរជួរ គឺយកក្បាលទល់គ្នា ហើយជើងត្រូវដាក់ចេញមកក្រៅតាមសំយាបរោង ពីសំយាបរោងមកដីមានកម្ពស់ប្រហែលជាង៣តឹក អ្នកដែលចូលទៅសម្រាកក្នុងរោងគឺត្រូវតែលូនទើបអាចចូលបាន ។ អស់ពេលជាច្រើនម៉ោងខ្ញុំត្រូវដើរទិនៗតាំងពីដើមរោងរហូតដល់ចុងរោងដើម្បីរកមើលមុខម៉ាក់ខ្ញុំ ខ្ញុំមានអារម្មណ៍ហាក់ដូចជាបានឃើញចុងជើងមួយ

គូដែលលេចចេញមកក្រៅមានលក្ខណៈដូចគ្នាបេះបិទទៅនឹងជើងរបស់ម៉ាក់ខ្ញុំ ។ ពេលនោះខ្ញុំបានដើរតម្រង់ទៅរូបភាពនោះ ហើយក៏ឱនមើល ។ អ្វីដែលខ្ញុំបានគិតនោះ គឺជាការពិតណាស់ ម៉ាក់ខ្ញុំបានកំពុងអង្គុយសណ្ដូកជើងប៉ះសម្លៀកបំពាក់ ។ ខ្ញុំស្រែកហៅ ម៉ាក់! ម៉ាក់! ម៉ាក់! ម៉ាក់ក៏ងើបមុខឡើង នៅពេលដែលម៉ាក់បានឃើញខ្ញុំភ្លាមទឹកភ្នែករបស់គាត់ក៏ហូរភ្លាម ដៃរបស់គាត់ម្ខាងបានឱបខ្ញុំជាប់ ហើយដៃម្ខាងទៀតអង្អែលក្បាលខ្ញុំ ។ ក្នុងយប់នោះម៉ាក់របស់ខ្ញុំបានសុំប្រធានកងចល័តឲ្យខ្ញុំបានសម្រាកនៅទីនោះជាមួយគាត់ពេញមួយយប់ ។ ក៏ប៉ុន្តែអ្វីដែលឈឺចាប់និងសោកសង្រេងនោះគឺការដែលបានឮសម្ដីរបស់ម្ដាយនិយាយថា «ចាប់ពីពេលនេះទៅកូននឹងមានការលំបាកក្នុងការមករកម៉ាក់! យើងនឹងត្រូវបែកគ្នាដោយពុំដឹងថា តើពេលណាយើងនឹងបានជួបគ្នាទេ» ។ រាល់សម្ដីដែលម៉ាក់បាននិយាយមកកាន់ខ្ញុំ គឺគាត់បានណែនាំកុំឲ្យខ្ញុំចង់នៅជាមួយគាត់ ។ ខ្ញុំបានសួរគាត់ទៀតថា ហេតុអ្វីបានជាខ្ញុំពុំអាចនៅក្នុងកងចល័តនេះជាមួយគាត់បាន? ម៉ាក់ពុំបានឆ្លើយនឹងសំណួររបស់ខ្ញុំទេ ។ គាត់បង្ហូរទឹកភ្នែករហូត ហើយអ្វីដែលគាត់និយាយគឺមានតែឲ្យខ្ញុំរត់ចេញពីភូមិនោះទៅទីណាក៏បានដែរ មិនបាច់គិតដល់គាត់ទេ ព្រោះគាត់អាចជួយខ្លួនឯងបានហើយ ។ ក្នុងខណៈនោះរូបខ្ញុំគិតអ្វីមិនចេញសោះក្រៅតែពីយំឱបម៉ាក់របស់ខ្ញុំឲ្យគាត់សុំគេឲ្យរូបខ្ញុំបាននៅជួបជុំជាមួយគាត់ដែរ ។ ពេញមួយយប់នោះខ្ញុំយំឱបម៉ាក់របស់ខ្ញុំរហូតដល់គេងលក់ដោយពុំដឹងខ្លួន ។ លុះព្រលឹមស្រាងៗឡើងសម្លេងកញ្ចែបានផ្លុំឡើងកងរំពងដើម្បីដាស់ឲ្យអ្នកដែលនៅក្នុងរោងត្រូវតែចេញទៅធ្វើការរៀងៗខ្លួន ។ ពេលនោះម៉ាក់ខ្ញុំបានដាស់ខ្ញុំឲ្យត្រឡប់ទៅវិញ ហើយពេលទៅដល់ភូមិត្រូវតែរៀបចំឥវ៉ាន់គេចខ្លួនភ្លាម ។ ម៉ាក់ឱបថើបថ្ពាសរបស់ខ្ញុំបីដង ហើយបាននិយាយផ្ដាំទៀតថា «ចាប់ពីពេលនេះតទៅកូនត្រូវចេះរស់ដោយខ្លួនឯង ហើយមិនដឹងពេលណាបានជួបគ្នាទៀតទេ! បើកូនមានពេលខស្សព្រាហ៍មកលេងនិងម៉ាក់ផង» ។ និយាយចប់ម៉ាក់ក៏បានដើរចេញទៅទាំងទឹកភ្នែករលីងរលោង ចំណែកខ្ញុំតាមសម្លឹងម៉ាក់ទាំងទឹកភ្នែកហូររហាមរហូតដល់បាត់ស្រមោលគាត់ក្នុងចំណោមមនុស្សដ៏កុះករ ។

ត្រឡប់ទៅភូមិបានប្រហែល២ថ្ងៃ ខ្ញុំក៏បានជួបនឹងបងប្រុសម្នាក់ដែលគាត់ជាប្រជាជនថ្មីដូចខ្ញុំដែរ ហើយគាត់ត្រូវទៅលើកទំនប់នៅកងចល័តស្រួចមួយដែលគេហៅថា «ទំនប់ដើមគបីដើម» ស្ថិតក្នុងស្រុកភ្នំជញ្ជាំង ខេត្តបាត់ដំបង ។ ខ្ញុំក៏បានសួរទៅគាត់ថា តើនៅក្នុងកងចល័តនោះមានក្មេងដែរទេ? គាត់ក៏ឆ្លើយថា មានប្អូនដប់នាក់ដែរ ព្រោះអីពួកគេមិនឲ្យមានក្មេងៗទេ ។ ខ្ញុំក៏បានឆ្លើយថា បើអ៊ីចឹងពេលបងឯងទៅវិញឲ្យខ្ញុំទៅជាមួយផង ព្រលឹមព្រឹកមួយនោះខ្ញុំក៏ភ្ជាក់ទៅជាមួយនឹងគាត់ ។

ភាពជាកុមាររបស់ខ្ញុំបានរស់នៅអណ្ដែតត្រសែតដូចចកក្នុងមហាជលសាដ៏ធំល្វឹងល្វើយមួយក្នុងចំណោមកុមារដប់នាក់ដទៃទៀតដែលស្ថិតនៅក្នុងកងចល័តស្រួចដើមគបីដើម ។ ខ្លួនខ្ញុំគ្មានសល់អ្វីទៀតទេ ក្រៅតែពីអាវពីរដែលជារបស់ម៉ាក់ខ្ញុំស្លាបព្រាមួយនិងកូនឆ្នាំងមួយតូចមានដៃសម្រាប់យួរទៅបើកបបរពេលថ្ងៃត្រង់និងពេលល្ងាចតែប៉ុណ្ណោះ ។ នៅក្នុងកងចល័តនោះ ខ្ញុំនិងកុមារដទៃទៀតត្រូវបានគេវាស់ដីឲ្យលើកជាភ្លឺស្រែក្នុងម្នាក់ៗ៥០ម៉ែត្រក្នុងមួយថ្ងៃ ឬឲ្យជីកដីលើកជាទំនប់ក្នុងទំហំដី១ម៉ែត្រគូបបីនាក់ក្នុងមួយថ្ងៃឲ្យហើយ ប្រសិនបើនរណាធ្វើមិនហើយទេនោះ គឺអ្នកនោះនឹងត្រូវកាត់របបមិនឲ្យហូប ឬក៏ដាក់ទារុណកម្មឲ្យធ្វើលុះត្រាតែរួចទើបបានឲ្យឈប់សម្រាក ។ ការរស់នៅក្នុងយុគសម័យដ៏ខ្មៅងងឹតនោះ ពីមួយថ្ងៃទៅមួយថ្ងៃមានរយៈពេលយូរដូចជាមួយសតវត្សរ៍ ខ្ញុំតែងតែចងចាំជានិច្ចនូវពាក្យសម្ដីនិងកាយវិការម៉ាក់ប៉ារបស់ខ្ញុំដែលបាននិយាយប្រាប់ខ្ញុំមុននឹងគាត់បែកពីរូបខ្ញុំថា «បើអស់ពីម៉ាក់ប៉ាទៅកូនត្រូវតែចេះរស់ដោយខ្លួនឯង» ។ តាំងពីខ្ញុំឃ្លាតពីម៉ាក់ខ្ញុំមក ខ្ញុំពុំដែលបានទទួលដំណឹងពីគាត់ទាល់តែសោះ ។ ក្នុងចិត្តខ្ញុំតែងតែគិតថា គាត់កំពុងតែមានជីវិតរស់នៅដូចគេដូចឯងនៅក្នុងភូមិ ។ គ្រាមួយ ខ្ញុំនិងមិត្តភក្តិពីរ-បីនាក់ទៀតបាននិយាយពីប្រវត្តិគ្រួសារឲ្យស្ដាប់ទៅវិញទៅមកថា «តើនៅពេលណាយើងនឹងបានជួបមុខម៉ែឪយើងវិញ» ។ ខណៈនោះមានបងប្រុសម្នាក់ដែលមានអាយុស្របាលនឹងបងប្រុសខ្ញុំដែរនោះបានដើរមកដល់ហើយ បានអង្គុយស្ដាប់ពួកយើងនិយាយគ្នាមួយសន្ទុះមក ទើបគាត់និយាយប្រាប់មកខ្ញុំថា គាត់បានដឹងថាម្ដាយរបស់ខ្ញុំ

ត្រូវបានគេយកទៅសម្លាប់ចោលបាត់ទៅហើយ ព្រោះអីគាត់ក៏ជាមនុស្សដែលនៅក្នុងភូមិជាមួយគ្រួសាររបស់ខ្ញុំដែរកាលពីមុន ហើយថ្មីៗនេះគាត់ទើបតែនឹងលួចរត់ទៅលេងម៉ែឪនៅភូមិ ។ ក្រោយពីខ្ញុំបានទទួលដំណឹងនេះភ្លាមទឹកភ្នែករបស់ខ្ញុំបានហូរធ្លាក់ដោយមិនដឹងខ្លួន ខ្ញុំមានអារម្មណ៍ថា ខ្ញុំអស់ហើយសម្រាប់ខ្លួនខ្ញុំគ្មានសល់អ្វីទៀតទេ សូម្បីតែរូបខ្លួនឯងក៏ពុំដឹងថាតើអាចមានជីវិតរស់នៅបានដែរឬអត់ផង ។ រហូតមកដល់ពេលនេះទើបខ្ញុំយល់ថា អ្វីដែលម៉ាក់ខ្ញុំផ្តាំគឺជាការពន្យាពនូវការសម្លាប់បំផុតពូជ ព្រោះបើពេលនោះខ្ញុំពុំបានលួចរត់មកនៅទីនេះទេនោះគ្រួសាររបស់ខ្ញុំនឹងត្រូវពួកវាសម្លាប់អស់គ្មានសល់ ។ ដោយសារតែការភ័យខ្លាចចំពោះសេចក្តីស្លាប់ទោះបីជាខ្ញុំបានទទួលដំណឹងថាម៉ាក់ខ្ញុំត្រូវបានពួកខ្មែរក្រហមសម្លាប់ក៏ដោយក៏ខ្ញុំពុំហ៊ានត្រឡប់ចូលទៅក្នុងភូមិដែលខ្ញុំធ្លាប់បានរស់នៅដើម្បីឲ្យបានដឹងច្បាស់ថាតើគាត់ស្លាប់មែនឬមិនមែន ប៉ុន្តែរហូតមកដល់ពេលនេះគឺនៅ តែបាត់ឈឹងរហូតៗ អស់រយៈពេលជាង ២០ឆ្នាំទៅហើយ ។

ដំណើររឿងដ៏ឈឺចាប់និងល្វីងជូរចត់នេះ គឺជាដំណើររឿងពិតមួយរបស់ក្មេងកំព្រាខ្មែរម្នាក់ក្នុងចំណោមក្មេងកំព្រាខ្មែររាប់ម៉ឺនរាប់សែននាក់ផ្សេងទៀត ដែលធ្លាប់បានឆ្លងកាត់នូវយុគសម័យដ៏ខ្មៅងងឹតមួយក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ប្រវត្តិជីវិតដែលប្រកបទៅដោយភាពឈឺចាប់ខ្លោចផ្សាទិរាសព្រាត់ប្រាសនេះត្រូវបានដក់ជាប់ក្នុងចិត្តរបស់ខ្ញុំជាអមតៈ ។

ចំពោះរូបខ្ញុំផ្ទាល់ ក្នុងនាមជាក្មេងកំព្រាម្នាក់ដែលជាជនរងគ្រោះ ខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំឲ្យមានតុលាការអន្តរជាតិមួយ ដើម្បីធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងឡាយ ដែលមានការជាប់ពាក់ពន្ធ័ទៅនឹងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាអំឡុងឆ្នាំ១៩៧៥-១៩៧៩ ដើម្បីស្វែងរកយុត្តិធម៌មួយផ្តល់ឲ្យប្រជាជនកម្ពុជាស្លូតត្រង់ដែលបានស្លាប់ដោយអយុត្តិធម៌បំផុតក្នុងអំឡុងពេលនៃរបបដ៏ព្រៃផ្សៃនោះ ។

**រស់ សមណ្ណារៈ ឌុឌ្ឍិ**



យោធាខ្មែរក្រហមពេលសម្រាកពីការងាររកជំទ័ត

# កោះខ្សាច់ទន្លេ កោះស្ត្រីមេម៉ាយ

ប្រទេសកម្ពុជាគឺជាកោះនៃស្ត្រីមេម៉ាយ ។ សម័យ ប៉ុល ពត បានបន្សល់ទុកនូវមរតកឈឺចាប់ជាច្រើន ។ មរតកមួយក្នុងចំណោមមរតកអនុស្សាវរីយ៍ដ៏ឈឺចាប់ទាំងអម្បាលម៉ាននៃរបបក្ងួរឲ្យរន្ធត់នោះគឺចំនួនស្ត្រីមេម៉ាយច្រើនឥតគណនាដែលត្រូវព្រាត់ប្រាសប្តីសី និងកូនជាទីស្រលាញ់របស់ខ្លួន ។ យោងតាមតួលេខរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិឃើញថា ២១ភាគរយនៃស្ត្រីខ្មែរ គឺជាស្ត្រីមេម៉ាយ ។

តើស្ត្រីមេម៉ាយទាំងនោះមកពីណាហើយមកពីមូលហេតុអ្វីបានជាស្ត្រីទាំងនោះធ្លាក់ខ្លួនទៅជាយ៉ាងនេះ?

ស្ត្រីចំនួនប្រាំរូបបានព្យាយាមឆ្លើយនូវសំណួរនេះដោយរៀបរាប់នូវរឿងរ៉ាវដូរចត់លំបាកវេទនា ការអត់ទ្រាំ និងការរស់រានមានជីវិតរបស់ខ្លួននៅលើកោះមួយ មានឈ្មោះថា «កោះខ្សាច់ទន្លេ» ដែលជាកន្លែងដែលស្ត្រីមេម៉ាយរស់នៅដល់សព្វថ្ងៃ ជាកន្លែងដែលត្រូវបានធ្វើឲ្យកំព្រាឯកោ និងពេលខ្លះត្រូវបានធ្វើឃាត ។ រឿងរ៉ាវទាំងនេះបានបង្ហាញអំពីការព្យាយាមដាច់ខាតរបស់ពួកខ្មែរក្រហមក្នុងការបំបែកបំបាក់ទំនាក់ទំនងគ្រួសារ ហើយនិងទំនាក់ទំនងជាប្រពៃណីដែលកើតមានរវាងប្តីនិងប្រពន្ធ និងរវាងម្តាយនិងកូននៃជនជាតិកម្ពុជា ។ ដោយត្រូវបានបោះបង់ចោលដោយអនាគតអាប់អួរ ស្ត្រីមេម៉ាយទាំងនោះមានចម្ងល់ថាតើអ្នកណានឹងសងសឹកហើយចងចាំនូវរឿងរ៉ាវដែលកើតឡើងទាំងអម្បាលម៉ានចំពោះរូបខ្លួន ។

នៅមុនឆ្នាំ១៩៧៥ ធីតា និងស្វាមី រស់នៅក្នុងទីក្រុងភ្នំពេញ ។ ធីតា ប្រកបការងាររលក់ដូរបន្តិចបន្តួចនៅក្នុងផ្សារ ពេលនោះប្តីរបស់នាងធ្វើជាអ្នកបម្រើការក្នុងសណ្ឋាគារមួយ ។ នៅពេលដែលពួកខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញនិងជម្លៀសប្រជាជននៅទីក្រុងទាំងកម្រោលនោះ ធីតា និងប្តីត្រូវបានជម្លៀសឲ្យទៅនៅឯស្រុកកំណើតរបស់ខ្លួនវិញនៅសិត្បូ ។ នៅទីនោះ ធីតា ត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់នៅឯបឹងត្នោត ព្រោះគាត់ស្ថិតក្នុងប្រភេទ «កម្លាំងស្រួច» ព្រមទាំងបង្ខំឲ្យរែកដីពីបឹងត្នោតទៅកាន់ទំនប់ទួលក្រសាំងក្នុងខណៈដែលប្តីរបស់នាងធ្វើការនៅចន្ទ័សាឈៀងដោយភ្ជួរស្រែនៅពេលយប់និងរែកដីនៅពេលថ្ងៃ ។ ប្តីប្រពន្ធទាំងពីនាក់កម្របានជួបមុខគ្នាណាស់ចាប់តាំងពីពេលដែលមានចេញនយោបាយមួយអនុញ្ញាតឲ្យប្តីប្រពន្ធជួបគ្នាតែម្តងក្នុងមួយសប្តាហ៍មក ។ ពេលដែលបានជួប



គ្នាម្តងៗ ប្តីធីតាតែងតែជួយបំពេញការងាររបស់ប្រពន្ធខ្លួនដែលអង្គការបាន១កំណាត់៥ម៉ែត្រការ៉េក្នុងមួយថ្ងៃ ដើម្បីធ្វើឲ្យពួកខ្លួនអាចមានឱកាសរួមមេត្រីជាមួយគ្នា មុនពេលដែលត្រូវបែកគ្នានាពេលព្រឹកព្រលឹម ។ ធីតាមានឱកាសបានជួបប្តីរបស់គាត់បានតែ៩លើកប៉ុណ្ណោះ មុនពេលដែលប្តីរបស់គាត់បាត់

ស្រមោលពីជីវិតរបស់គាត់ទៅ ។ នៅខែមីនា ឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានមកចាប់អូសប្តីរបស់គាត់ពីកន្លែងធ្វើការ នៅពេលល្ងាច ហើយនាំយកទៅកាន់កោះគរដែលជាគុក និងជាកន្លែងសម្លាប់ធំជាងគេទាំងអស់នៅក្នុងស្រុកស្អាង ។ ពួកវាបានចោទប្រកាន់គាត់ថាជាអនុសេនីយ៍ឯកបម្រុងស័ក្តិពីរកន្ទះ ក្នុងរបបសាធារណរដ្ឋ ។ នៅក្នុងសម័យ ប៉ុល ពត ទាហាន មន្ត្រីយោធា បុគ្គលិករាជការ និងអ្នកដែលមានការចំណេះដឹងខ្ពស់ៗ ត្រូវបានចាត់ទុកជាសត្រូវដាច់ខាតរបស់របបនោះ ហើយដាច់ខាតត្រូវតែកម្ចាត់ចោល ។ ទោះបីជាប្តីរបស់ ធីតា ជាអ្នកបម្រើ



ការងារពេលកម្មរបស់ស្ត្រីក្នុងរបបខ្មែរក្រហម

ការងារក្នុងសណ្ឋាគារក៏ដោយ ក៏ទំនាក់ទំនងរបស់គាត់ទៅនឹងជីវិតទីក្រុងនាំឲ្យគាត់ក្លាយជាមុខសញ្ញាត្រូវសម្លាប់ដែរ ។ ធីតា មិនបានទៅជួបប្តីនៅពេលដែលគាត់ត្រូវនាំយកទៅនោះទេ តែ ធីតា ព្រមទាំងកូនត្រូវទទួលរងនូវផលវិបាកនៃការសម្លាប់នោះ ។ សូម្បីតែនៅមុនពេលពួកខ្មែរក្រហមបញ្ជូនខ្លួនទៅកាន់កោះខ្សាច់ទន្លេនោះក៏ដោយ ក៏នាងនិងកូនត្រូវបានទទួលរងនូវភាពជូរចត់នៃការមើលងាយ មើលថោកពីសំណាក់អង្គការរួចស្រេចទៅហើយ ។ ពួកខ្មែរក្រហមបានបង្ខំឲ្យនាងនិងកូនកាប់ដីតាមផែនការអង្គការកំណត់ ហើយទទួលនូវការងារដ៏ធ្ងន់ធ្ងរបំផុត ហើយសូម្បីតែរបបអាហារក៏នាងបានទទួលខុសពីអ្នកដទៃដែរ ។ ថ្វីត្បិតតែនាងគ្មានប្តីនៅជិតក្តី ក៏នាងនៅតែបន្តការងារដ៏ធ្ងន់ធ្ងរនោះដដែល ។ នាងបានពោលថាៈ បើអ្នកឯងមិនធ្វើការគេនឹងសម្លាប់អ្នកឯងចោលភ្លាម ។ ដូចឃើញស្រាប់ គេបានសម្លាប់ប្តីអ្នកឯងចោលបាត់ទៅហើយ ។ ប៉ុន្តែគេមិនឲ្យអ្នកឯងយំដាច់ខាត ។ បើអ្នកណាហ៊ានយំនឹងត្រូវសម្លាប់ចោល ។

ដូច ធីតា អ៊ីចឹងដែរ ចន្ទូ មានដើមកំណើតនៅភូមិសិត្បូ ។ នៅពេលដែលពួកខ្មែរក្រហមមកយកប្តីខ្លួនទៅ ចន្ទូ បានទួញសោកម្នាក់ឯង ។ ក្នុងអំឡុងពេលប៉ុន្មានខែនៃការច្បាំងគ្នានោះ ចន្ទូ បាននាំគ្រួសារមកកាន់ភ្នំពេញមុនពេលដែលនាងត្រូវជម្លៀសមកកាន់ភូមិកំណើតរបស់នាងវិញនៅក្នុងឆ្នាំ១៩៧៥ ។ ចន្ទូ ជាស្ត្រីមេម៉ាយកូនមួយ មុនថ្ងៃដែលគាត់ត្រូវអង្គការបានបង្ខំឲ្យរៀបការម្តងទៀត ។ គាត់ពិតជាមិនចង់រៀបការម្តងទៀតឡើយ ប៉ុន្តែ ចន្ទូ ត្រូវតែបង្ខំចិត្ត ព្រោះ ចន្ទូ ដឹងប្រាកដថាបើនាងមិនធ្វើដូច្នោះទេ នាងនឹងត្រូវទទួលនូវផលវិបាកជាមិនខាន ។ ចន្ទូ និយាយថា «ក្នុងចិត្តខ្ញុំ ខ្ញុំមិនចង់រៀបការទេ តែបើយើងមិនធ្វើតាមគេនឹងសម្លាប់យើងចោលភ្លាម ។ ដូច្នេះបើយើងមិនចង់ស្លាប់ត្រូវតែបង្ខំចិត្តរៀបការ» ។ ក៏ដូចជា ធីតា អ៊ីចឹងដែរ ចន្ទូ បានជួបមុខប្តីរបស់នាងតែម្តងប៉ុណ្ណោះក្នុងមួយសប្តាហ៍ឬ១០ថ្ងៃ ។ ការជួបគ្នារវាងប្តីប្រពន្ធនាងត្រូវបានពួកខ្មែរក្រហមចាំឃ្លាំមើល ពោលគឺមិនអាចជួបគ្នាដោយសេរីបានទេ ។ ពេលដែលយើងចេញទៅធ្វើការយើងជួបគ្នាធម្មតា តែមិនត្រូវបានអនុញ្ញាតឲ្យនិយាយគ្នាទេ សូម្បីតែពាក្យមួយម៉ាត់ក៏មិនបានដែរ ។ យើងចេះតែលួចមើលគ្នាទៅវិញទៅមក ប៉ុន្តែពួកខ្មែរក្រហមមិនឲ្យយើងនិយាយគ្នាទេ ។ អាពាហ៍ពិពាហ៍រាប់ពាន់គូត្រូវបានគេរៀបចំឡើងនៅក្នុងសម័យប៉ុលពត ប៉ុន្តែវាមិនច្បាស់ទាល់តែសោះ ហេតុអ្វីបានជាប្រជាជនត្រូវបានបង្ខំឲ្យរៀបការជាមួយគ្នាទាំងមិនពេញចិត្ត និងជូនកាលក្រោយពីរៀបការហើយត្រូវបំបែកចេញពីគ្នានោះ ។ ចន្ទូ

បានទទួលរងនូវកម្មនេះពេលដែលនាងមានផ្ទៃពោះ៧ខែ ។ នៅឆ្នាំ១៩៧៧ ចន្ទូ បានជួយលើកទំនប់នៅបឹងត្នោតក្នុងខណៈដែលប្តីរបស់គាត់ត្រូវបានបញ្ជូនទៅកោះគរ ។ មួយសប្តាហ៍ក្រោយមកទើបគាត់ដឹងថាប្តីរបស់គាត់បានបាត់ខ្លួន ។

តែផ្ទុយទៅវិញ ដាវី បានឃើញប្តីរបស់គាត់ត្រូវបានពួកខ្មែរក្រហមចាប់យកទៅ ហើយគាត់បានតវ៉ាប្រឆាំងនឹងនយោបាយរបស់អង្គការទៀតផង ។ ដាវី គឺជា«អ្នកមូលដ្ឋាន» ដែលរស់នៅព្រែកអំពិលចាប់តាំងពីគាត់រៀបការហើយម្ល៉េះ ។ ប្តីរបស់គាត់ក្រ ហើយមានសុខភាពខ្សោយ ហើយប្តីប្រពន្ធមួយគូនេះរស់នៅក្នុងកូនខ្ទមមួយនៅក្នុងភូមិ ។ អ្នកទាំងពីរចិញ្ចឹមទាគ្រាន់តែផ្គត់ផ្គង់ជីវភាពគ្រួសារ ហើយមានឈើមួយចំនួនដែលខ្លួនខំសន្សំទុកសម្រាប់ធ្វើផ្ទះ ។ ក្នុងឆ្នាំ១៩៧៨ កងឈ្លបបានមកសុំទានិងឈើរបស់ ដាវី ។ ពេលនោះ ដាវី បានបដិសេធ ព្រោះគាត់មានតែរបស់ប៉ុណ្ណឹងសម្រាប់រស់និងធ្វើផ្ទះនៅ ។ ពីរបីថ្ងៃក្រោយមក ពួកឈ្លបបានមកយកប្តីគាត់ទៅដោយនិយាយថាៈ «យើងគ្រាន់តែមកយកគាត់ទៅអប់រំប៉ុណ្ណោះ» ។ ដាវីបានយល់នូវផលវិបាកនៃពាក្យថា «អប់រំ» នេះស្រេចបាត់ទៅហើយ ។ «អប់រំ មិនឆាប់ប៉ុន្មានទេ ។ ខ្ញុំដឹងថា បើប្តីខ្ញុំទៅគាត់នឹងទៅរហូតគ្មានថ្ងៃត្រឡប់មកវិញទេ» ។ ដាវី បានសួរពួកឈ្លបថា ពេលដែលយកប្តីគាត់ទៅ តើមានអ្នកណាជួយចិញ្ចឹមបីបាច់កូនគាត់ទាំង៤ទេ ។ អង្គការបានឆ្លើយតបវិញថា «អង្គការនឹងទទួលរាប់រងកិច្ចការទាំងនេះ» ។ នៅក្នុងសម័យ ប៉ុល ពត ការទាក់ទងគ្នាត្រូវបានកាត់ផ្តាច់ គ្រួសារត្រូវបានបំបែក ហើយអារម្មណ៍និងមនោសញ្ចេតនាត្រូវបាត់បង់អស់ ។ អង្គការក្លាយជាឪពុកម្តាយ ប្តី និងគ្រួសារ ដែលម្នាក់ៗត្រូវតែដាច់ខាតប្តេជ្ញានិងប្រគល់ភក្តីភាពជូន ។ ដាវី បានបដិសេធមិនព្រមទទួលយកនូវការពិតនេះឡើយ ។ ដាវី ប្រឆាំងដាច់ខាត ហើយហ៊ានឲ្យពួកឈ្លបទាំងនោះសម្លាប់គ្រួសារនាងទាំងមូលទៀតផង ។ «ម្តេចមិនបាញ់សម្លាប់មនុស្សទាំងអស់នៅក្នុងគ្រួសារនេះឲ្យអស់ទៅ ។ បាញ់សម្លាប់ខ្ញុំ កូន និងប្តី ឲ្យអស់តែម្តងទៅ ព្រោះបើអង្គការយកប្តីខ្ញុំទៅ ខ្ញុំក៏នឹងត្រូវដាច់ពោះស្លាប់ដែរ» ។ មានប្រជាជនភាគតិចណាស់ដែលហ៊ានចេញមុខប្រឆាំងដូចជា ដាវី ។ ពេលដែលខ្ញុំសួរថា តើហេតុអ្វីបានជាអ្នកទាំងនោះមិនហ៊ានប្រឆាំងនឹងអង្គការ? ធីតា បានឆ្លើយថា តើយើងរត់តាមផ្លូវណា? បើយើងរត់គេនឹងដាក់ទោសរឹតតែខ្លាំង ហើយសូម្បីតែកូនយើងក៏នឹងត្រូវប៉ះពាល់ដែរ ។ ខ្ញុំប្រាប់ទៅ បើប្តីយើងហ៊ានប្រឈមមុខតបតនឹងពួកវា គាត់អាចរស់តែ តែខ្លាចបាត់បង់គ្រួសារ ដោយពួកវាបានគំរាមថា បើប្តីនាងឯងហ៊ានជំទាស់ យើងនឹងយកទាំងគ្រួសារតែម្តង» ។ ត្រង់ចំណុចនេះប្តីខ្ញុំពិតជាមិនហ៊ានជំទាស់ឡើយ ។ ប៉ុន្តែ ធីតា បានបន្ថែមយ៉ាងលឿនថាៈ «បើយើងបានដឹងថាធ្វើយ៉ាងម៉េចក៏ស្លាប់ដែរនោះ យើងពិតជាហ៊ានប្រឆាំងមិនខានឡើយ» ។ ប្តីរបស់ ដាវី មិនហ៊ានជំទាស់ឡើយ គាត់ស៊ូលះបង់ខ្លួនដើម្បីគ្រួសារទាំងមូល ។

ការឈានដើងឃ្លាតពីគ្រួសាររបស់ប្តីគាត់ បុប្ផ មានភាពសោកសៅតិចជាងអ្នកដែលបានរៀបរាប់ខាងលើ ។ បុប្ផារស់នៅទីក្រុងភ្នំពេញតែមួយរយៈខ្លីប៉ុណ្ណោះមុនពេលដែលត្រឡប់ទៅស្រុកកំណើតវិញនៅភូមិស្វាយប្រទាល ។ ពេលត្រឡប់មកវិញ ប្តី បុប្ផា បានដាំបន្លែ ហើយគាត់ធ្វើការនៅក្បែរភូមិដែលខ្លួនរស់នៅ ។ នៅម៉ោង៧ព្រឹក ឆ្នាំ១៩៧៧ គឺជាពេលដែលពួកខ្មែរក្រហមមកហៅប្តីគាត់ពីផ្ទះ ។ ពេលនោះបុប្ផាមានផ្ទៃពោះ២ខែ ។ ពួកវាបានប្រាប់គាត់ ពួកខ្មែរក្រហមមកយកប្តីគាត់ទៅជួយភ្ជួរស្រែ ។ ល្បិចបែបនេះនាំឲ្យគាត់នឹកដល់បងប្រុសរបស់គាត់ដែលត្រូវបាននាំយកទៅកាលពីឆ្នាំ១៩៧៦ កាលណោះពួកវាបានប្រើវិធីនេះដែរ ។ ពួកខ្មែរក្រហមបានប្រើកលល្បិចច្រើនណាស់ក្នុងការបោកបញ្ឆោតបង្វែងការពិតចំពោះសមាជិកគ្រួសារប្រជាជនខ្មែរ ។ ពួកខ្មែរក្រហមមិនត្រឹមតែប្រើតែល្បិចយកមនុស្សទៅអប់រំតែមួយប៉ុណ្ណោះទេ តែពួកវានៅមានប្រើកលល្បិចបោកបញ្ឆោតជាច្រើនផ្សេងទៀត ។ ធីតា បាននិយាយថាៈ «ពួកវាអាចគ្រាន់តែមកទល់មុខយើងហើយនិយាយថាតោះយកបង្គីមក» ។ ពេលដែលយើងដើរទៅយកបង្គីនោះយើងដឹងបាត់ទៅហើយថាយើងពិតជាត្រូវវាសម្លាប់ ។ ពេលដែលប្តីរបស់ បុប្ផា ចាកចេញទៅគាត់ក៏បានដឹងខ្លួនឯងហើយដែរថាខ្លួននឹងត្រូវសម្លាប់ ។ ដូច្នេះគាត់មិនបានយករបស់របរទៅតាមខ្លួនឡើយ ។ គាត់បានទុករបស់ទាំងអស់ឲ្យប្រពន្ធ ដោយដឹងថាគាត់ពិតជាគ្មានឱកាសវិលត្រឡប់មកជួបជុំគ្រួសារវិញឡើយ ។ មួយខែក្រោយមកបុប្ផាក៏រលូតកូនដោយសារការ

ជីកប្រឡាយ ។

សុភាព ក៏មានផ្ទៃពោះ២ខែដែរ នៅខណៈដែលប្ដីរបស់គាត់ត្រូវពួកខ្មែរក្រហមនាំយកទៅ ។ នៅក្នុងឆ្នាំ១៩៧៥ សុភាព និងប្ដីត្រូវបានជម្លៀសពីភ្នំពេញដែលជាកន្លែងប្ដីរបស់គាត់ធ្វើជាជាងជួសជុលម៉ូតូ ។ ពីរនាក់ប្ដីប្រពន្ធនេះបានត្រឡប់ដល់ភូមិកំណើតនៅភូមិស្វាយប្រទាល ដោយនាំយកមកជាមួយនូវកូនមួយដែលទើបតែអាយុ២០ថ្ងៃប៉ុណ្ណោះ ។ សុភាព និងប្ដី ត្រូវបានបំបែកឲ្យធ្វើការនៅកន្លែងផ្សេងពីគ្នា ។ សុភាព ធ្វើការនៅកងចល័តនារីដែលមានប្ដី «កងចល័តនារី» ដកស្ទូងស្រូវ ហើយនិងកាប់ព្រៃ ។ ពេលនោះប្ដីរបស់គាត់ធ្វើការនៅកងចល័តភ្ជួររាស់ ។ ពេលដែលពួកខ្មែរក្រហមមកយកប្ដីគាត់ទៅកោះគរនោះ គឺថ្ងៃជ្រេបន្តិចទៅហើយ ។ សុភាព មើលមិនឃើញគេយកប្ដីគាត់ទៅឡើយ ។ ក្នុងខណៈនោះមិនមែនមានតែប្ដីគាត់ម្នាក់ប៉ុណ្ណោះទេ មានមនុស្ស៤-៥នាក់រួមជាមួយដែរ ។ ករណីនេះដូចជាករណីដែលកើតឡើងចំពោះ បុប្ផា ដូច្នោះដែរ ពោលគឺពួកវានិយាយថា «យកគាត់ទៅភ្ជួរស្រែ និងជីកខស» ។

មិនយូរប៉ុន្មានក្រោយពីពេលដែលប្ដីត្រូវបានបញ្ជូនទៅដាក់គុកនៅឯកោះគរមក ស្ត្រីទាំងប៉ុន្មានដែលបានរៀបរាប់ខាងលើក៏ត្រូវបានបញ្ជូនទៅកាន់កោះខ្សាច់ទន្លេ ។ ស្ត្រីទាំងនោះមានការប្រាកដក្នុងចិត្តថា ខ្លួនពិតជាមិនមានថ្ងៃបានជួបប្ដីវិញឡើយ មិនមែនពីព្រោះតែកោះគរជាកន្លែងដែលមិនសូវមានការសម្លាប់មនុស្សទេ ហើយក៏មិនមែនដោយសារតែកោះខ្សាច់ទន្លេជាកោះសម្រាប់ស្ត្រីដែរ ។ បុប្ផា ពោលថាៈ «ខ្ញុំមិនអាចនិយាយថាយើងអាចជួបគ្នាវិញនោះទេ» ។ «ពេលដែលពួកខ្មែរក្រហមនាំយកគាត់ទៅកន្លែងនោះ...កន្លែងនោះពោរពេញទៅដោយស្ត្រីមេម៉ាយ» ។

ពេលដែលពួកខ្មែរក្រហមយកទៅដាក់កោះខ្សាច់ទន្លេនោះ សុភាព ហៀបតែនឹងឆ្លងទន្លេទៅហើយ ។ ពួកខ្មែរក្រហមបានប្រាប់គាត់ថាពួកគេនាំយកគាត់ទៅជួបប្ដី ។ «ពេលដែលខ្ញុំចេញទៅ ខ្ញុំមិនដឹងថាពួកខ្មែរក្រហមនាំយកខ្ញុំមកកាន់កោះនេះឡើយ ។ ទើបតែក្រោយពេលចេញទូកទើបដឹងច្បាស់ ។ ពេលមកយកខ្ញុំ ពួកខ្មែរក្រហមមិនបានប្រាប់ថាតើទៅណាមកណាឡើយ ។ ខ្ញុំចេះតែដើរៗទៅ ។ ពួកវានិយាយថា «យើងយកនាងទៅជួបប្ដី» ។ ពេលនោះខ្ញុំដឹងថាពួកវាពិតជានិយាយកុហក ។ តាមពិតប្ដីរបស់ខ្ញុំត្រូវវាសម្លាប់ចោលបាត់ទៅហើយ ។ ពួកវាបានប្រមូលស្ត្រីមេម៉ាយទាំងអស់ ។ ម្នាក់ៗដែលប្ដីរបស់ខ្លួនត្រូវបានសម្លាប់នោះសុទ្ធតែត្រូវបានបញ្ជូនមកកាន់កោះនេះ ។ ពួកខ្មែរក្រហមក៏បានប្រាប់ ធីតា ដែរថាពួកវាយកនាងទៅជួបប្ដី ។ ពេលនោះ ធីតា មានការសប្បាយចិត្តយ៉ាងខ្លាំង ហើយខំដើរយ៉ាងប្រញាប់ប្រញាល់ដោយឆ្លៀតប្រាប់កូនថា «ដើរឲ្យស្រួលបួលកូន ។ យើងទៅជួបប៉ាយើង... យើងទៅជួបប៉ាយើង ។ មើលនោះហ្ន៎ ប៉ាកូនកំពុងរង់ចាំយើងហើយ» ។ ពេលដើរតាមផ្លូវ ធីតា បានឃើញស្ត្រីជាច្រើនធ្វើដំណើរកាត់ទន្លេ ។ ប៉ុន្តែគ្មានឃើញបុរសម្នាក់សោះ ។ «ពេលណាដែលខ្មែរក្រហមនាំគាត់ទៅកន្លែងណាមួយ ពួកខ្មែរក្រហមតែងតែនិយាយថាទៅជួបប្ដី ។ ទៅដល់នោះទៅជួបហើយ ។ ពុ្ ដូច្នេះពួកយើងទាំងអស់មានការរីករាយមែនទែន ។ ប៉ុន្តែសូម្បីតែរាត្រីឈានមកដល់ក៏ខ្ញុំមិនដឹងថាប្ដីខ្ញុំទៅទីណាឡើយ» ។

ស្ត្រីទាំង៥រូបមិនដែលបានជួបប្ដីរបស់ខ្លួនឡើយ ប៉ុន្តែជួបស្ត្រីជាច្រើននៅលើកោះដែលប្រឈមមុខនឹងវាសនាដូចៗគ្នា ។ គ្មានភាពប្រាកដប្រជាឡើយថាតើស្ត្រីទាំងអស់នេះមកពីណា ប៉ុន្តែគ្រាន់តែដឹងថាមានស្ត្រីរាប់ពាន់នាក់នៅទីនោះ ។ ចន្ទ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយដឹងថានៅលើកោះមានស្ត្រីម៉េមាយច្រើនយ៉ាងនេះ ។ ស្ត្រីម្នាក់ៗសុទ្ធតែមានវិបត្តិម៉្យាងដូចគ្នា ។ ស្ត្រីទាំងនោះគឺជាស្ត្រីមេម៉ាយដែលត្រូវបានបោះបង់ចោលនៅលើកោះដោយសារតែការជាប់ទាក់ទងជាមួយប្ដីរបស់ខ្លួនដែលពួកខ្មែរក្រហមមានមន្ទិលសង្ស័យតែប៉ុណ្ណោះ ។ ពេលដែលសុភាព ទៅដល់កោះនោះ មេកងបានប្រកាសថា «អ្នកដែលមកដល់កោះនេះមានបានដឹងរឿងទេ? អ្នកឯងទាំងអស់គ្នាសុទ្ធតែជាប្រពន្ធទាហាន និងតម្រួតយោធា ។ យើងនាំអ្នកទាំងអស់មកដាក់នៅទីនេះ» ។ សុភាព បានពោលអះអាងថា គ្មានប្រពន្ធទាហានឬតម្រួតយោធាឯណានៅលើកោះនេះឡើយ ។ ស្ត្រីនៅទីនេះសុទ្ធតែជាប្រជាជនសាមញ្ញតែប៉ុណ្ណោះ ។ ការលើកហេតុផលបែបនេះរបស់ខ្មែរក្រហមទោះជាយ៉ាងណាក៏ដោយក៏ជាការបង្ហាញយ៉ាងងាយអំពីគម្រោងនៃការបែងចែកមនុស្សទៅតាមប្រភេទ ។ **(នៅមានត)** **ម៉ម កល្យានី**

ចម្រៀងខ្មែរក្រហម

## ១៧មេសា កម្ពុជារំដោះ

# ប្តេជ្ញារៀនសូត្រគំរូមិត្តយើងដ៏រុងរឿង

ស. ១៧មេសាកម្ពុជារំដោះ សម្រែកជយឃោសក្រើកមេឃា
ដុំពកខ្មៅរលាយហើយណា រស្មីភ្លឺថ្លាកិត្តិយសចាំងចែង ។
ប. ទំព័រខ្ញុំគេត្រូវបិទជាអវសាន បងប្អូនគ្រប់ប្រាណធ្វើម្ចាស់ខ្លួនឯង
អត្តភាពកម្ពុជាចោលឆ្ងាយក្រៃលែង មិត្តយើងស្ងប់ស្ងែងពាសពេញក្នុងលោក ។
ស. នេះគឺមកពីវីរភាពខ្ពង់ខ្ពស់ យុទ្ធមិត្តទាំងអស់បានវាយសម្រុក
ទ្រាំទ្រវេទនាលំបាកសព្វមុខ លះបង់ទាំងគ្រប់លះបង់ជីវី ។
ប. យើងខ្ញុំឃើញច្បាស់វីរភាពយុទ្ធមិត្ត ជាងប្រាំឆ្នាំពិតទាំងយប់ទាំងថ្ងៃ
តទល់អាខ្មាំងមេក្លោងលើដី លុះដណ្តើមជ័យជាអវសាន្ត ។
ស. យុទ្ធមិត្តតស៊ូត្រាំទឹករាល់ថ្ងៃ អត់បាយផ្សាផ្ទៃនៅក្នុងលេណដ្ឋាន
មិត្តចូលប្រយុទ្ធរថក្រោះសាមាន្យ មិត្តវាយផ្ទាល់ប្រាណតទល់ចោរខ្មាំង ។
ប. យុទ្ធមិត្តប្រយុទ្ធហែលឆ្លងទន្លេ ទៅវាយបនក្លែព្រៃផ្សែហនេយ្យុំ
យុទ្ធមិត្តហៀវហោះចរចេញតតាំង វាយចោរអាគាំងកណ្តាលសមុទ្រ ។
ស. យុទ្ធមិត្តប្រយុទ្ធអស្ចារ្យក្នុងគុក ទោះខ្មាំងធ្វើទុក្ខទារុណកម្មបំផុត
វាដាក់ខ្សែភ្លើងក៏មិត្តគ្មានស្លុត រក្សាសម្ងាត់លុះក្ស័យជីវី ។
ប. យើងខ្ញុំចាំច្បាស់ឈាមស្រស់យុទ្ធមិត្ត ក្រហមឆ្អៅពិតស្រោចស្រពប្រថពី
ជាង៥ឆ្នាំនេះជាទំព័រថ្មី ភ្លឺផ្លេកពណ្ណរាយកម្ពុជាបដិវត្តន៍ ។
យើងខ្ញុំប្តេជ្ញារាបសារៀនសូត្រ គំរូយុទ្ធមិត្តរុងរឿងបំផុត
ហើយដើរតាមផ្លូវយុទ្ធមិត្តរហូត ធ្វើបដិវត្តលុះទីអវសាន្ត ។
សាងកម្ពុជាជាទីស្នេហា ឲ្យប្រែក្លាយជារមណីយដ្ឋាន
សម្បូរសប្បាយរុងរឿងថ្កើងថ្កាន បងប្អូនគ្រប់ប្រាណសុខសួស្តីអើយ ។

**កត់ត្រាចងក្រងជាឯកសារ**

**កញ្ញា សើ សាយ្យាណា**

***ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃ ដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ទស្សនាវដ្តីចំនួន១០០០ក្បាលជារៀងរាល់លេខ នឹងដាក់លក់តាមបណ្តាទីរួមខេត្តនិងក្រុង មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល***

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 4, April 2000
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; and the Canada Funds, Canadian Embassy, Phnom Penh, Cambodia